KINGDOM OF CAMBODIA



# ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និង ជំនួយសម្រាប់ពាណិជ្ជកម្ម នៅប្រទេសកម្ពុជា



**Ministry of Commerce**
Phnom Penh, July 2011

KINGDOM OF CAMBODIA

# ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម
# និង ជំនួយសម្រាប់ពាណិជ្ជកម្ម
# នៅក្នុងប្រទេសកម្ពុជា

ក្រសួងពាណិជ្ជកម្ម
រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១១

# បុព្វកថា

ធ្វើនៅភ្នំពេញ
ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១១

ប្រទេសកម្ពុជា បានទទួលផលប្រយោជន៍យ៉ាងច្រើនពីជំនួយបច្ចេកទេសទាក់ទងនឹងវិស័យពាណិជ្ជកម្មដែលបានផ្តល់ឲ្យដោយដៃគូអភិវឌ្ឍន៍របស់ខ្លួន។ ជំនួយសម្រាប់ពាណិជ្ជកម្មនេះបានជួយឲ្យ ប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងក្លាក្នុងការពង្រីក និងការធ្វើពិពិធកម្ម( ឲ្យមានភាពសម្បូរបែប )នៃវិស័យនាំចេញរបស់ខ្លួន។ ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម គឺជាយន្តការដ៏សំខាន់នៃយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រជារួមរបស់ប្រទេសកម្ពុជា និងវត្ថុបំណងនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDG) ដូចបានចែងនៅក្នុងយុទ្ធសាស្រ្តចតុកោណរបស់រដ្ឋាភិបាល និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។

នៅក្នុងបរិបទនៃការពិនិត្យឡើងវិញជាសកលលើកទី៣ នៃជំនួយសម្រាប់ពាណិជ្ជកម្មដែលបានរួមគ្នារៀបចំរបស់អង្គការពាណិជ្ជកម្មពិភពលោក ( WTO ) និងអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ( OECD ) នៅ ( ទីក្រុងហ្សឺណែវខែកក្កដាឆ្នាំ២០១១ ) ប្រទេសកម្ពុជាបានឆ្លើយតបទៅនឹង ការអំពាវនាវដែលធ្វើឡើយដោយអង្គការទាំងពីរនេះ និងបានរៀបចំ"ករណីសិក្សា" ចំនួន ៥ នៃជំនួយសម្រាប់ពាណិជ្ជកម្ម។ សព្វថ្ងៃនេះ ករណីសិក្សាទាំងនោះត្រូវបានដាក់បញ្ចូលនៅក្នុងគេហទំព័ររបស់សន្និសីទហើយ។

យ៉ាងណាមិញ ប្រទេសកម្ពុជាយល់ឃើញថា វានឹងមានប្រយោជន៍ចំពោះអ្នកដទៃទៀតដែលមានចំណាប់អារម្មណ៍ទៅលើការសិក្សាពីបទពិសោធន៍របស់វាដើម្បីប្រមូលផ្តុំករណីសិក្សាទាំង ៥ នេះឲ្យទៅជាឯកសារតែមួយនិងដាក់វាទៅក្នុងបរិបទកាន់តែធំមួយនៃជំនួយសម្រាប់ពាណិជ្ជកម្មសម្រាប់ប្រទេសនេះ។ នេះគឺជាគោលបំណងនៃការបោះពុម្ពផ្សាយឯកសារខ្លីនេះ។

ដូចបានបញ្ជាក់នៅក្នុងករណីសិក្សាដែលមានក្នុងឯកសារនេះ ប្រទេសកម្ពុជាបានធ្វើឲ្យមានការរីកចម្រើនយ៉ាងធំ លើការធ្វើកំណែទម្រង់ច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងអាជីវកម្មបន្ទាប់ពីបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ( WTO )។ ដោយសារមានការអនុវត្តការគ្រប់ហានិភ័យ និង ASYCUDA ដំណើរការ និងការត្រួតពិនិត្យពន្ធគយមានភាពប្រសើរឡើងយ៉ាងខ្លាំង ហើយពេលវេលាក្នុងការដោះដូរការនាំចេញ និងការនាំចូលត្រូវបានកាត់បន្ថយជិតពាក់កណ្តាល។ ការវិនិយោគដោយផ្ទាល់ពីបរទេសបានកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២០០០ នេះ។ មូលដ្ឋាននៃការនាំចេញរបស់យើងកំពុងត្រូវបានធ្វើពិពិធកម្មជាមួយនឹងការរីក ចម្រើនយ៉ាងធំលើការនាំចេញអង្ករ ដំឡូងមី ជ័រកៅស៊ូ គ្រាប់ស្វាយចន្ទី សូត្រ និងវិស័យផ្សេងៗទៀត ដោយមានឥទ្ធិពលជាវិជ្ជមាន យ៉ាងខ្លាំងលើជនក្រីក្រ។ យើងក៏កំពុងព្យាយាមធ្វើការយ៉ាងខ្លាំងផងដែរ ដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាល ដើម្បីផ្តល់សេវាកាន់តែប្រសើរទៅដល់អ្នកនាំចេញជាមួយនឹងការផ្តល់ព័ត៌មានដ៏ទូលំទូលាយអំពី សេដ្ឋកិច្ចកាន់តែប្រសើរឡើង។ ការអភិវឌ្ឍជាច្រើនក្នុងចំណោមការអភិវឌ្ឍទាំងនេះគឺបានមកពីកិច្ចសហប្រតិបត្តិការវិជ្ជមានរវាងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាជាមួយនឹងដៃគូអភិវឌ្ឍន៍នានា។

សរុបមក ខ្ញុំសូមថ្លែងអំណរគុណចំពោះការផ្តល់ជំនួយគាំទ្ររបស់កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម ( EIF ) Tier 1 ហើយបើមិនមានជំនួយគាំទ្រនេះទេ ការងារទៅលើករណីសិក្សាដំបូងទាំងនេះ និងការបោះពុម្ពផ្សាយឯកសារខ្លីនេះនឹងមិនអាចធ្វើទៅបានឡើយ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់សមាជិកក្រុមការងារទទួលបន្ទុកផ្នែកករណីសិក្សារបស់ក្រសួងពាណិជ្ជកម្ម ដែលដឹកនាំដោយឯកឧត្តម រដ្ឋលេខាធិការ ប៉ាន សូរស័ក្តិ ឯកឧត្តម សុខ សុភ័ក្ត្រ ឯកឧត្តម ពេជ ឫទ្ធី លោក តាន់ យុវរដ្ឋ លោក ស៊ឹម សុខខេង លោក សួន ប្រសិទ្ធ និងជំនួយការបច្ចេកទេសរបស់បណ្ឌិត Thierry Noyelle ចំពោះការងាររបស់ពួកគាត់ ក្នុងការរៀបចំករណីសិក្សា និងឯកសារនេះ។

**H.E. CHAM Prasidh**

Senior Minister, Minister of Commerce
Kingdom of Cambodia

# មាតិកា


បុព្វកថាថ្លែងដោយ **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ....................5
**ពាក្យបំព្រួញកាត់** ....................8
**អាទិភាពសម្រាប់អភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា**....................10
ការបញ្ជ្រាបពាណិជ្ជកម្ម និងជំនួយសម្រាប់ពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ ១៩៩០ ....................10
អាទិភាពអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាក្រោមអភិក្រមគ្របដណ្ដប់
លើវិស័យពាណិជ្ជកម្ម (Trade SWAp) ....................12
ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃអភិក្រមគ្របដណ្ដប់លើវិស័យពាណិជ្ជកម្មកម្ពុជា ....................13

**ករណីសិក្សា: ការអនុវត្ត កម្មវិធីការងារធ្វើកំណែទម្រង់ច្បាប់ និងការប្ដេជ្ញាចិត្តដែលកើតចេញពីការចូលជាសមាជិករបស់**
**អង្គការពាណិជ្ជកម្មពិភពលោក** (WTO) **របស់ប្រទេសកម្ពុជា**....................16
១. បញ្ហាដែលត្រូវបានដោះស្រាយ....................16
២. វត្ថុបំណងដែលសម្រេចបាន ....................17
៣. បញ្ហាប្រឈម និងកត្តាឈានទៅរកជោគជ័យ ....................17
៤.លទ្ធផលដែលសម្រេចបាន- ប្រសិទ្ធភាពដែលអាចវាស់វែងបាន ....................20
៥. បទពិសោធន៍ដែលទទួលបាន ....................21
**តារាងទី ១** ៖ កម្មវិធីការងារកំណែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជាដោយសារតែការចូលជាសមាជិក
របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) (នៅខែតុលា ឆ្នាំ២០០៤)
ស្ថានភាពនៃការអនុវត្តមកដល់ខែកុម្ភៈ ឆ្នាំ២០១១....................22
**ក្រាហ្វិក ១**: ការចុះបញ្ជីម៉ាកតាមឆ្នាំ (២០០០-២០០៩) ....................26
**រូបភាព ២**: ការបង្ហាញទីតាំងភូមិសាស្ត្រ ស្ករត្នោត ខេត្តកំពង់ស្ពឺ....................26
**រូបភាព ៣** : ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញម្រេចកំពត ....................26

**ករណីសិក្សា: ការកែទម្រង់ការសម្របសម្រួលពាណិជ្ជកម្មនៅកម្ពុជា** ....................27
១. បញ្ហាដែលត្រូវបានដោះស្រាយ....................28
២. គោលដៅដែលត្រូវបន្ត....................29
៣. បញ្ហាប្រឈមដែលបានជួបប្រទះ និងកត្តានានាសម្រាប់ភាពជោគជ័យ ....................29
៤. លទ្ធផលដែលសម្រេចបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន....................31
៥. បទពិសោធន៍ដែលទទួលបាន ....................32
**តារាងលេខ ១** ៖ ស្ថានភាពក្នុងឆ្នាំ ២០១១ នៃផែនការសកម្មភាពទាំង ១២ចំណុច ដែលបានអនុម័តដោយ
ក្រុមការងារអន្តរក្រសួងពិសេសស្ដីពីការសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ
(SITF) នៅក្នុងខែមិថុនា ឆ្នាំ២០០៤ ....................32
**តារាងលេខ ២** ៖ ច្បាប់ អនុក្រឹត្យរបស់រដ្ឋាភិបាល និងប្រកាសអន្តរក្រសួង ....................35
**តារាលេខ ៣** ៖ ការគ្រប់គ្រងហានិភ័យ....................36

**ករណីសិក្សា: ការពង្រីក និងធ្វើពិពិធកម្មការនាំអង្ករចេញរបស់កម្ពុជា** ....................37
១. បញ្ហាដែលត្រូវបានដោះស្រាយ....................38
២. គោលដៅដែលត្រូវបន្ត ....................39
៣. បញ្ហាប្រឈមដែលបានជួបប្រទះ និងកត្តានាំទៅរកភាពជោគជ័យ....................39
៤. លទ្ធផលដែលទទួលបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន ....................42
៥. បទពិសោធន៍ដែលទទួលបាន ....................42

**តារាងលេខ ១ ៖** តារាងតម្លៃអង្ករបស់កម្ពុជា (២០០៨-២០០៩) ....43
**តារាងលេខ ២ ៖** ទីផ្សារទាក់ទាញបំផុតទាំង ២៥ សម្រាប់អង្ករបស់កម្ពុជា ឆ្នាំ ២០០៨ (HS 100630) ....44
**តារាងទី ៣ ៖** ទីផ្សារទាក់ទាញបំផុតទាំង ២០ សម្រាប់អង្ករបាក់របស់កម្ពុជាឆ្នាំ ២០០៨ (HS 100640) ....45
**តារាងទី ៤ ៖** គោលនយោបាយស្រូវខែកក្កដា ឆ្នាំ ២០១០ របស់រដ្ឋាភិបាល ....46

**ករណីសិក្សា: ការពង្រីក និងធ្វើពិពិធកម្ម ការនាំចេញផលិតផលសូត្រកម្ពុជា** ....49
១. បញ្ហាដែលបានដោះស្រាយ ....50
២. គោលដៅដែលត្រូវបន្ត ....51
៣. បញ្ហាប្រឈមដែលជួបប្រទះ និងកត្តាឈានទៅរកជោគជ័យ ....51
៤. លទ្ធផលសម្រេចបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន ....53
៤. បទពិសោធន៍ដែលទទួលបាន ....53
**តារាង ១ ៖** ចំនួន និងទីតាំងរបស់អ្នកតម្បាញសូត្រនៅប្រទេសកម្ពុជា ឆ្នាំ ២០១០ ....54

**ករណីសិក្សា: ការកសាងសមត្ថភាពសម្រាប់ខ្សែចង្វាក់តម្លៃនៃការនាំចេញ និងព័ត៌មានអំពីពាណិជ្ជកម្មនៅប្រទេសកម្ពុជា** ....55
១. បញ្ហាដែលត្រូវបានដោះស្រាយ ....56
២. គោលដៅដែលត្រូវបន្ត ....56
៣. បញ្ហាប្រឈម និងកត្តាឈានទៅរកជោគជ័យ ....57
៤. លទ្ធផលដែលសម្រេចបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន ....59
៥. បទពិសោធន៍ដែលទទួលបាន ....59

**ប្រកាសស្ដីពីការបង្កើតក្រុមការងារសម្រាប់រៀបចំឯកសារស្ដីពីការអនុវត្តជំនួយពាណិជ្ជកម្មនៅកម្ពុជា** ....60

នៅក្នុងឯកសារខ្លីនេះ បានរួមបញ្ចូលគ្នានូវមេរៀនជាច្រើនដែលបានមកពីករណីសិក្សាអំពីជំនួយសម្រាប់ពាណិជ្ជកម្មទាំង៥ដែលត្រូវបានរៀបចំឡើងដោយប្រទេសកម្ពុជាសម្រាប់ការត្រួតពិនិត្យឡើងវិញជាសកលលើកទី ៣ នៅខែកក្កដា ឆ្នាំ២០១១ នូវជំនួយសម្រាប់ពាណិជ្ជកម្មដែលរៀបចំឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍ សេដ្ឋកិច្ច (OECD) ។ ការរៀបចំឯកសារនេះបានទទួលការឧបត្ថម្ភថវិកាពីកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) Tier 1 របស់ប្រទេសកម្ពុជា។

# ពាក្យបំព្រួញកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AFD | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ |
| AfT | ជំនួយសម្រាប់ពាណិជ្ជកម្ម |
| AusAid | ទីភ្នាក់ងារផ្តល់ជំនួយអូស្ត្រាលីសម្រាប់ការអភិវឌ្ឍ |
| Danida | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណាម៉ាក |
| Camcontrol | អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញអាហារ័ណនីហ័រណនិងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CTIS 2007 | យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០០៧ |
| DICO | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| DTIS | ការវិភាគយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម |
| EC | គណៈកម្មការអឺរ៉ុប |
| ECAP (II or III) | កម្មវិធីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញារបស់ EC-ASEAN |
| EIF | កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម |
| EU | សហភាពអឺរ៉ុប |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម |
| GDCE | អគ្គនាយកដ្ឋានគយ និងរដ្ឋាករ |
| GI | ការកំណត់ភូមិសាស្ត្រទំនិញ |
| G-PSF | វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន |
| GTZ | កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសអាឡឺម៉ង់ |
| ICAO | អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ |
| IF | ក្របខ័ណ្ឌសមាហរណកម្ម |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| ITC | មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ UNCTAD/WTO |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| LDC | ប្រទេសអភិវឌ្ឍន៍តិចតួច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| | |
|---|---|
| **MoC** | ក្រសួងពាណិជ្ជកម្ម |
| **MoH** | ក្រសួងសុខាភិបាល |
| **MoI** | ក្រសួងមហាផ្ទៃ |
| **MoJ** | ក្រសួងយុត្តិធម៌ |
| **MoT** | ក្រសួងទេសចរណ៍ |
| **MPDF** | មូលនិធិអភិវឌ្ឍវិស័យឯកជនតំបន់ទន្លេមេគង្គ |
| **MPT** | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| **MPWT** | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MULTRAP** | កម្មវិធីជំនួយគោលនយោបាយពាណិជ្ជកម្មពហុភាគី (EC) |
| **NBC** | ធនាគារជាតិនៃកម្ពុជា |
| **NCIPR** | គណៈកម្មាធិការជាតិទទួលបន្ទុកកម្មសិទ្ធិបញ្ញា |
| **NZAid** | កម្មវិធីជំនួយប្រទេសញ៉ូវហ្សឺឡែន |
| **OECD** | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SAD** | ឯកសាររដ្ឋបាលតែមួយ |
| **SECO** | កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចប្រទេសស្វីស |
| **SITF** | ក្រុមការងារពិសេសអន្តរក្រសួងទទួលបន្ទុកសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ |
| **SSCA** | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| **SWAp** | អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម |
| **TA** | ជំនួយបច្ចេកទេស |
| **TDSP** | កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម |
| **TFCP** | កម្មវិធីកិច្ចសម្រួលពាណិជ្ជកម្ម និងការប្រកួតប្រជែង |
| **TPD** | នាយកដ្ឋានជំរុញពាណិជ្ជកម្ម |
| **UNCTAD** | សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNDP TRADE** | គម្រោងជំនួយពាណិជ្ជកម្មដើម្បីការអភិវឌ្ឍ និងសមធម៌របស់ UNDP |
| **UNESCAP** | គណៈកម្មការសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិសម្រាប់ទ្វីបអាស៊ី និងប៉ាស៊ីភិច |
| **UNIDO** | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |
| **USAID** | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ |
| **VCU** | អង្គភាពខ្សែចង្វាក់តម្លៃ |
| **WB** | ធនាគារពិភពលោក |
| **WCO** | អង្គការពន្ធគយពិភពលោក |
| **WIPO** | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| **WTO** | អង្គការពាណិជ្ជកម្មពិភពលោក |

# អាទិភាពសម្រាប់អភិវឌ្ឍន៍ វិស័យពាណិជ្ជកម្មនៅកម្ពុជា

## ការបញ្ជ្រាបពាណិជ្ជកម្ម និងជំនួយសម្រាប់ពាណិជ្ជកម្ម នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីពាក់កណ្ដាល ទសវត្សរ៍ឆ្នាំ ១៩៩០

### អំឡុងពេលមុនក្រោយជម្លោះ

ការអភិវឌ្ឍទាំង ៣ បានស្ថិតនៅជាចំណុចស្នូលនៃកិច្ចខិតខំប្រឹងប្រែងដំបូងបង្អស់របស់ប្រទេសកម្ពុជា ដើម្បីបង្វែរការអភិវឌ្ឍវិស័យពាណិជ្ជកម្មឲ្យក្លាយទៅជាកម្លាំងចលករដ៏សំខាន់មួយ ក្នុងការកាត់បន្ថយភាពក្រីក្រ និងការលូតលាស់សេដ្ឋកិច្ចនៅក្នុងអំឡុងពេលក្រោយជម្លោះ។

លើកទី១ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៤ ប្រទេសកម្ពុជាបានដាក់ពាក្យសុំចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO)។ ក្រុមការងារមួយត្រូវបានបង្កើតឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ១៩៩៤។ អនុស្សរណៈរបស់ប្រទេសកម្ពុជា ស្ដីពីរបបពាណិជ្ជកម្មបរទេសត្រូវបានដាក់នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ១៩៩៩។ ការចរចាជាច្រើនលើកទៅលើលក្ខន្តិកៈ នៃការក្លាយជាសមាជិករបស់ព្រះរាជាណាចក្រនេះ ត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័សនៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំដំបូងនៃសហសវត្សរ៍ថ្មីនេះ។ ពិធីសារនៃការចូលជាសមាជិករបស់ប្រទេសកម្ពុជាត្រូវបានយល់ព្រម និងចុះហត្ថលេខានៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្ថិតក្រោមការធ្វើសច្ចាប័នដោយរដ្ឋសភា និងព្រឹទ្ធសភា។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកទី១៤៨របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃ ទី១៣ ខែតុលា ឆ្នាំ២០០៤។

លើកទី ២ ចាប់ផ្ដើមនៅអំឡុងឆ្នាំ១៩៩៧ ប្រទេសកម្ពុជាបានអភិវឌ្ឍប្រកបដោយជោគជ័យនូវវិស័យកាត់ដេរដ៏សំខាន់ ដែលក្នុងនោះវិស័យនេះ ត្រូវបានផ្ដល់ដល់ប្រទេសដែលទទួលបានឋានៈអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម(MFN)ដោយសហរដ្ឋអាមេរិកនិងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ជាក្របខ័ណ្ឌជាមួយនឹងសហភាពអឺរ៉ុប ដើម្បីទទួលបានទីផ្សារក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់ខ្លួន។ កិច្ចព្រមព្រៀងទ្វេភាគីរយៈពេល ៣ឆ្នាំដែលបានចុះហត្ថលេខាជាមួយនឹងសហរដ្ឋអាមេរិកនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩ បានបង្កើតឡើងនូវការកំណត់កូតា ក្នុងកិច្ចព្រមព្រៀងពហុវាយនភណ្ឌ (MFA)នៅក្នុងទីផ្សារដែលស្របទៅតាមបទដ្ឋានពលកម្ម។ ទោះជាយ៉ាងណាក៏ដោយអត្រាលូតលាស់ប្រចាំឆ្នាំនេះបានបង្កើតបន្ថែមនូវកូតា (៦% ក្នុងមួយឆ្នាំ) ស្របតាមចំណុច នៃអត្រាលូតលាស់បន្ថែមដែលអាចទទួលបានពីការបំពេញនូវបទដ្ឋានពលកម្មដែលបញ្ជាក់ដោយអង្គការពលកម្មអន្តរជាតិ (ILO) ដែលធ្វើឲ្យការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកមានការលូតលាស់យ៉ាងឆាប់រហ័ស។

លើកទី ៣ ជាមួយនឹងសន្តិភាពបានវិលត្រឡប់មកកាន់ប្រទេសជាតិវិញ ប្រទេសកម្ពុជាបានស្ដារឡើងវិញនូវវិស័យទេសចរណ៍ដែលផ្ដោតជាដំបូងទៅលើតំបន់អង្គរវត្តនៅភាគខាងលិចនៃប្រទេស។ ចន្លោះរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០៤ អ្នកទេសចរបានចូលមកច្រើនជាងបួនដងពីចំនួនមិនដល់ ៣០០,០០០ នាក់ផងក្នុងមួយឆ្នាំទៅរហូតដល់លើស ១,៤ លាននាក់។

### សហសវត្សរ៍ថ្មី

ខណៈពេលដែលការចរចាអំពីការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលបានដំណើរការក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២០០០ ការដាក់ចេញនូវមូលដ្ឋានគោលនយោបាយនិងច្បាប់សំខាន់ថ្មីៗសម្រាប់ការ បញ្ជ្រាបការអភិវឌ្ឍវិស័យពាណិជ្ជកម្មនៅក្នុងការកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជារាជរដ្ឋាភិបាលកម្ពុជា (RGC) ក៏មានភាពសកម្មផងដែរនៅក្នុងការកំណត់កំណែទម្រង់គោលនយោបាយ និងច្បាប់ផ្សេងៗ តម្រូវការក្នុងការអភិវឌ្ឍស្ថាប័ន ព្រមទាំងតម្រូវការអភិវឌ្ឍន៍សមត្ថភាពផ្នែកផ្គត់ផ្គង់ដែលនឹងត្រូវការឲ្យមានការយកចិត្តទុកដាក់ផងដែរ។

នៅខែកក្កដា ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវ "យុទ្ធសាស្ត្រវិស័យពាណិជ្ជកម្មសម្រាប់កាត់បន្ថយភាពក្រីក្រ " នៅក្នុងអំឡុងកិច្ចប្រជុំតុមូលរបស់អ្នកផ្ដល់ជំនួយនៅក្នុងទីក្រុងតូក្យូ។ កិច្ចប្រជុំនៅទីក្រុងតូក្យូនេះ បានឯកភាពលើការរៀបចំកម្មវិធីពង្រឹងសមត្ថភាពសមាហរណកម្មពាណិជ្ជកម្ម (DTIS) ស្ថិតក្រោមកម្មវិធីក្របខ័ណ្ឌសមាហរណកម្ម (IF) សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (LDC)។ ការសិក្សានេះត្រូវបានបង្កើតឡើងនៅអំឡុងឆមាសទីពីរនៃឆ្នាំ២០០១ និងមានសុពលភាពដល់អំឡុងពេលបើកសិក្ខាសាលានៅខែ វិច្ឆិកា ឆ្នាំ ២០០១ នៅក្នុងទីក្រុងភ្នំពេញ។ ប្រទេសកម្ពុជា ជាប្រទេសអភិវឌ្ឍន៍តិចតួច(LDC) ទីមួយដែលបញ្ចប់ការវិភាគយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (DTIS) ស្ថិតក្រោមកម្មវិធីក្របខ័ណ្ឌសមាហរណកម្ម។

ថ្វីបើមានអនុសាសន៍ដ៏ទូលំទូលាយ ដែលបានមកពីការវិភាគយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (DTIS) ដំបូងក៏ដោយក៏ការយកចិត្តទុកដាក់លើជំនួយបច្ចេកទេសក្នុងអំឡុងឆមាសទីមួយនៃឆ្នាំ២០០០ នៅមានកម្រិតនៅឡើយ ដោយក្នុងនោះបានបង្ហាញឲ្យឃើញតិចតួចពីចំណុចអាទិភាពរបស់រដ្ឋាភិបាល សមត្ថភាពស្រូបយករបស់ស្ថាប័នទាំងឡាយក្នុងប្រទេសកម្ពុជា និងការប្ដេជ្ញាចិត្តមិនច្បាស់លាស់របស់ដៃគូអភិវឌ្ឍន៍ចាស់ៗឆ្ពោះទៅរកការអភិវឌ្ឍវិស័យពាណិជ្ជកម្ម។ ការយកចិត្តទុកដាក់ច្រើនទៅលើជំនួយអភិវឌ្ឍន៍ពីបរទេស (ODA) នៅក្នុងវិស័យពាណិជ្ជកម្មក្នុងអំឡុងប៉ុន្មានឆ្នាំនោះគឺ ទៅលើការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងកំណែទម្រង់ច្បាប់ដែលពាក់ព័ន្ធ (UNCTAD,EC-MULTRAP,

AFD,ADB,IMF,ដទៃទៀត) ស្តីពីការពង្រឹងកិច្ចពិភាក្សារវាងរដ្ឋាភិបាល និងវិស័យឯកជន (វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន [G-PSF] ផ្តល់ជំនួយដោយមូលនិធិអភិវឌ្ឍវិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលគ្រប់គ្រងដោយ សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ព្រមទាំងជួយរដ្ឋាភិបាលនិងវិស័យឯកជនក្នុងការអនុវត្តបទដ្ឋានពលកម្ម ដែលដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងវាយនភណ្ឌទ្វេភាគី រវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក (តាមរយៈកម្មវិធីរោងចក្រ កាន់តែប្រសើរ ដែលអនុវត្តដោយអង្គការពលកម្មអន្តរជាតិ (ILO) ក្រោមការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងអ្នកពាក់ព័ន្ធដទៃទៀត)។ អ្នកផ្តល់ជំនួយទ្វេភាគីមួយចំនួនពិតជាមានភាពសកម្មនៅក្នុងវិស័យផលិតផលនីមួយៗ ដោយរាប់បញ្ចូលទាំងវិស័យនានាដែលមានសមត្ថភាពនាំចេញនៅពេលបច្ចុប្បន្ន ឬ មានសក្តានុពលនាំចេញ (អង្គការជំនួយអូស្ត្រាលីសម្រាប់ការអភិវឌ្ឍ (AusAid) ក្នុងវិស័យអង្ករ, ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ក្នុងវិស័យជ័រកៅស៊ូ, ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណាម៉ាក (Danida) ក្នុងវិស័យជលផលជាដើម) ហើយជាមួយនឹងការចាប់ផ្តើមកម្មវិធីកិច្ចសម្រួលពាណិជ្ជកម្មដែលផ្តល់មូលនិធិ ដោយធនាគារពិភពលោកនិងការប្រកួតប្រជែងនៅក្នុងឆ្នាំ២០០៤ ការផ្តោតការយកចិត្តទុកដាក់លើការងារគយ និងកំណែទម្រង់ដែលពាក់ព័ន្ធបានស្តែងចេញជារូបរាងក្នុងអំឡុងឆ្នាំ ២០០៤។

## កម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មកម្ពុជា

ការចាប់ផ្តើមអនុវត្តនូវគំនិតផ្តួចផ្តើមកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្មក្នុងអំឡុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីរបស់ អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅទីក្រុងហុងកុង ឆ្នាំ២០០៥ ដែលជាកម្លាំងរុញច្រានដែលបង្កើតឡើងដោយសេចក្តីប្រកាសទីក្រុងប៉ារីសឆ្នាំ២០០៥ស្តីពីប្រសិទ្ធភាពជំនួយ នៃការពង្រឹងការផ្តួចផ្តើមគំនិត លើក្របខ័ណ្ឌសមាហរណកម្ម (IF) ដែលនាំឲ្យមានការចាប់ផ្តើមអនុវត្តនូវកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម(EIF) នៅក្នុងឆ្នាំ២០០៧ ដោយមានមូលនិធិសង្គមអ្នកផ្តល់ជំនួយពហុភាគីថ្មីៗ ព្រមទាំងមានការយកចិត្តទុកដាក់សារ ជាថ្មី របស់ដៃគូអភិវឌ្ឍន៍សម្រាប់ការអភិវឌ្ឍពាណិជ្ជកម្មរួមគ្នាដើម្បីផ្តល់នូវកាលានុវត្តភាពថ្មីៗ សម្រាប់ប្រទេសកម្ពុជា ក្នុងការកៀងគរជំនួយសម្រាប់ពាណិជ្ជកម្ម សម្រាប់បញ្ហាបពាណិជ្ជកម្មនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០។

ការអភិវឌ្ឍមួយចំនួនបានលេចឡើង។ ការវិភាគយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (DTIS) ដែលបានធ្វើបច្ចុប្បន្នភាព គឺយុទ្ធសាស្ត្រធ្វើសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ (CTIS 2007) ត្រូវបានរៀបចំតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ក្រសួងពាណិជ្ជកម្ម (MoC) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងក្រុមដៃគូអភិវឌ្ឍន៍ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៦។ យុទ្ធសាស្ត្រ*ធ្វើសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ (CTIS 2007)* ត្រូវបានឯកភាពដោយ "អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគពាក់ព័ន្ធពាណិជ្ជកម្ម" របស់រដ្ឋាភិបាលក្នុងខែមីនា ឆ្នាំ ២០០៧ (បានចាប់ផ្តើមអនុវត្តជាផ្លូវការដោយសម្តេចនាយករដ្ឋមន្ត្រីនៅក្នុងខែធ្នូ ឆ្នាំ២០០៧)។

កម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម(Trade SWAp) ត្រូវបានចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០០៨ ដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានការប្រឹក្សាជាមួយដៃគូអភិវឌ្ឍន៍ដើម្បីអនុវត្តនូវវត្ថុបំណងនៃ*យុទ្ធសាស្ត្រធ្វើសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ (CTIS 2007)* និងជួយពង្រឹងភាពជាម្ចាស់ និងការគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) ដែលជាកម្មវិធីម្ចាស់ជំនួយពហុភាគី ឧបត្ថម្ភហិរញ្ញវត្ថុ ដោយសហភាពអឺរ៉ុប(EU), ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណាម៉ាក (Danida) និង អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (UNIDO) ស្ថិតក្រោមការចាត់ចែងមូលនិធិសង្គមដោយធនាគារពិភពលោក ត្រូវបានរៀបចំឡើងដើម្បីផ្តល់ឲ្យរដ្ឋាភិបាលនូវធនធាននានា ដើម្បីគាំទ្រដល់ អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (TradeSWAp)។ កម្មវិធីដែលផ្តល់មូលនិធិដោយអ្នកផ្តល់ជំនួយដទៃទៀត មានដូចជា UNDP TRADE, USAID, ADB, IFC, EIF Tier 1 និងអ្នកផ្តល់ជំនួយផ្សេងទៀតត្រូវបានផ្សារភ្ជាប់ជាមួយនឹងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ដើម្បីធានាថា ពួកគេនឹងផ្តល់ការគាំទ្រពេញលេញដល់គោលបំណងរួមទាំងនេះ។



# អាទិភាពនានានៃការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាក្រោមអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម

*យុទ្ធសាស្ត្រធ្វើសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០០៧* (*CTIS 2007*) បានកំណត់ផ្នែកអាទិភាពមួយចំនួនសម្រាប់ធ្វើកំណែទម្រង់ និងអភិវឌ្ឍន៍ ដែលបានក្លាយជាមូលដ្ឋានសម្រាប់ "សសរស្តម្ភ" ទាំងបីនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ៖

- សសរស្តម្ភទី ១ ដែលផ្តោតលើ "ការអនុវត្តលើការកំណែទម្រង់ច្បាប់គ្រប់អន្តរវិស័យ និងស្ថាប័នដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្ម" ដោយមានផ្នែកអាទិភាពមួយចំនួនដូចជា (១) ការបញ្ចប់ការអនុវត្តកំណែទម្រង់ច្បាប់ និងការសន្យានានាដែលពាក់ព័ន្ធនឹងការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO) (២) ការកាត់បន្ថយចំណាយនានានៃកិច្ចសម្រួលពាណិជ្ជកម្ម (៣)ការកែលម្អបរិយាកាសវិនិយោគ (៤)ជំរុញការប្រើប្រាស់ការគាំពារកម្មសិទ្ធិបញ្ញា (៥) ការអភិវឌ្ឍបរិយាកាសច្បាប់ និងស្ថាប័នសម្រាប់អនាម័យ និងភូតគាមអនាម័យ (SPS) ព្រមទាំងបទដ្ឋាននានាក្នុងចំណោមវិស័យផ្សេងៗទៀត។
- សសរស្តម្ភទី ២ ដែលផ្តោតលើ "ការអភិវឌ្ឍការផ្គត់ផ្គង់ការនាំចេញប្រកបដោយការប្រកួតប្រជែង" ជាមួយនឹងការសង្កត់ធ្ងន់ទៅលើការធ្វើពិពិធកម្ម នូវទីផ្សារនាំចេញរបស់ប្រទេសកម្ពុជា តាមរយៈផលិតផល និងសេវាកម្មថ្មីៗ និងទីផ្សារថ្មីៗជាមួយវិស័យអាទិភាពនានា ដូចជា (១) ការអភិវឌ្ឍខ្សែចង្វាក់តម្លៃនាំចេញ និងព័ត៌មានអំពីពាណិជ្ជកម្ម (២) ការពង្រឹងស្ថាប័នគាំទ្រពាណិជ្ជកម្មនៅកម្រិតសមាគមផលិតផល និងនៅតាមបណ្តាខេត្តនានា និង (៣) ការពង្រឹងសមត្ថភាពផ្គត់ផ្គង់ការនាំចេញនៅក្នុងវិស័យដែលមានសក្តានុពលជាអាទិភាពចំនួន ១៩ ដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០០៧* (*CTIS 2007*) ។
- សសរស្តម្ភទី ៣ ដែលផ្តោតលើ "ការកសាងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីដឹកនាំ ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្ម" ដែលមានដូចជា (១) ការកសាងសមត្ថភាពនៅក្នុងនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិរបស់ក្រសួងពាណិជ្ជកម្ម (MoC) ដែលបង្កើតថ្មី ដើម្បីដើរតួជាលេខាធិការដ្ឋានទទួលបន្ទុកអភិក្រមគ្របដណ្តប់លើវិស័យកសិកម្ម(Trade SWAp)កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) និងកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) Tier 1 និងទទួលកិច្ចការដឹកនាំកម្មវិធីជំនួយសម្រាប់ ពាណិជ្ជកម្ម (AfT)ពីមួយថ្ងៃទៅមួយថ្ងៃ (២) ការកសាងសមត្ថភាពនៅតាមខ្សែបណ្តោយក្រសួង ដែលពាក់ព័ន្ធនឹងភាពជោគជ័យនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) (៣) ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវគោល នយោបាយពាណិជ្ជកម្ម (៤) ការពង្រឹងសមត្ថភាពចរចាលើកិច្ចការពាណិជ្ជកម្ម ជាដើម។




វត្ថុបំណង ចំណុចគោល និងគោលដៅអាទិភាពនៃសសរស្តម្ភទាំង ៣ ឥឡូវនេះត្រូវបានបញ្ចូលនៅក្នុងផែនទីបង្ហាញផ្លូវទាំង ៣ ដែលកំពុងផ្តល់ការណែនាំទៅដល់មូលនិធិម្ចាស់ជំនួយពហុភាគី (TDSP) នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) Tier 1, និងកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) ដទៃទៀតដែលកំពុងដំណើរការ (ADB, IFC,AusAid, USAid, AFD, JICA, ជាដើម)[១] ។

ករណីសិក្សាទាំងឡាយដែលមាននៅក្នុងឯកសារខ្លីនេះ ផ្តោតជាសំខាន់ទៅលើវិស័យអាទិភាពទាំង៥ នៅក្នុងសសរស្តម្ភទាំង៣ និងស្វែងរកមេរៀនល្អៗសម្រាប់ប្រទេសកម្ពុជា និងសម្រាប់ប្រទេសដទៃទៀតពីការរីកចម្រើននានា ដែលបានធ្វើឡើងនៅក្នុងប្រទេសទាំងនោះចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ មក ដែលមានដូចជា ៖

- ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងការសន្យានានាដែលជាលទ្ធផលនៃការចូលជាសមាជិករបស់ អង្គការពាណិជ្ជកម្មពិភពលោក (WTO) (សសរស្តម្ភទី ១)
- កំណែទម្រង់ និងការធ្វើទំនើបកម្មកិច្ចសម្រួលពាណិជ្ជកម្ម (សសរស្តម្ភទី ១)
- ការពង្រីក និងការធ្វើឲ្យមានភាពសម្បូរបែបនូវការនាំចេញអង្ករ (សសរស្តម្ភទី ២)
- ការពង្រីក និងការធ្វើឲ្យមានភាពសម្បូរបែបនូវការនាំចេញផលិតផលសូត្រ (សសរស្តម្ភ ទី ២)
- ការអភិវឌ្ឍសមត្ថភាពខ្សែចង្វាក់តម្លៃនៃការនាំចេញ និងព័ត៌មានអំពីពាណិជ្ជកម្ម (គ្របដណ្តប់លើសសរស្តម្ភទី ២ និងទី ៣)។

[១] សសរស្តម្ភទី ១ នៃផែនទីបង្ហាញផ្លូវ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ សសរស្តម្ភទី ២ នៃផែនទីបង្ហាញផ្លូវ (ព្រាង) ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១១ សសរស្តម្ភទី ៣ នៃផែនទីបង្ហាញផ្លូវ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១០

# ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មកម្ពុជា

## គោលដៅនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ( TSG )

| TSG ១: | TSG ២: | TSG ៣: | TSG ៤: | TSG ៥: |
|---|---|---|---|---|
| ការបង្កើតការងារ និង កាត់បន្ថយភាពក្រីក្ររងឥទ្ធិពលវិជ្ជមានពីការពង្រីកពាណិជ្ជកម្ម | ការនាំចេញកើនឡើងដោយសារតែការធ្វើពិពិធកម្ម | រាជរដ្ឋាភិបាលកម្ពុជាបង្កើនសមត្ថភាពក្នុងការបង្កើត និង អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ពាណិជ្ជកម្ម | ភាពឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាទៅនឹងតម្រូវការរបស់វិស័យឯកជន មានការកើនឡើងដោយសារតែមានកិច្ចពិភាក្សាកាន់តែប្រសើរឡើង | រាជរដ្ឋាភិបាលកម្ពុជាបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការកសាងផែនការ អនុវត្ត និង ត្រួតពិនិត្យតាមរយៈការអនុវត្ត Trade SWAp |

## លទ្ធផលនៃសសរស្តម្ភ( PO )

**សសរស្តម្ភ I :កំណែទម្រង់និងបញ្ហាអន្តរវិស័យសម្រាប់អភិវឌ្ឍពាណិជ្ជកម្ម**

ពង្រឹងភាពប្រកួតប្រជែងនៃការនាំចេញនាពេលបច្ចុប្បន្ន, ជំរុញការធ្វើឲ្យមានភាពសម្បូរបែបនៃការនាំចេញដោយធ្វើឲ្យប្រសើរឡើងនូវការបង្កើត និង ការអនុវត្តគោលយោបាយពាណិជ្ជកម្ម និងច្បាប់នានា

**សសរស្តម្ភទី១ លទ្ធផលទី ១ (P១០ ១)** :សុវត្ថិភាព និងគុណភាពផលិតផលកើនឡើយធ្វើឲ្យមានឥទ្ធិវិជ្ជមានទៅលើការនាំចេញ និងសុខភាពសាធារណៈ

**P១០ ២** : លំហូរពាណិជ្ជកម្មកើន ឡើងដោយសារនីតិវិធី និងដំណើរការនាំចូល នាំចេញ និងផ្ទេរទំនិញកាន់តែមានភាពសាមញ្ញ និងកាន់តែមានតម្លាភាព

**P១០ ៣** : ការនាំចេញផលិតផល ដែលត្រូវបានការពារក្រោមរបប កម្មសិទ្ធិបញ្ញារបស់កម្ពុជាមានការកើនឡើង

**P១០ ៤** : ប្រព័ន្ធច្បាប់ពាក់ព័ន្ធនឹង ពាណិជ្ជកម្មត្រូវបានធ្វើឲ្យប្រសើរឡើង និងបញ្ជប់ស្របទៅតាមបទដ្ឋានអន្តរជាតិ និងកាតព្វកិច្ចអន្តរជាតិ

**P១០ ៥** : ការវិនិយោគពាក់ព័ន្ធនឹង ពាណិជ្ជកម្មមានការកើនឡើង

**P១០ ៦** : ការគោរពបទដ្ឋានការងារស្នូលបានបង្កើនភាពប្រកួតប្រជែងនិងផលិតភាពនៃការនាំចេញ

**P១០ ៦** : SMEs ជាពិសេសនៅក្នុងវិស័យកសិកម្មទទួលបានការប្រើប្រាស់ឥណទានកាន់តែងាយស្រួលតាមផ្លូវការសម្រាប់ពង្រីកសកម្មភាពរបស់ខ្លួន និងបង្កើនការនាំចេញ

**សសរស្តម្ភ II : ការអភិវឌ្ឍការនាំចេញផលិតផល និងសេវាកម្ម**

ពង្រឹងសមត្ថភាពផ្គត់ផ្គង់ផលិតផល និងសេវាកម្មទាំង១៩ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧

**P២០ ១** : រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តល់ឲ្យវិធីសាស្ត្រ និងព័ត៌មានដើម្បីដឹកនាំការអភិវឌ្ឍ និងការបង្កើតគោលនយោបាយតម្រង់ទិសការនាំចេញ ការត្រួត ពិនិត្យដំណើរការ និងកំណត់អត្តសញ្ញាណសម្រាប់ TRTA និង AfT។

*ក្រុមការងារបច្ចុប្បន ៖ អង្គភាពព័ត៌មានអំពីខ្សែសង្វាក់តម្លៃ*

**P២០ ២** : ការផ្តល់សេវាកម្មគាំទ្រពាណិជ្ជកម្មនៅថ្នាក់មូលដ្ឋានត្រូវបានធ្វើឲ្យប្រសើរឡើងតាមរយៈសមាគមពាណិជ្ជ ដែលមានភាពរឹងមាំ សភាពាណិជ្ជកម្មក្នុងស្រុក, PDoCs, សេវាកម្មផ្សព្វផ្សាយរបស់រដ្ឋាភិបាល, កិច្ចពិភាក្សារដ្ឋ-ផ្នែកឯកជន, G-PSF ជាដើម។

*ក្រុមការងារបច្ចុប្បន្ន ៖ ស្ថាប័នទ្រទ្រង់ពាណិជ្ជកម្ម និង PPPD*

**P២០ ៣** :ការនាំចេញត្រូវបានធ្វើពិពិធកម្ម និងពង្រីកដោយជោគជ័យនៅក្នុងវិស័យជាច្រើនក្នុងចំណោមវិស័យទាំង ១៩ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រុមការងារដែលផ្តោតទៅលើផលិតផលនិងសេវាកម្មលក្ខណៈបុគ្គល (បច្ចុប្បន្ន មានក្រុមការងារចំនួន ៨ ក្រុម)

**សសរស្តម្ភ III : ការអភិវឌ្ឍសមត្ថភាព**

ពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាដើម្បីអនុវត្តកែលម្អនិងគ្រប់គ្រងរបៀបវារៈនៃការអភិវឌ្ឍពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីចរចាពីផលប្រយោជន៍របស់ប្រទេសនៅក្នុងវេទិកាស្តីពីពាណិជ្ជកម្ម និងការវិនិយោគ ពាក់ព័ន្ធនឹងពាណិជ្ជកម្ម

**P៣០ ១** : សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការធ្វើសមាហរណកម្ម សម្របសម្រួល និងអនុវត្តកំណែទម្រង់ពាក់ព័ន្ធវិស័យពាណិជ្ជកម្ម

**P៣០ ២** : អភិក្រមដែលមានប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយពាណិជ្ជកម្មត្រូវបានដាក់ឲ្យអនុវត្ត

**P៣០ ៣** : ប្រព័ន្ធស្ថាប័ន និងជំនាញស្នូល គឺមានសម្រាប់ធានាឲ្យមានដំណើរការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពពីសំណាក់ស្ថាប័ននានាដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម

**P៣០ ៤** : ការយល់ដឹងទូលំទូលាយអំពីកាលានុវត្តភាព និងលទ្ធផល Trade SWAp ក្នុងចំណោមភាគីពាក់ព័ន្ធ

**P៣០ ៥** : សមត្ថភាពចរចារបស់ស្ថាប័នក្នុងរាជរដ្ឋាភិបាលកម្ពុជាដែលត្រូវបានចាត់តាំង និងពង្រឹង

# ការអនុវត្ត " កម្មវិធីការងារធ្វើកំណែទម្រង់ច្បាប់ និងការសន្យាដែលកើតចេញពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ( WTO ) " របស់ប្រទេសកម្ពុជា



# ការអនុវត្ត "កម្មវិធីការងារធ្វើកំណែទម្រង់ច្បាប់ និងកាសន្យា ដែលកើតចេញពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO)" របស់ប្រទេសកម្ពុជា

## សេចក្តីសង្ខេប


ដោយសារលទ្ធផលនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នៅដើមឆ្នាំ ២០០៤ នូវ "កម្មវិធីការងារ" ប្រកបដោយមហិច្ឆតាទៅលើការធ្វើកំណែទម្រង់ច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងអាជីវកម្មទាំងឡាយក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវបរិយាកាសបង្កលទ្ធភាព និងធ្វើឲ្យច្បាប់ស្តីពីពាណិជ្ជកម្មនិងច្បាប់ពាក់ព័ន្ធនឹងអាជីវកម្មរបស់ប្រទេសកម្ពុជាស្របទៅតាមគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ក្នុងចំណោមច្បាប់ទាំង ៧៤ អនុក្រឹត្យរបស់រដ្ឋាភិបាល និងបទបញ្ជារបស់ក្រសួងនានាដែលបានកំណត់ក្នុងរយៈពេលកន្លងមក ដើម្បីអនុវត្តកម្មវិធីនេះ គឺមានច្បាប់ចំនួន ៥០ (២/៣) ត្រូវបានប្រកាសឲ្យប្រើប្រាស់ និងអនុម័តនៅដើមឆ្នាំ២០១១។

កំណែទម្រង់ជាច្រើនទាំងនោះ គឺកើតចេញពីជំនួយបច្ចេកទេសរបស់នៃគម្រោងជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) នៅក្នុងដំណាក់កាលត្រួតពិនិត្យសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យនានាលើកដំបូង និងនៅក្នុងការកសាងសមត្ថភាពសម្រាប់អនុវត្តការងារ។ ការកៀងគរធនធាន និងការសម្របសម្រួលបច្ចេកទេស គឺមានប្រសិទ្ធភាពយ៉ាងខ្លាំងដោយមានភាពដឹកនាំច្បាស់លាស់មកពីស្ថាប័នមួយក្នុងជួររដ្ឋាភិបាល។ ការដាក់ចេញនូវអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) នៅដើមឆ្នាំ២០០៨ បានធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងឡាយ (និងក្នុងចំណោមដៃគូអភិវឌ្ឍន៍នានា) នៅក្នុងវិស័យដែលគ្របដណ្តប់ដោយកម្មវិធីការងារកំណែទម្រង់ច្បាប់។ ភាគច្រើននៃកំណែទម្រង់ដែលត្រូវបានអនុម័តរួចរាល់មានឥទ្ធិពលជាចម្បង និងវិជ្ជមានទៅលើការអភិវឌ្ឍអាជីវកម្ម ដែលធ្វើឲ្យមានការកើនឡើងជាពិសេសនូវកំណើនដ៏សំខាន់មួយទាំងការវិនិយោគក្នុងប្រទេស និងក្រៅប្រទេសនៅក្នុងប្រទេសកម្ពុជា ការរីកចម្រើនដ៏ខ្លាំងក្លាក្នុងផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម ឬ ភាពជឿនលឿនគួរឲ្យកត់សម្គាល់ក្នុងការអនុវត្ត និងការប្រើប្រាស់ការការពារសិទ្ធិកម្មសិទ្ធិបញ្ញា។


## ១ បញ្ហាដែលត្រូវបានដោះស្រាយ

ប្រទេសកម្ពុជាបានដាក់ពាក្យសុំចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៤។ ក្រុមការងារមួយត្រូវបានបង្កើតឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤។ អនុស្សារណៈរបស់កម្ពុជានៃរបបពាណិជ្ជកម្មបរទេសត្រូវបានដាក់ជូនអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៩។ ការចរចាជាច្រើនលើកទៅលើលក្ខខ័ណ្ឌនៃការក្លាយជាសមាជិករបស់ព្រះរាជាណាចក្រនេះ ត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័សនៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំដំបូងនៃសហសវត្សរ៍ថ្មីនេះ។ ពិធីសារនៃការចូលជាសមាជិករបស់ប្រទេសកម្ពុជាត្រូវបានយល់ព្រម និងចុះហត្ថលេខានៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្ថិតក្រោមការធ្វើសច្ចាប័នដោយរដ្ឋសភា និងព្រឹទ្ធសភា។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកទី១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។

នៅពេលដែលរៀបចំខ្លួនសម្រាប់ការធ្វើសច្ចាប័ន ក្រសួងពាណិជ្ជកម្ម និងក្រុមការងារចរចាអន្តរក្រសួងរបស់ប្រទេសកម្ពុជាសម្រាប់ការសុំចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) បានរៀបចំ "កម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកើតចេញពីការសុំចូលជាសមាជិករបស់ប្រទេសកម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO)" ដោយដាក់បញ្ចូលគ្នានៅក្នុងឯកសារតែមួយនូវការសន្យា និងតម្រូវការក្នុងការធ្វើកំណែទម្រង់ច្បាប់ដែលមានឥទ្ធិពលទៅលើពាណិជ្ជកម្ម និងអាជីវកម្មដែលបានកំណត់នៅក្នុងពិធីសារនៃការចូលជាសមាជិក។[២] កម្មវិធីនេះត្រូវបានដាក់ជូន និងឯកភាពដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៤។

[២] "កម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជាកើតចេញពីការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)", គណៈរដ្ឋមន្ត្រី ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០០៤

## ២ វត្ថុបំណងដែលសម្រេចបាន

នៅក្នុងវិធានការដ៏ធំនោះ រដ្ឋាភិបាលបានប្រើប្រាស់នូវឱកាសក្នុងការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) រួមទាំងការបង្កើតរូបមន្ត និងការចរចាលើពិធីសារក្នុងការចូលជាសមាជិករបស់ខ្លួនដើម្បីកំណត់ និងចាប់ផ្តើមអនុវត្តកម្មវិធីដ៏ធំមួយស្តីពីការធ្វើកំណែទម្រង់ច្បាប់ និងបទបញ្ញត្តិនានាក្នុងគោលបំណង ដើម្បីពង្រឹងបរិយាកាសបង្កលទ្ធភាពដល់ពាណិជ្ជកម្ម និងធុរកិច្ចរបស់ប្រទេសតាមវិធីយ៉ាងទូលំទូលាយ និងជំរុញផ្នែកពាណិជ្ជកម្ម និងការវិនិយោគ ដើម្បីបង្កើនល្បឿនការអភិវឌ្ឍ។ បញ្ហាប្រឈម គឺហាក់ដូចជាថ្មីសម្រាប់ប្រទេសកម្ពុជាដែលបន្ទាប់ពីរយៈពេលប៉ុន្មានឆ្នាំនៃសង្គ្រាមស៊ីវិល ត្រូវប្រឈមមុខនឹងកិច្ចការយ៉ាងធំក្នុងការកសាងក្របខ័ណ្ឌច្បាប់ឡើងវិញ ដើម្បីឲ្យមានបរិយាកាសបង្កលទ្ធភាពដល់ពាណិជ្ជកម្ម និងធុរកិច្ចដែលស្ទើរតែបាត់សូន្យទាំងស្រុងទៅហើយនោះ។

ដូចដែលបានបង្ហាញនៅក្នុងតារាង ១ "កម្មវិធីការងារ" ប្រកបដោយមហិច្ឆតានេះ បាននាំឲ្យមានភាពចាំបាច់ក្នុងការប្រកាសឲ្យប្រើប្រាស់ និងអនុម័តច្បាប់ចំនួន ៧៤ រួមទាំង("អនុក្រឹត្យ") របស់រដ្ឋាភិបាលនិងបញ្ញត្តិនានារបស់ក្រសួងសំខាន់ៗ ("ប្រកាស ") មួយចំនួនទៀត។[៣] នៅដើមឆ្នាំ២០១១ មានច្បាប់ចំនួន ៥0 រួមទាំងអនុក្រឹត្យ និងទបបញ្ញត្តិសំខាន់ៗមួយចំនួនទៀតត្រូវបានបញ្ចប់សព្វគ្រប់ ហើយមានច្បាប់ចំនួន៤ ផ្សេងទៀតត្រូវបានបញ្ជូន ឬ រៀបចំរួចរាល់ដើម្បីបញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីបន្តដំណើរការត្រួតពិនិត្យឡើងវិញ និងអនុម័តជាផ្លូវការ។ នេះបង្ហាញឲ្យឃើញនូវការរីកចម្រើនដ៏គួរឲ្យកត់សម្គាល់នៅក្នុងទិដ្ឋភាពនៃកិច្ចការដ៏ធំដែលប្រឈមនឹងរដ្ឋាភិបាលនៅក្នុងឆ្នាំ ២០០៤។

## ៣ បញ្ហាប្រឈម និងកត្តាឈានទៅរកជោគជ័យ

ដើម្បីអនុវត្តកម្មវិធីការងាររបស់ខ្លួនប្រកបដោយជោគជ័យ រាជរដ្ឋាភិបាលកម្ពុជាបានដោះស្រាយបញ្ហាប្រឈមមួយចំនួន និងកត្តាសំខាន់ៗ ដូចជា ៖

១. សម្របសម្រួលកិច្ចខិតប្រឹងប្រែងរបស់រដ្ឋាភិបាលជុំវិញកម្មវិធីប្រកបដោយមហិច្ឆតាដែលពាក់ព័ន្ធនឹងខ្សែបណ្តោយអន្តរក្រសួងជាច្រើន
២. ធានាឲ្យមានការចូលរួមមតិយោបល់ពីភាគីពាក់ព័ន្ធទាំងឡាយ
៣. ធានាឲ្យមានការផ្តល់ជំនួយបច្ចេកទេសនៅទីណាដែលចាំបាច់ និងពេលណាដែលអាចធ្វើទៅបាន
៤. សម្រាលកត្តាខាងក្រៅនានាដែលអាចនឹងជះឥទ្ធិពលអវិជ្ជមានលើការរីកចម្រើន និង
៥. អភិវឌ្ឍន៍សមត្ថភាពមនុស្ស និងស្ថាប័នដើម្បីអនុវត្ត និងដាក់ឲ្យអនុវត្តច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិថ្មីៗ។

### ៣.១ ការសម្របសម្រួលរបស់រដ្ឋាភិបាល

ចាប់តាំងពីមានការអនុម័តកម្មវិធីការងារមក ការសម្របសម្រួលរបស់រដ្ឋាភិបាលបានដំណើរការតាមពីររបៀប។ ទី១ នៅថ្នាក់ ក្រសួង គណៈកម្មាធិការអន្តរក្រសួងរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលមានក្រសួងពាណិជ្ជកម្មជាប្រធានដែលត្រូវបានបង្កើតឡើងដើម្បីដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងអំឡុងនៃការចរចា ត្រូវបានបង្កើតឡើង ដើម្បីជួយដល់ការសម្របសម្រួលរួមលើការអនុវត្តកម្មវិធីការងារនេះ។ ខណៈពេលដែលកម្មវិធីនេះបានចាត់ចែងការទទួលខុសត្រូវច្បាស់លាស់ទៅឲ្យខ្សែបណ្តោយអន្តរក្រសួង ទាំងឡាយដើម្បីរៀបចំធ្វើកំណែទម្រង់ផ្សេងៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំនោះក្រសួង ពាណិជ្ជកម្មបានប្រើប្រាស់ការទទួលខុសត្រូវក្នុងភាពជាប្រធានរបស់ខ្លួនដោយផ្អែកភាគច្រើនទៅលើមូលដ្ឋានពិសេស ធ្វើការដឹកនាំក្រសួងទាំងឡាយឲ្យចូលរួមដឹកនាំការត្រួតពិនិត្យឡើងវិញតាមពេលកំណត់ទៅលើការរីកចម្រើន និងពិភាក្សាអំពីតម្រូវការជំនួយបច្ចេកទេស។ លើសពីនេះទៀត ទៅតាមតម្រូវការចាំបាច់ និងនៅពេលដែលទំនួលខុសត្រូវនានាអាចនឹងត្រូវឆ្លងកាត់តាមក្រសួងជាច្រើន គណៈកម្មាធិការអន្តរក្រសួងត្រូវបានបង្កើតឡើងដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែកជាក់លាក់មួយចំនួនដែលត្រូវធ្វើកំណែទម្រង់ ៖ ឧទហរណ៍ជាក់ស្តែង គណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា (NCIPR) ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ (ព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហានេះមាននៅខាងក្រោម) ឬ នៅពេលថ្មីៗនេះ មានសេចក្តីព្រាងបទបញ្ញត្តិអន្តរក្រសួងស្តីពីការអនុវត្ត និងការរៀបចំស្ថាប័នទទួលបន្ទុកសុវត្ថិភាពស្បៀងអាហារដែលមានការពាក់ព័ន្ធនឹងក្រសួងមិនតិចជាង ៦ ឡើយ។

[៣] គួរកត់សម្គាល់ថា មានតែបញ្ញត្តិរបស់ក្រសួងសំខាន់ៗដែលពាក់ព័ន្ធនឹងកម្មវិធីកំណែទម្រង់ប៉ុណ្ណោះត្រូវបានរួមបញ្ចូល។ ជាអាទិ ការប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីគយ បាននាំឲ្យមានការអនុម័តនូវអនុក្រឹត្យរបស់រដ្ឋាភិបាល និងបទបញ្ញត្តិរបស់ក្រសួងទាំង ២៥។ មានតែអនុក្រឹត្យ និងទបបញ្ញត្តិស្តីពីការអនុវត្តកិច្ចព្រមព្រៀងស្តីពីការវាយតម្លៃគយប៉ុណ្ណោះ ត្រូវបានបង្ហាញនៅក្នុងតារាង។

ទី២ ដំណើរការត្រួតពិនិត្យឡើងវិញយ៉ាងហ្មត់ចត់របស់រដ្ឋាភិបាលនិងការអនុម័តរបស់អង្គនីតិបញ្ញត្តិត្រូវបានប្រើប្រាស់ដើម្បីធានាឲ្យមានសេចក្ដីព្រាងត្រឹមត្រូវការត្រួតពិនិត្យឡើងវិញ និងការអនុម័តសមស្របទៅលើអត្ថបទច្បាប់នានា។ ជាទូទៅច្បាប់នីមួយៗត្រូវឆ្លងកាត់ ៨ដំណាក់កាល(ដោយអាចនឹងមានការបញ្ជូនត្រឡប់ទៅមកនៅត្រង់ចំណុចខ្លះដើម្បីឲ្យអ្នកធ្វើសេចក្ដីព្រាងនោះឆ្លើយតបទៅនឹងមតិយោបល់ផ្សេងៗ) មុននឹងព្រះមហាក្សត្រប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ៖

១. ក្រសួងពាក់ព័ន្ធបង្កើតក្រុមការងារធ្វើសេចក្ដីព្រាងច្បាប់។
២. សេចក្ដីព្រាងច្បាប់ត្រូវបានរៀបចំឡើង និងធ្វើការត្រួតពិនិត្យឡើងវិញនៅថ្នាក់ក្រសួង។ នៅពេលដែលមានការផ្ដល់ជំនួយបច្ចេកទេស ជាទូទៅ សេចក្ដីព្រាងច្បាប់ដំបូងត្រូវធ្វើឡើងជាភាសាអង់គ្លេសមុននឹងធ្វើការបកប្រែទៅជាភាសាខ្មែរ។
៣. ខ្សែបណ្ដោយអន្តរក្រសួងត្រូវស្វែងរកការចូលរួមមតិយោបល់ពីភាគីពាក់ព័ន្ធនានា។
៤. ក្រោយពីក្រសួងមួយបានអនុម័ត សេចក្ដីព្រាងច្បាប់នោះនឹងត្រូវដាក់ជូនទៅគណៈរដ្ឋមន្ត្រី
៥. បន្ទាប់មក សេចក្ដីព្រាងច្បាប់នេះនឹងត្រូវពិនិត្យឡើងវិញដោយក្រុមការងារអន្តរក្រសួង ដោយក្រុមប្រឹក្សាយុត្តិធម៌ដើម្បីធានាបាននូវការគោរពតាមច្បាប់រដ្ឋធម្មនុញ្ញ និងត្រួតពិនិត្យដោយ ECOSOCC (ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌) ដើម្បីវាយតម្លៃលើផលប៉ះពាល់ដែលអាចកើតមានទៅលើសេដ្ឋកិច្ច សង្គម និងវប្បធម៌។
៦. ក្រោយពីគណៈរដ្ឋមន្ត្រីបានអនុម័ត សេចក្ដីព្រាងច្បាប់នេះនឹងត្រូវដាក់ទៅរដ្ឋសភា។
៧. ដំបូងឡើយ សេចក្ដីព្រាងច្បាប់នេះត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការដែលសមស្របរបស់រដ្ឋសភា បន្ទាប់មកទៀតត្រួតពិនិត្យ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាមុនពេលដាក់ជូនទៅសភាពេញអង្គដើម្បីពិភាក្សា។
៨. បន្ទាប់ពិភាក្សា និងអនុម័តដោយរដ្ឋសភា សេចក្ដីព្រាងច្បាប់នេះអាចនឹងត្រូវធ្វើវិសោធនកម្មហើយដាក់ជូនទៅព្រឹទ្ធសភាដើម្បីធ្វើសច្ចាប័ន។
៩. ក្រោយពីព្រឹទ្ធសភាធ្វើសច្ចាប័នរួច ច្បាប់នេះនឹងត្រូវដាក់ថ្វាយទៅព្រះមហាក្សត្រដើម្បីប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ។

## ៣.២ ការធានាឲ្យមានការចូលរួមមតិយោបល់ពីភាគីពាក់ព័ន្ធ

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ រដ្ឋាភិបាលបានគិតគូយ៉ាងខ្លាំងទៅលើការធានាឲ្យមានការចូលរួមមតិយោបល់ពីភាគីពាក់ព័ន្ធនានាជាពិសេស វិស័យឯកជន នៅក្នុងអំឡុងដំណាក់កាលធ្វើសេចក្ដីព្រាងច្បាប់ ប៉ុន្តែមិនមែនផ្ដាច់មុខតែឯងនោះទេ។ ដោយសារតែគ្មានដំណើរការផ្លូវការ មធ្យោបាយនៃការពិភាក្សាត្រូវបានធ្វើឡើងតាមរយៈវិធីសាស្ត្រចម្រុះដូចខាងក្រោម ៖
១. សិក្ខាសាលាដែលរៀបចំឡើងដោយក្រសួងពាក់ព័ន្ធនានាដើម្បីលើកឡើង និងពិភាក្សាលើសេចក្ដីព្រាងច្បាប់។
២. ការប្រឹក្សាមួយទល់មួយជាមួយនឹងសមាគមផលិតផល។
៣. ការប្រើប្រាស់ក្រុមការងារស្ថិតក្រោមវេទិកាការរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ជាពិសេសក្រុមការងារផ្នែកច្បាប់ ពន្ធដារ និងផ្នែកគ្រប់គ្រងដែលមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន និងក្រុមការងារទទួលបន្ទុកដំណើការនាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្មដែលមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាប្រធាន។

លើសពីនេះទៀត ក្រសួងនានាបានរួមចំណែកជាញឹកញាប់ក្នុងការធ្វើសេចក្ដីព្រាងច្បាប់ជាមួយនឹងដៃគូអភិវឌ្ឍន៍ក្នុងនាមជាអង្គការពហុភាគី (ដូចជាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា (IPRs), អង្គការពន្ធគយពិភពលោក (WCO) ទទួលបន្ទុកផ្នែកពន្ធគយ ជាដើម) ឬ ដៃគូទ្វេភាគី (សហរដ្ឋអាមេរិក បារាំង ជប៉ុន សហភាពអឺរ៉ុប ប្រទេសផ្សេងៗទៀត) ដើម្បីស្នើសុំមតិយោបល់ និងការណែនាំផ្សេងៗពីពួកគេ។

## ៣.៣ ជំនួយសម្រាប់ពាណិជ្ជកម្ម

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ ប្រទេសកម្ពុជាបានទទួលជំនួយបច្ចេកទេសផ្សេងៗដើម្បីជួយដល់ក្រសួងនានាក្នុងការធ្វើសេចក្ដីព្រាងច្បាប់ អនុក្រឹត្យ ឬ បទបញ្ញត្តិមួយចំនួន (តារាង ១)។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយសម្រាប់ពាណិជ្ជកម្មដើម្បីជួយរៀបចំច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិនានានៅក្នុងការធ្វើកំណែទម្រង់យ៉ាងតិច ៤១ ក្នុងចំណោម ៧៤ ដែលបានកំណត់។[៤]

ជាទូទៅ ការសម្របសម្រួលជំនួយសម្រាប់ពាណិជ្ជកម្មបានធ្វើឡើងនៅថ្នាក់ក្រសួងសាមី។ វាបានដំណើរការយ៉ាងល្អក្នុងករណីពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់គយ និងស្ថាប័នក្រោមការសម្របសម្រួល របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មានការចូលរួមពី មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), អង្គការពន្ធគយពិភពលោក (WCO), គម្រោងកិច្ចសម្រួលពាណិជ្ជកម្ម និងការប្រកួត

[៤] ព័ត៌មានមួយចំនួនសម្រាប់ច្បាប់មួយចំនួនក្នុងចំណោមច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិនានាកំពុងតែបាត់បង់ ដូច្នេះហើយចំនួនសរុបនៃជំនួយអាចនឹងកាន់តែខ្ពស់ឡើង។

ប្រជែង (TFCP) របស់ធនាគារពិភពលោក, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JAICA), ទីភ្នាក់ងារផ្ដល់ជំនួយអូស្ត្រាលីសម្រាប់ការអភិវឌ្ឍ (AusAid), កម្មវិធីជំនួយ ប្រទេសញ៉ូវហ្សីឡែន (NZAid) និងសហភាពអឺរ៉ុប (EU)។ ក្នុងដំណើរឆ្ពោះទៅមុខ បានទទួលជំនួយគួរឲ្យកត់សម្គាល់ពីកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) នៃកម្មវិធីអភិក្រមគ្រប់ដណ្ដប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) និងមូលនិធិពហុម្ចាស់ជំនួយ [៥] របស់អ្នកផ្ដល់ជំនួយពហុភាគី ដើម្បីបន្តធ្វើការលើក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិគយ បង្កើនការយល់ដឹង និងការឈ្វេងយល់អំពីនីតិវិធីគយនៅក្នុងវិស័យឯកជន និងបន្តកសាងសមត្ថភាពរបស់មន្ត្រីគយ។ ដូចគ្នានេះដែរ គណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា (D/IPR) នៃក្រសួងពាណិជ្ជកម្ម បច្ចុប្បន្ននេះកំពុងព្យាយាមជួយសម្របសម្រួលជំនួយគាំទ្រពី អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO), កម្មវិធីប្រចាំតំបន់របស់កម្មវិធីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា (ECAP III) របស់សហភាពអឺរ៉ុប (EU), ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងជំនួយគាំទ្រផ្សេងទៀតដែលអាចរកបាននៅក្នុងចំណោមក្រសួងផ្សេងៗ ដោយមានការទទួលខុសត្រូវនៅក្នុងផ្នែកកម្មសិទ្ធិបញ្ញាដែលបានជ្រើសរើស។ ដូចបានបង្ហាញខាងក្រោម មានការរំពឹងថា គណៈកម្មាធិការជាតិទទួល បន្ទុកកម្មសិទ្ធិបញ្ញា (NCIPR) នឹងបានទទួល ជំនួយពីកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) ដើម្បីចងក្រងឯកសារបណ្ដុះបណ្ដាលដល់ សិស្ស និងអ្នកមានអាជីពផ្នែកច្បាប់បច្ចុប្បន្ន ស្ដីពីសិទ្ធិកម្មសិទ្ធិបញ្ញា (IPR) នៅក្នុងប្រទេសកម្ពុជា។

នៅក្នុងផ្នែកផ្សេងៗទៀត ការសម្របសម្រួលមិនមែនសុទ្ធតែមានប្រសិទ្ធភាពទាំងអស់នោះទេ ដែលនាំឲ្យមានការបាត់បង់ជំនួយបច្ចេកទេសនៅពេលដែលគេត្រូវការវា ឬ ការផ្ដល់ត្រួតគ្នាដែលមិនចាំបាច់ក្នុងចំណោមអ្នកផ្ដល់ជំនួយ ដោយសារតែការបរាជ័យរបស់ដៃគូអភិវឌ្ឍន៍នានាក្នុងការសម្របសម្រួលនៅក្នុងចំណោមពួកគេ។ ទោះជាយ៉ាងនេះក្ដី ក៏នៅមានការរីកចម្រើននៅក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែការដាក់ចេញនូវអភិក្រមគ្រប់ដណ្ដប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលបានជួយឲ្យរដ្ឋាភិបាលកាន់តែមានភាពច្បាស់លាស់ និងនាំយកស្មារតីនៃវិន័យដាក់បញ្ចូលទៅក្នុងចំណោមគម្រោងអភិវឌ្ឍន៍ (DP) ដែលវាអាចមានការខ្វះខាតកាលពីអតីតកាល។

## ៣.៤ ការកាត់បន្ថយកត្តាខាងក្រៅ

កត្តាដែលរាជរដ្ឋាភិបាលកម្ពុជាបានគ្រប់គ្រងតិចតួចបំផុតនោះ គឺលទ្ធភាពទទួលបានការគាំទ្រពាក់ព័ន្ធនឹងជំនួយសម្រាប់ពាណិជ្ជកម្ម។ ដូចបានបញ្ជាក់ខាងលើ លទ្ធភាពទទួលបានជំនួយបច្ចេកទេសដែលពាក់ព័ន្ធ ត្រូវបានពង្រឹងដោយសារតែមានការណែនាំនាពេលថ្មីៗនេះនូវអភិក្រមគ្រប់ដណ្ដប់លើវិស័យពាណិជ្ជកម្ម (Trade SWAp)។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំដំបូង បានបង្ហាញឲ្យឃើញនូវការផ្ដល់ ជំនួយត្រួតគ្នាដែលគ្មានប្រសិទ្ធភាព និងគ្មានហេតុផលសមស្របពីសំណាក់ដៃគូអភិវឌ្ឍន៍ ហើយមិនមានជំនួយគាំទ្រនៅពេលដែលគេត្រូវការវា។

## ៣.៥ សមត្ថភាពមនុស្ស និងស្ថាប័នក្នុងការអនុវត្ត និងដាក់ឲ្យអនុវត្តច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិថ្មីៗ

ជាការពិតណាស់ ការធ្វើកំណែទម្រង់ច្បាប់ គឺមិនមានទីបញ្ចប់នោះទេ ប៉ុន្តែត្រូវចាប់ផ្ដើមពីចំណុចដែលបង្កើតបរិយាកាសអំណោយផលដល់អាជីវកម្ម និងទំនាក់ទំនងសង្គមនៅក្នុងសង្គម។ ដើម្បីឲ្យការធ្វើកំណែទម្រង់ច្បាប់មានប្រសិទ្ធភាព គឺតម្រូវឲ្យមានមនុស្ស និងស្ថាប័នសម្រាប់អនុវត្ត និងដាក់ឲ្យអនុវត្តច្បាប់ និងបទបញ្ញត្តិនានា។ ប្រសិនបើផ្នែកដ៏ធំនៃកំណែទម្រង់នោះបានគ្របដណ្ដប់លើកម្មវិធីការងារ នោះវានឹងមិនអាចពិភាក្សាគ្នានៅទីនេះទៅលើផ្នែកទាំងអស់ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែមានភាពសកម្មនៅក្នុងការអភិវឌ្ឍសមត្ថភាពគាំទ្រនោះបានទេ។ បើនិយាយឲ្យចំទៅ គឺថាការខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាព និងកៀងគរធនធានជំនួយបច្ចេកទេសកំពុងស្ថិតក្នុងដំណើរការនៅក្នុងផ្នែកមួយចំនួនធំ។ ការកើនឡើងនូវចំណាប់អារម្មណ៍ពីដៃគូអភិវឌ្ឍន៍ ចំពោះការកសាងសមត្ថភាពនៅក្នុងផ្នែកជាច្រើនដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មដែលបានចាប់ផ្ដើមឡើងនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ ២០០០ រួមជាមួយនឹងការដាក់ចេញនូវអភិក្រមគ្រប់ដណ្ដប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) បានជួយដល់ដំណើរការនេះ។

ការអនុវត្ត និងការដាក់ឲ្យអនុវត្តនូវការគាំពារកម្មសិទ្ធិបញ្ញាដែលជាផ្នែកមួយក្នុងចំណោមផ្នែកសំខាន់ៗនៃកំណែទម្រង់ដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីការងារនោះ បានធ្វើឲ្យមានការយល់ដឹងកាន់តែច្បាស់លើផ្នែកមួយចំនួន។ ទំនួលខុសត្រូវនានាចំពោះការគាំពារសិទ្ធិកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា ត្រូវបានបែងចែកនៅក្នុងចំណោមក្រសួងជាច្រើន។ ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវចំពោះពាណិជ្ជសញ្ញា និងការសម្គាត់ផ្នែកពាណិជ្ជកម្ម។ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលទទួលខុសត្រូវចំពោះប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសសៀគ្វីបម្រួម។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈទទួលខុសត្រូវចំពោះសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលផ្សេងៗទៀត ក្រសួងព័ត៌មានទទួលខុសត្រូវចំពោះការផ្សព្វផ្សាយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ទទួលខុសត្រូវចំពោះវិស័យអ៊ិនធឺណិត ទំនួលខុសត្រូវចំពោះសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងនឹងត្រូវបែងចែករវាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

(៥) TDSP ឬ កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្មត្រូវបានរៀបចំឡើងដើម្បីជួយគាំទ្រដល់វត្ថុបំណងមួយចំនួនក្នុងចំណោមវត្ថុនៃអភិក្រម Trade SWAp ហើយត្រូវបានអនុវត្តដោយក្រសួងពាណិជ្ជកម្ម (MoC)។ កម្មវិធីនេះទទួលបានមូលនិធិពីមូលនិធិក្នុងអាណត្តិព្យាបាលភាពរបស់ម្ចាស់ជំនួយពហុភាគី (MDTF) និងគ្រប់គ្រងដោយធនាគារពិភពលោក និងផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប (EU), ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណាម៉ាក (Danida) និងអង្គការ អភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (UNIDO)។

ក្រសួងនីមួយៗបានកំពុងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យដែលខ្លួន គ្រប់គ្រង។ ការចុះបញ្ជីស្លាកសញ្ញាដែលធ្វើឡើងដោយក្រសួងពាណិជ្ជកម្មបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ (មានចំនួន ៣៦ ០៩១ នៅចុងឆ្នាំ ២០១០)។ ការចុះបញ្ជីដោយគ្មានអាណត្តិនូវសិទ្ធិអ្នកនិពន្ធក៏មានការកើនឡើងផងដែរ (ប្រហែល ៥០ នៅក្នុងឆ្នាំ ២០១០) ទោះបីជាយ៉ាងនេះក្តី ក៏វិសាលភាពរបស់វាកាន់តែមានដែនកំណត់ដោយសារតែប្រទេសកម្ពុជា មិនទាន់ក្លាយជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ឺន ទើបវាមិនបានការពារសិទ្ធិការងារដែលបង្កើតឡើងនៅខាងក្រៅប្រទេសកម្ពុជា។ ការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបានកើនឡើងប្រហែល ១០០នៅចុងឆ្នាំ២០១០ ប៉ុន្តែក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅតែកំពុងធ្វើការងារលើការដាក់ឲ្យអនុវត្តដំណើរការចុះបញ្ជីផ្លូវការដោយមានជំនួយខ្លះពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។ គំនូរឧសហ្សាហកម្មជាង ១០០ ត្រូវបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

យន្តការសម្រាប់ការដោះស្រាយវិវាទមានការប្រែប្រួលអាស្រ័យទៅលើលក្ខណៈនៃសិទ្ធិ ប៉ុន្តែមានសម្រាប់អនុវត្ត ឬ កំពុងតែដាក់ឲ្យអនុវត្តនៅក្នុងវិស័យកម្មសិទ្ធបញ្ញា (IP) ភាគច្រើន។ ជាពិសេស អ្នកគ្រប់គ្រងសិទ្ធិអាចប្រើប្រាស់មធ្យោបាយមួយចំនួនដើម្បីការពារសិទ្ធិមានដូចជា "បញ្ឈប់ ឬ ផ្អាក" លិខិត ឬ ការសម្រុះសម្រួលតាមរយៈក្រសួងពាក់ព័ន្ធ (រួមមាន ក្រសួងពាណិជ្ជកម្មបានសម្រុះសម្រួល និងបានដោះស្រាយបញ្ហាវិវាទទាក់ទងនឹងពាណិជ្ជនាមចំនួន ៣២ ក្នុងចំណោម ៣៥ នៅក្នុងឆ្នាំ ២០១០) ដោយសុំជំនួយពីនរគបាលសេដ្ឋកិច្ច (នគរបាលសេដ្ឋកិច្ចមានអំណាចធ្វើការ "ផាកពិន័យ" ចំពោះអ្នករំលោភបំពាន បញ្ឈប់ការក្លែងបន្លំ (ដូចជា មានស៊ីឌី/វីស៊ីឌីចំនួន ២៥០ ០០០បន្ទះ ត្រូវបានរឹបអូសនៅក្នុងឆ្នាំ ២០១០ ដែលលើសពីឆ្នាំ ២០០៩ ចំនួន ២៧ ០០០ បន្ទះ) ឬ ស្នើទៅតុលាការដើម្បីអធិបញ្ញា។

ប៉ុន្តែ បទពិសោធន៍ដំបូងនៅក្នុងការដោះស្រាយវិវាទបានបង្ហាញឲ្យឃើញពីតម្រូវការធ្វើការសម្របសម្រួលបន្ថែមនៅក្នុងចំណោមអ្នកអនុវត្តជាច្រើនដែលទទួលខុសត្រូវក្នុងការអនុវត្ត និងដាក់ឲ្យអនុវត្តសិទ្ធិផ្សេងៗ មិនត្រឹមតែខ្សែបណ្តោយអន្តរក្រសួងដូចបានលើកឡើងពីខាងដើមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនគរបាលសេដ្ឋកិច្ចរបស់ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ អាហារណ នីហារណ និងបង្ក្រាបការក្លែងបន្លំនៃក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងផ្សេងៗទៀតផងដែរ។ នៅឆ្នាំ ២០០៨ រដ្ឋាភិបាលបានអនុម័តនូវ អនុក្រឹត្យមួយដែលបង្កើតគណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា (NCIPR) ដើម្បីសម្របសម្រួលភ្នាក់ងារទាំងអស់ដែលពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា។

គណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា (NCIPR) ថ្មីនេះ កើតចេញពីការពង្រីកគណៈកម្មាធិការពីដំបូង (គណៈកម្មាធិការអន្តរក្រសួងគ្រប់គ្រងផ្នែកទាំង ៣ នៃកម្មសិទ្ធិបញ្ញា)។ បន្ថែមទៅលើការផ្តោតការយកចិត្តទុកដាក់លើតម្រូវការជំនួយបច្ចេកទេស និងការសម្របសម្រួលឲ្យមានការទទួលបាននូវធនធានជំនួយសម្រាប់ពាណិជ្ជកម្ម គណៈកម្មាធិការនេះបានបង្កើតអនុគណៈកម្មាធិការចំនួន ២ គឺ ៖ អនុគណៈកម្មាធិការមួយផ្តោតលើការដាក់ឲ្យអនុវត្ត និងមួយទៀតផ្តោតលើការអប់រំ (បទបញ្ញត្តិដែលបង្កើតអនុគណៈទាំង ២ នោះ នៅមិនទាន់បានប្រើប្រាស់នៅឡើយទេ)។ អនុគណៈកម្មាធិការទី ១ មានផែនការពង្រឹងការសម្របសម្រួលនៅក្នុងចំណោមភ្នាក់ងារនានាដែលកំពុងធ្វើការងារនៅក្នុងផ្នែកនេះ កំណត់ទំនួលខុសត្រូវច្បាស់លាស់ បង្កើតគោលការណ៍ណែនាំនានាដែលមានសង្គតភាពនឹងគ្នា និងបង្កើតកម្មវិធី Databases ក្នុងការដាក់ឲ្យអនុវត្ត។ អនុគណៈកម្មាធិការទី ២ មានបំណងបង្កើតឯកសារកម្មវិធីបណ្តុះបណ្តាលដល់អ្នកមានអាជីពការងារផ្នែកច្បាប់នៅកម្រិតសាកលវិទ្យាល័យ ព្រមទាំងអ្នកមានអាជីពការងារផ្សេងៗដែលកំពុងអនុវត្តការងារផងដែរ និងដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនទូទៅផងដែរ។ កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម បានឯកភាពរួចហើយលើការផ្តល់មូលនិធិមួយចំនួនសម្រាប់ បង្កើតឯកសារកម្មវិធីបណ្តុះបណ្តាល។

និយាយឲ្យខ្លីទៅ រដ្ឋាភិបាលបានធ្វើដំណើរហួសពីដំណើរការធម្មតានៃការតាក់តែង និងការអនុម័តច្បាប់ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការបង្កើតស្ថាប័នដើម្បីអនុវត្ត និងដាក់ឲ្យអនុវត្ត។ ជំនួយសម្រាប់ពាណិជ្ជកម្មដើរតួនាទី និងទំនងជាបន្តដើរតួនាទីយ៉ាងសំខាន់នៅក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាពរបស់រដ្ឋាភិបាលដើម្បីអនុវត្ត និងដាក់ឲ្យអនុវត្តច្បាប់។

## ៤ លទ្ធផលដែលសម្រេចបាន- ប្រសិទ្ធភាពដែលអាចវាស់វែងបាន

ជាថ្មីម្តងទៀត ទាក់ទងនឹងលក្ខណៈរីករាលដាលនៃកំណែទម្រង់ស្ថិតក្រោមកម្មវិធីការងារនេះ និងលក្ខណៈខ្លីៗនៃករណីសិក្សា វាជាការលំបាកក្នុងការអនុវត្តការពិនិត្យឡើងវិញដោយផិតដល់បំផុតទៅលើលទ្ធផលដែលសម្រេចបានដោយកម្មវិធីការងារនេះ។ ប៉ុន្តែ ឧទហរណ៍មួយចំនួនបានបង្ហាញ ឲ្យឃើញនូវវិសាលភាពនៃការប្រែប្រួលដែលមានលក្ខណៈវិជ្ជមាន។

កម្មវិធីកិច្ចសម្រួលពាណិជ្ជកម្ម គឺជាផ្នែកមួយដែលមានភាពប្រសើរឡើងតាមផ្នែកដោយសារតែការអនុវត្តច្បាប់គយ និងការអភិវឌ្ឍសមត្ថភាពនៅក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ ក្នុងនោះមានដូចជា ចំនួនថ្ងៃដែលត្រូវការដើម្បីពិនិត្យកុងតេនឺនាំទំនិញចេញចូលឆ្លងកាត់គយបានថយចុះជិតពាក់កណ្តាលចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០មក គឺ ៣៧ថ្ងៃទៅនៅត្រឹម ២២ ថ្ងៃ សម្រាប់កុងតេនឺនាំទំនិញចេញ និងពី ៤៥ ថ្ងៃ ទៅនៅត្រឹម ២៧ ថ្ងៃសម្រាប់កុងតេនឺនាំទំនិញចូល។(៦)

(៦) សូមមើល "ករណីសិក្សាស្តីពីជំនួយសម្រាប់ពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាលេខ ២ ៖ កំណែទម្រង់ការសម្របសម្រួលពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា "សម្រាប់ព័ត៌មានពិស្តារបន្ថែម។

ការគាំពារកម្មសិទ្ធិបញ្ញា គឺជាផ្នែកមួយផ្សេងទៀតដែលបានបង្ហាញនូវការអភិវឌ្ឍគួរឲ្យកត់សម្គាល់។ តាមការកត់សម្គាល់ពីមុនមក មានពាណិជ្ជសញ្ញាជាង ៣៦ ០០០ ត្រូវបានចុះបញ្ជី គិតមកដល់ចុងឆ្នាំ២០១០។ គួរឲ្យកត់សម្គាល់ជាងនេះទៅទៀត មានការកើនឡើងជាគំហុកក្នុងការចុះបញ្ជីប្រចាំឆ្នាំដែលចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៧ (ក្រាហ្វិក ១)។ ស្របពេលជាមួយគ្នានោះ ការងារកម្មសិទ្ធិបញ្ញាចំនួន ៥០ ត្រូវបានចុះបញ្ជីនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (ស្នាដៃទាំងអស់នោះនិពន្ធដោយអ្នកនិពន្ធជនជាតិកម្ពុជា)។ ពាក្យប្រកាសនីយបត្រតក្កកម្មប្រហែល ១០០ និងពាក្យសុំការគំនូរស្សាហកម្មចំនួន ១៣០ ត្រូវបានទទួលដោយនាយកដ្ឋានកម្មសិទ្ធិឧស្សាកម្មនៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។ ម៉ាកសម្គាល់ភូមិសាស្ត្រផលិតផលចំនួន ២ ត្រូវបានបង្កើតឡើង ក្នុងនោះមួយសម្រាប់ផលិតផលម្រេចក្នុងខេត្តកំពត និងមួយទៀតសម្រាប់ផលិតផលស្ករត្នោតក្នុងខេត្តកំពង់ស្ពឺ (រូបភាព ១) ដោយមានក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ (MAFF) ជួយដល់ក្រសួងពាណិជ្ជកម្ម (MoC) នៅក្នុងការបង្កើតព្រំដែនទីតាំងភូមិសាស្ត្រនៃម៉ាកសម្គាល់ភូមិសាស្ត្រផលិតផលទាំងនោះ។

កំណើនគួរឲ្យកត់សម្គាល់លើការវិនិយោគពីបរទេស បានកើតចេញពីផ្នែកមួយនៃបរិយាកាសដែលបង្កលទ្ធភាពល្អប្រសើរដល់ធុរកិច្ច, លទ្ធផលនៃកំណែទម្រង់លើផ្នែកជាច្រើននៃច្បាប់វិនិយោគ, តំបន់សេដ្ឋកិច្ចពិសេស (SEZ) និងផ្នែកផ្សេងៗទៀត។ ស្ថិតិនៃសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ(UNCTAD)បង្ហាញថាការវិនិយោគផ្ទាល់ពីបរទេសចូលមកក្នុងប្រទេសកម្ពុជាបានកើនឡើងយ៉ាងខ្លាំងចាប់ពីឆ្នាំ២០០៣មក គឺ កើនពី ៨០លានដុល្លារអាមេរិក ទៅដល់ ១៣១លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៤, ៣៨១លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៥, ៤៨៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៦ និង ៨៦៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧, ៨១៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៨ និង ៥៣៣លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៩។ [៧]បន្ទាប់ពីអំឡុងពេលទទួលរងវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០០៨ - ២០០៩ មានការបង្ហាញឲ្យឃើញជាដំបូងថា ការិនិយោគពីបរទេសបានលោតឡើងវិញក្នុងឆ្នាំ ២០១០។

## ៥ បទពិសោធន៍ដែលទទួលបាន

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការអនុវត្តកម្មវិធីការងារប្រកបដោយមហិច្ឆតារបស់ខ្លួនលើការធ្វើកំណែទម្រង់ច្បាប់ដោយសារតែការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ការរីកចម្រើននេះមានលក្ខណៈគួរឲ្យកត់សម្គាល់ និងមានភាពឆាប់រហ័សយ៉ាងខ្លាំងនៅលើផ្នែកមួយចំនួនដែលមានការដឹកនាំដ៏រឹងមាំដោយស្ថាប័នមួយ និងលើផ្នែកដែលរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពកៀងគរ និងសម្របសម្រួលធនធានជំនួយសម្រាប់ពាណិជ្ជកម្ម (AfT)។ ការរីកចម្រើនលើផ្នែកមួយចំនួននៃច្បាប់ពន្ធគយ និងការការពារកម្មសិទ្ធិបញ្ញា អាចជាឧទាហរណ៍ដ៏ល្អសម្រាប់ករណីនេះ។ ម៉្យាងវិញទៀត ការរីកចម្រើនអាចនឹងមានការលំបាក ឬកាន់តែយឺតយ៉ាវក្នុងការសម្រេចបានលទ្ធផលចំពោះផ្នែកដែលការដឹកនាំដ៏ច្បាស់លាស់ត្រូវការពេលវេលាយូរដើម្បីឲ្យលេចចេញជារូបរាង (ប្រហែលជាដោយសារតែពេលវេលាដែលត្រូវការដើម្បីបែងចែកប្រភេទបណ្តាញទំនួលខុសត្រូវនៅក្នុងចំណោមក្រសួងផ្សេងៗ) ដោយសារតែមានលំបាកកាន់តែធំធេងក្នុងការកៀងគរធនធានជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) ឬ ដោយសារតែកត្តាផ្សេងៗទៀត។ ផ្នែកអនាម័យ និងភូតគាមអនាម័យ (SPS) ពាក់ព័ន្ធនឹងពាណិជ្ជកម្ម គឺជាឧទហរណ៍ដ៏សមស្របមួយសម្រាប់ករណីលើកក្រោយ។ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងជាថ្មីម្តងទៀតពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងជំនួយគាំទ្រថ្មីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) បានស្នើសុំឲ្យមានការអភិវឌ្ឍលក្ខណៈវិជ្ជមានឆាប់រហ័សបន្ថែមទៀតទៅលើដំណើរការឆ្ពោះទៅមុខ។

ការបន្តវត្តមានរបស់គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកអនុវត្តកាតព្វកិច្ច និងការសន្យារបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលមានក្រសួងពាណិជ្ជកម្មជាប្រធាន ដើម្បីផ្តល់ការយល់ដឹងស៊ីជម្រៅបន្ថែមអំពីការអនុវតកម្មវិធីការងារត្រូវបានធ្វើឡើងក្នុងគោលបំណងមួយផ្នែក ដើម្បីធានាឲ្យមានការគោរពច្បាប់ស្របតាមកិច្ចព្រមព្រៀង និងគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅពេលដែលអាចអនុវត្តបាន។ ជាពិសេស សេចក្តីព្រាងច្បាប់ដែលត្រូវធ្វើការពិនិត្យឡើងវិញ និងផ្តល់មតិយោបល់ដោយក្រសួងពាណិជ្ជកម្មដើម្បីឲ្យស្របទៅតាមគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ចំណុចនេះមិនមែនសុទ្ធតែជាករណី ដែលមានលទ្ធផលមិនល្អចំពោះច្បាប់មួយចំនួនដែលត្រូវបានអនុម័តដោយគ្មានបទបញ្ញត្តិស្របតាមអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលនឹងតម្រូវឲ្យមានការធ្វើវិសោធនកម្មបន្ថែមទៀតនោះទេ។

កំណែទម្រង់ច្បាប់មិនបានបញ្ឈប់ត្រឹមការប្រកាសឲ្យប្រើប្រាស់ច្បាប់ និងការអនុវត្តអនុក្រឹត្យនានារបស់រាជរដ្ឋាភិបាល និងបទបញ្ជានានារបស់អន្តរក្រសួងនោះឡើយ។ សមត្ថភាពរបស់មនុស្ស និងស្ថាប័នក៏ត្រូវតែអភិវឌ្ឍផងដែរដើម្បីអនុវត្ត និងដាក់ឲ្យអនុវត្តច្បាប់ និងបទបញ្ជាថ្មីៗ។ ដំណើរការនេះកំពុងតែមានចលនាទៅមុខក្នុងល្បឿនមួយកាន់តែលឿនសម្រាប់ផ្នែកមួយចំនួនលើសពីផ្នែកដទៃទៀត។ ការអនុវត្តលើផ្នែកមួយចំនួន គឺមានភាពយឺតយ៉ាវដោយសារតែតម្រូវឲ្យធ្វើការបែងចែកទំនួលខុសត្រូវនៅក្នុងចំណោមក្រសួងពាក់ព័ន្ធនានា និងមានជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) មិនគ្រប់គ្រាន់។ ទំនាក់ទំនងទន់ខ្សោយបំផុតក្នុងការជំរុញការអនុវត្តច្បាប់ គឺនៅតែធ្លាក់ទៅលើប្រព័ន្ធច្បាប់ដែលទន់ខ្សោយ និងប្រព័ន្ធតុលាការដែលបានបង្កើតឡើងនោះដដែល។

---

[៧] UNCTAD, របាយការណ៍ស្តីពីការវិនិយោគសាកលឆ្នាំ២០១០ ទីក្រុងហ្សឺណែវ ឆ្នាំ២០១០

**តារាងទី ១ ៖** កម្មវិធីការងារកំណែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមលក្ខខណ្ឌការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) (នៅខែតុលា ឆ្នាំ២០០៤) ស្ថានភាពនៃការអនុវត្តមកដល់ខែកុម្ភៈ ឆ្នាំ២០១១

## ពាណិជ្ជកម្ម

| ផ្នែក | ច្បាប់/អនុក្រឹត្យ/បទបញ្ញាអន្តរក្រសួង (ប្រកាស) | ភាគីទទួលខុសត្រូវ | ស្ថានភាពមកត្រឹមខែកុម្ភៈ ឆ្នាំ២០១១ | TRTA ដែលបានទទួល (អតីតកាល ឬ បច្ចុប្បន្ន) |
|---|---|---|---|---|
| ១. | អនុក្រឹត្យលេខ ២១ ស្តីពី "ការគ្រប់គ្រងហានិភ័យនៅតាមព្រំដែន" | MEF ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខែមីនា ឆ្នាំ២០០៦ | AusAid, WB, IMF |
| ២. | ច្បាប់ពន្ធគយ (អនុក្រឹត្យ ១, ប្រកាស ២៥ ដែលអនុម័តហើយ។ មានតែអនុក្រឹត្យលេខ ២០៩ និងប្រកាស លេខ ៣៨៧ របស់ MEF ដែលបានបង្ហាញខាងក្រោម) | MEF | ប្រកាសឲ្យប្រើថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ | IMF, WCO |
| ៣. | អនុក្រឹត្យលេខ ២០៩ ស្តីពីទំនិញហាមឃាត់ និងរឹតត្បិត | MEF | អនុម័តឆ្នាំ២០០៧ | IMF, WCO |
| ៤. | ប្រកាសលេខ ៣៨៧ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងលើការកំណត់តម្លៃពន្ធគយ | MEF | អនុម័តថ្ងៃទី២២ ខែឧសភាឆ្នាំ២០០៨ | IMF, WCO |
| ៥. | ច្បាប់ធ្វើវិសោធនកម្មលើច្បាប់ស្តីពីការគ្រប់គ្រងឱសថ | MoH ក្រសួងសុខាភិបាល | ប្រកាសឲ្យប្រើថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ | n.a. |
| ៦. | ប្រកាសស្តីពីការនាំចូលឱសថ | MoH | អនុម័តថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៨ | n.a. |
| ៧. | ច្បាប់ស្តីពីដំណោះស្រាយពាណិជ្ជកម្ម (ប្រឆាំងនឹងការចាក់កាកសំណល់, ការការពារ និងវិធានការទប់ទល់) | MoC ក្រសួងពាណិជ្ជកម្ម | ព្រាងជាភាសាអង់គ្លេសស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៅថ្នាក់ក្រសួងពាណិជ្ជកម្ម។ ការបកប្រែជាភាសាខ្មែរកំពុងដំណើរការ។ | MULTRAP, USAID |
| ៨. | ច្បាប់ស្តីពីវិធានដើម | MEF, MoC | សេចក្តីព្រាងស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៅថ្នាក់ក្រសួង | UNCTAD ដើម្បីផ្តល់ |
| ៩. | អនុក្រឹត្យលេខ១៤៨ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស | MEF, MoC, MIME, CDC | អនុម័តថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥ | n.a. |
| ១០. | ច្បាប់ស្តីពីបទដ្ឋានរបស់កម្ពុជា | MIME ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រកាសឲ្យប្រើថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ | UNIDO |
| ១១. | អនុក្រឹត្យលេខ ៦២ ធ្វើការបង្កើតវិទ្យាស្ថានបទដ្ឋានជាតិកម្ពុជា | MIME | អនុម័តថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨ | n.a. |
| ១២. | អនុក្រឹត្យលេខ ១៥ ស្តីពីការដាក់រោងចក្រឲ្យដាច់ពីគេ | MAFF ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | អនុម័តក្នុងឆ្នាំ២០០៣ | NZAid, AusAid, ADB |
| ១៣. | អនុក្រឹត្យលេខ ១៦ ស្តីពីការគ្រប់គ្រងអនាម័យសត្វ និងផលិតផលសាច់សត្វ | MAFF | អនុម័តក្នុងឆ្នាំ២០០៣ | NZAid, AusAid, ADB |
| ១៤. | ប្រកាសរបស់អន្តរក្រសួងស្តីពីការអនុវត្ត និងការរៀបចំស្ថាប័នសុវត្ថិភាពស្បៀងដោយពឹងផ្អែកលើវិធាន "ផលិតផលពីកសិដ្ឋានទៅលីតុ" | MEF, MoC, MIME, MAFF, MoH, MoT | អនុម័តថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ | ADB |
| ១៥. | ប្រកាសលេខ ៥៨៩ ដែលលុបបំបាត់ QRs ស្តីពីការនាំចូលថ្នាំសម្លាប់សត្វល្អិត និងជី | MAFF | អនុម័តក្នុងឆ្នាំ២០០៣ | n.a. |

## សិទ្ធិកម្មសិទ្ធិបញ្ញា

| ផ្នែក | ច្បាប់/អនុក្រឹត្យ/បទបញ្ញត្តិអន្តរក្រសួង (ប្រកាស) | ភាគីទទួលខុសត្រូវ | ស្ថានភាពមកត្រឹមខែកុម្ភៈ ឆ្នាំ២០១១ | TRTA ដែលបានទទួល (អតីតកាល ឬ បច្ចុប្បន្ន) |
|---|---|---|---|---|
| ១៦. | ច្បាប់ពាក់ព័ន្ធនឹងម៉ាកសញ្ញា, ពាណិជ្ជសញ្ញា, និងបញ្ញត្តិនៃការប្រកួតប្រជែងមិនស្មើភាព | MoC | ប្រកាសឲ្យប្រើថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០២ | WIPO |
| ១៧. | អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកសញ្ញា | MoC | អនុម័តថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៦ | WIPO |
| ១៨. | ប្រកាសស្តីពីភ្នាក់ងារចេញពាណិជ្ជនាម | MoC | អនុម័តឆ្នាំ ២០១១ | WIPO |
| ១៩. | ច្បាប់ស្តីពីការបង្ហាញទីតាំងភូមិសាស្រ្ត | MoC | ប្រកាសដែលគ្រប់គ្រង GIs នៅពេលបច្ចុប្បន្ន។ សេចក្តីព្រាងច្បាប់កំពុងដំណើរការ | AFD, ECAP II |
| ២០. | ច្បាប់ស្តីពីកិច្ចការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់ | MoC | សេចក្តីព្រាងកំពុងស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៅថ្នាក់ក្រសួង | ប្រទេសកាណាដា (APEC-BIP) |
| ២១. | ច្បាប់ស្តីពីការតចរន្តរួម និងការរៀបចំបណ្តាញ | MIME | សេចក្តីព្រាងកំពុងដំណើរការ | |
| ២២. | ច្បាប់ស្តីពីប័ណ្ណប៉ាតង់ | MIME | ប្រកាសឲ្យប្រើថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ | WIPO |
| ២៣. | ប្រកាសស្តីពីការអនុវត្តច្បាប់ស្តីពីប័ណ្ណប៉ាតង់ ដែលទាក់ទងនឹងការចុះបញ្ជីទ្រង់ទ្រាយឧស្សាហកម្ម | MIME | អនុម័តថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ | WIPO |
| ២៤. | ប្រកាសស្តីពីការអនុវត្តច្បាប់ស្តីពីប័ណ្ណប៉ាតង់ ដែលទាក់ទងនឹងការចុះបញ្ជីប័ណ្ណប៉ាតង់ និងគំរូសេវាកម្ម | MIME | អនុម័តថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ | WIPO |
| ២៥. | ច្បាប់ស្តីពីការគ្រប់គ្រងគ្រាប់ពូជ និងសិទ្ធិបង្កាត់កូនឈើ | MIME, MIME | ប្រកាសឲ្យប្រើថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០៨ | n.a. |
| ២៦. | ចូលរួមអនុសញ្ញាអន្តរជាតិស្តីពីការការពារប្រភេទរុក្ខជាតិថ្មីៗ | NCIPR | មិនទាន់ដំណើរការនៅឡើយ | |
| ២៧. | អនុក្រឹត្យស្តីពីការវាស់វែងព្រំដែនកម្មសិទ្ធិបញ្ញា | MEF+MoC | ពង្រាងកំពុងដំណើរការ | |
| ២៨. | ច្បាប់ស្តីពីសិទ្ធិថតចម្លង និងសិទ្ធិដែលពាក់ព័ន្ធ | MoCFA | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៣ | WIPO |
| ២៩. | ប្រកាសស្តីពីការគ្រប់គ្រង និងការបង្ក្រាបសកម្មភាពដែលរំលោភបំពានលើសិទ្ធិថតចម្លង | MoCFA | អនុម័តថ្ងៃទី១៨ ខែមីនាឆ្នាំ២០០៣ | គ្មាន TA |
| ៣០. | ប្រកាសស្តីពីនីតិវិធីផ្តល់សិទ្ធិធ្វើការគ្រប់គ្រងសិទ្ធិអក្សរសាស្រ្ត សិល្បៈ និងតន្ត្រីដោយគ្មានទាយាទ | MoCFA | អនុម័តថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៧ | គ្មាន TA |
| ៣១. | ចូលរួមក្នុងអនុសញ្ញាទីក្រុងប៊ឺន | MoC | មិនទាន់ដំណើរការនៅឡើយ | |
| ៣២. | អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា (NCIPR) | MoC, NCIPR | អនុម័តក្នុងឆ្នាំ ២០០៨ | គ្មាន TA |
| ៣៣. | អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការជាតិទទួលបន្ទុកអនុវត្តកម្មសិទ្ធិបញ្ញាស្ថិតក្រោម NCIPR | MoC, NCIPR | បានព្រាងរួចរាល់សម្រាប់ដាក់ជូនទៅ COM | គ្មាន TA |
| ៣៤. | អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការជាតិទទួលបន្ទុកការអប់រំអំពីកម្មសិទ្ធិបញ្ញា និងការយល់ដឹងជាសាធារណស្ថិតក្រោម NCIPR | MoC | បានព្រាងរួចរាល់សម្រាប់ដាក់ជូនទៅCOM | គ្មាន TA |

## បរិយាកាសធុរកិច្ច

| ផ្នែក | ច្បាប់/អនុក្រឹត្យ/បទបញ្ជាអន្តរក្រសួង (ប្រកាស) | ភាគីទទួលខុសត្រូវ | ស្ថានភាពមកត្រឹមខែកុម្ភៈ ឆ្នាំ២០១១ | TRTA ដែលបានទទួល (អតីតកាល ឬ បច្ចុប្បន្ន) |
|---|---|---|---|---|
| ៣៥. | ច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម | MoC | សេចក្តីព្រាងកំពុងដំណើរការ | CIDA, MULTRAP, JICA |
| ៣៦. | ច្បាប់ស្តីពីស្ថាប័នយុត្តិធម៌ (អនុញ្ញាតឲ្យបង្កើតតុលាការពិសេស) | MoJ | ស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយក្រុមប្រឹក្សាគណៈវិនិច្ឆ័យ | n.a. |
| ៣៧. | ច្បាប់ស្តីពីអសាធភាព | MoC | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៨ | ADB, IMF |
| ៣៨. | ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម | MoC | ស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយគណៈកម្មាធិការអន្តរក្រសួង | ADB |
| ៣៩. | ច្បាប់ស្តីពីទីភ្នាក់ងារពាណិជ្ជកម្ម | MoC | សេចក្តីព្រាងកំពុងដំណើរការ | n.a. |
| ៤០. | ច្បាប់ស្តីពីមជ្ឈិត្តការផ្នែកពាណិជ្ជកម្ម | MoC | ប្រកាសឲ្យប្រើនៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០០៦ | ADB |
| ៤១. | អនុក្រឹត្យលេខ១២៤ ស្តីពីការបង្កើតមជ្ឈិត្តកម្មជាតិ | MoC | អនុម័តក្នុងឆ្នាំ ២០០៩ | ADB, IFC |
| ៤២. | ក្រមរដ្ឋប្បវេណី | MoJ | ប្រកាសឲ្យប្រើនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ | JICA |
| ៤៣. | ក្រមនីតិវិធីរដ្ឋប្បវេណី | MoJ | ប្រកាសឲ្យប្រើនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ | JICA |
| ៤៤. | ក្រមព្រហ្មទណ្ឌ | MoJ | ប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ | សហប្រតិបត្តិការប្រទេសបារាំង |
| ៤៥. | ក្រមនីតិវិធីព្រហ្មទណ្ឌ | MoJ | ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ | សហប្រតិបត្តិការប្រទេសបារាំង |
| ៤៦. | ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម | MoC | ប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ | ADB |
| ៤៧. | ច្បាប់ស្តីពីសញ្ញាប័ណ្ណរដ្ឋាភិបាល | MEF | ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ | ADB |
| ៤៨. | ច្បាប់ស្តីពីការធ្វើពាណិជ្ជកម្ម និងការចេញសញ្ញាប័ណ្ណក្រៅរដ្ឋាភិបាល | MEF | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៧ | ADB |
| ៤៩. | ច្បាប់ស្តីពីលិខិតូបករណ៍ចរចា និងការផ្ទេរប្រាក់ | NBC | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៥ | n.a. |
| ៥០. | ច្បាប់ស្តីពីការផ្ទេរប្រាក់ដោយសុវត្ថិភាព | MoC | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៧ | ADB |
| ៥១. | ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ (ច្បាប់ដើមស្តីពីការវិនិយោគត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ៥ ខែសីហា ឆ្នាំ១៩៩៤) | CDC | ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ | IFC |
| ៥២. | អនុក្រឹត្យលេខ ១១១ ស្តីពីការអនុវត្តច្បាប់ ការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីការវិនិយោគ (លុបបំបាត់រង្វាន់លើកទឹកចិត្តសម្រាប់ការងារនាំចេញ) | CDC | អនុម័តនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ | IFC |
| ៥៣. | អនុក្រឹត្យលេខ ១៤៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ CDC | CDC | អនុម័តនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៨ | n.a. |
| ៥៤. | ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច | MoC | សេចក្តីព្រាងជាភាសាអង់គ្លេសស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៅថ្នាក់ MoC | UNCTAD, TDSP |
| ៥៥. | ច្បាប់ស្តីពីការប្រកួតប្រជែង | MoC | សេចក្តីព្រាងជាភាសាអង់គ្លេសស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៅថ្នាក់ MoC | UNCTAD, ADB |
| ៥៦. | ច្បាប់ស្តីពីផលផល | MAFF | ប្រកាសឲ្យប្រើនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ | Danida |
| ៤៩. | ច្បាប់ស្តីពីលិខិតូបករណ៍ចរចា និងការផ្ទេរប្រាក់ | NBC | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៥ | n.a. |

## ផ្នែកសេវាកម្ម

| ផ្នែក | ច្បាប់/អនុក្រឹត្យ/បទបញ្ជាអន្តរក្រសួង (ប្រកាស) | ភាគីទទួលខុសត្រូវ | ស្ថានភាពមកត្រឹមខែកុម្ភៈ ឆ្នាំ២០១១ | TRTA ដែលបានទទួល (អតីតកាល ឬ បច្ចុប្បន្ន) |
|---|---|---|---|---|
| ៥៧. | ច្បាប់ទូរគមនាគមន៍ (ការបង្កើតស្ថាប័ននិយតកម្មឯករាជ្យ) | MPTC | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៥ | WB, ADB |
| ៥៨. | អនុក្រឹត្យដែលផ្តាច់ទូរគមនាគមន៍កម្ពុជាចេញពីក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ | MPTC | អនុម័តនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ | WB, ADB |
| ៥៩. | ច្បាប់ស្តីពីការធ្វើវិសោធនកម្មទៅលើច្បាប់ការងារ (សេចក្តីបង្គាប់របស់ GATS : អនុញ្ញាតឲ្យមានលិខិតអនុញ្ញាតការងាររយៈពេល ២ឆ្នាំ សម្រាប់ជនបរទេសដែលអាចបន្តជាថ្មីរយៈពេលរហូតដល់ ៥ ឆ្នាំ) | MLVT | n.a. | n.a. |
| ៦០. | អនុក្រឹត្យដែលធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៥ (សេចក្តីបង្គាប់របស់ GATS : អនុញ្ញាតឲ្យមានលិខិតអនុញ្ញាតឲ្យរស់នៅ និងទិដ្ឋាការរយៈពេល ២ឆ្នាំ សម្រាប់ជនបរទេស) | MoI | n.a. | n.a. |
| ៦១. | ការធ្វើវិសោធនកម្មទៅលើព្រះរាជក្រឹត្យ (សេចក្តីបង្គាប់របស់ GATS : អនុញ្ញាតឲ្យវិស្វករដែលបានទទួលអាជ្ញាប័ណ្ណជាជនបរទេសចុះហត្ថលេខាលើគម្រោងធំៗ) | MLMUPC | n.a. | MULTRAP |
| ៦២. | ច្បាប់ស្តីពីលក្ខណៈសម្បត្តិវិជ្ជាជីវៈរបស់ស្ថាបត្យករ | MLMUPC | n.a. | MULTRAP |
| ៦៣. | ច្បាប់ស្តីពីលក្ខណៈសម្បត្តិវិជ្ជាជីវៈរបស់វិស្វករ | MLMUPC | n.a. | MULTRAP |
| ៦៤. | ច្បាប់ស្តីពីលក្ខណៈសម្បត្តិវិជ្ជាជីវៈរបស់អ្នកសាងសង់អាជីព | MLMUPC | n.a. | WIPO |
| ៦៥. | ការធ្វើវិសោធនកម្មលើច្បាប់ស្តីពីគណៈមេធាវី (សេចក្តីបង្គាប់របស់ GATS) | Bar Association | n.a. | n.a. |
| ៦៦. | ច្បាប់ទេសចរណ៍ | MoT | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៩ | n.a. |
| ៦៧. | ប្រកាសស្តីពីបទដ្ឋានអប្បបរមានៅក្នុងសណ្ឋាគារ | MoT | អនុម័តក្នុងឆ្នាំ ២០០៩ | n.a. |
| ៦៨. | អនុក្រឹត្យស្តីពីការចាត់ចំណាត់ថ្នាក់សណ្ឋាគារ | MoT | អនុម័តនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៤ | n.a. |
| ៦៩. | ច្បាប់ស្តីពីការដឹកជញ្ជូនតាមសមុទ្រ | MPWT | សេចក្តីព្រាងកំពុងដំណើរការ | ប្រទេសប៊ែលហ្ស៊ិក |
| ៧០. | ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវគោក | MPWT | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៧ | |
| ៧១. | ច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិល | SSCA | ប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៨ | ICAO |
| ៧២. | ច្បាប់ស្តីពីការធានារ៉ាប់រង និងការធានារ៉ាប់រងឡើងវិញ ដែលបានប្តូរទៅជាអនុក្រឹត្យជំនួសឲ្យការបង្កើតច្បាប់នេះវិញ | MEF | សេចក្តីព្រាងកំពុងដំណើរការ | ADB |
| ៧៣. | ច្បាប់ស្តីពីភតិកសន្យាពាណិជ្ជកម្ម | NBC | n.a. | n.a. |

*ប្រភព: កម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជាដែលកើតចេញពីការចូលជាសមាជិករបស់ប្រទេសកម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) រៀបចំលើកដំបូងដោយក្រសួងពាណិជ្ជកម្ម (MoC) សម្រាប់ទីស្តីការគណៈរដ្ឋមន្ត្រី (COM) ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ហើយបានធ្វើបច្ចុប្បន្នកម្មដោយ ក្រសួងពាណិជ្ជកម្ម (MoC) នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៧។ កម្មវិធីការងារនេះត្រូវបានធ្វើបច្ចុប្បន្នកម្មដោយ ក្រសួងពាណិជ្ជកម្ម (MoC) ដូចមានក្នុងតារាង ក្នុងខែកុម្ភៈ ឆ្នាំ ២០១១។*

**សម្គាល់ :** បញ្ជីច្បាប់ និងអនុក្រឹត្យរបស់រដ្ឋាភិបាលដែលផ្អែកលើកម្មវិធីការងារឆ្នាំ២០០៤ គឺមានភាពទូលំទូលាយ។ មានតែប្រកាស (សំខាន់) ដែលបានជ្រើសរើសប៉ុណ្ណោះត្រូវបានចុះបញ្ជី។

## ពាក្យបំព្រួញកាត់ (តាមលំដាប់អក្សរ)

| | | | |
|---|---|---|---|
| BA : | គណៈមេធាវី | MoI: | ក្រសួងមហាផ្ទៃ |
| CDC: | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | MoJ: | ក្រសួងយុត្តិធម៌ |
| MAFF: | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | MoT: | ក្រសួងទេសចរណ៍ |
| MEF: | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | MPTC: | ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ |
| MIME: | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | MPWT: | ក្រសួងសាធារណការណ៍ និងដឹកជញ្ជូន |
| MLVT: | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | NBC: | ធនាគារជាតិនៃកម្ពុជា |
| MLMUPC: | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | NCIPR: | គណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិកម្មសិទ្ធិបញ្ញា |
| MoC: | ក្រសួងពាណិជ្ជកម្ម | SSCA: | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |
| MoH: | ក្រសួងសុខាភិបាល | | |

ក្រាហ្វិក ១:

ការចុះពាណិជ្ជសញ្ញាតាមឆ្នាំ (២០០០-២០០៩)




*ប្រភព : ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកម្មសិទ្ធិបញ្ញា*

**រូបភាព ១ :** ម៉ាកសម្គាល់ភូមិសាស្ត្រស្ករត្នោតខេត្តកំពង់ស្ពឺ




**PHOTO 2: Kampot Pepper Geographical Indication**



# កំណែទម្រង់កិច្ចសម្រួល
# ពាណិជ្ជកម្មនៅកម្ពុជា





# ការកែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មនៅកម្ពុជា

## សេចក្ដីសង្ខេប


កាលពីឆ្នាំ ២០០៤ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានធ្វើការប្រជុំក្រុមការងារអន្តរក្រសួងពិសេសមួយស្ដីពីការជួយសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគទុន (SITF) និងបានធ្វើការសម្រេចលើចំណុចសកម្មភាពទាំង ១២ចំណុច ដើម្បីអនុវត្តការងារកំណែទម្រង់ និងធ្វើឲ្យមានភាពជឿនលឿនលើហេដ្ឋារចនាសម្ព័ន្ធនៃកិច្ចសម្រួលពាណិជ្ជកម្មរបស់ខ្លួន។ ចាប់តាំងពីពេលនោះមក មានការវិវឌ្ឍឈានឡើងដ៏ចម្បងមួយតាមរយៈកំណែទម្រង់ច្បាប់ និងបទបញ្ញត្តិទូលំទូលាយ ដើម្បីធ្វើឲ្យវិស័យគយគោរពតាមកាតព្វកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក ការគណនាអំពីប្រតិបត្តិការរបស់ខ្លួន (ប្រើប្រាស់កម្មវិធី ASYCUDA) និងការណែនាំអំពីវិធានគ្រប់គ្រងហានិភ័យសម្រាប់ការត្រួតពិនិត្យរបស់គយ។ ការវិវឌ្ឍនេះសម្រេចបានជាអន្លើរៗដោយសារតែគយទទួលបាននូវជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) ។

ផ្ទុយមកវិញ ភាពជឿនលឿននាពេលបច្ចុប្បន្នក្នុងវិស័យគយ ការវិវឌ្ឍឈានឡើង និងការធ្វើទំនើបកម្មនៅក្នុងផ្នែកគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យ (SPS) មានសភាពយឺតយ៉ាវជាងមុន ប៉ុន្តែការប្រែប្រួលកំពុងតែមានដំណើរការទៅមុខ។ ការវិវឌ្ឍយ៉ាងច្រើនបន្ថែមទៀតនឹងត្រូវការនៅពេលអនាគតដើម្បីឲ្យប្រទេសកម្ពុជាអាចមានលទ្ធភាពអនុវត្តផែនការ ច្រកចេញចូលតែមួយ ដូចដែលមានចែងស្ថិតក្រោមក្របខ័ណ្ឌអាស៊ាន និងប្រាក់ត្រូវបង់ថេរដែលមានភាពចុះសម្រុងគ្នារបស់អង្គការពាណិជ្ជកម្មពិភពលោក។

ការវិវឌ្ឍរីកចម្រើនដែលសម្រេចបានដោយគយ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការសម្អាតកុងតេនីនៅតាមព្រំដែន ដោយកាត់បន្ថយចំនួនថ្ងៃដែលត្រូវការជាងពាក់កណ្ដាលបើធៀបនឹងឆ្នាំ ២០០៧ និង ២០១០។ ការវិវឌ្ឍរីកចម្រើនបន្ថែមទៀតនឹងអាចកំណត់បានជាផ្នែកៗផងដែរតាមរយៈសន្ទុះដែលការគ្រប់គ្រង អនាម័យ និងភូតគាមអនាម័យ (SPS) ពាក់ព័ន្ធនឹងពាណិជ្ជកម្មត្រូវបានដាក់ឲ្យអនុវត្តក្រោមវិធានគ្រប់គ្រងហានិភ័យ។


## ១ បញ្ហាដែលត្រូវបានដោះស្រាយ

កម្ពុជា គឺជាប្រទេសដំបូងគេដែលបានបំពេញយុទ្ធសាស្ត្រវិភាគសមាហរណកម្មពាណិជ្ជកម្ម (DTIS) កាលពីឆ្នាំ ២០០១ ស្ថិតក្រោមកម្មវិធីក្របខ័ណ្ឌសមាហរណកម្ម។ ការសិក្សានេះបានសម្គាល់ឃើញថា មានផ្នែកជាច្រើនដែលទាមទារឲ្យមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល និងពីវិស័យឯកជន ដើម្បីពន្លឿនការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសចូលទៅក្នុងពាណិជ្ជកម្មសកលលោក។ ក្នុងនោះមានផ្នែកមួយគឺការសម្របសម្រួលពាណិជ្ជកម្ម។ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះការយកចិត្តទុកដាក់ជាសំខាន់របស់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍគឺទៅលើការបំពេញឲ្យចប់សព្វគ្រប់នូវការចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (ចូលជាធរមាននៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០០៤[៨] ដោយបានអនុវត្តជំនួយទ្វេភាគីដែលបានជ្រើសរើសនៅក្នុងវិស័យផលិតផលជាច្រើន (ឧទាហរណ៍ដូចជា វិស័យកាត់ដេរ អង្ករ កៅស៊ូ) និងជាមួយនឹងការដាក់ចេញនូវគម្រោងកិច្ចសម្រួលសម្រួលពាណិជ្ជកម្ម និងការប្រកួតប្រជែង (TFCP) របស់ធនាគារពិភពលោកក្នុងឆ្នាំ ២០០៤។ ការផ្ដោតការយកចិត្តទុកដាក់ខ្លាំងជាងនេះ គឺទៅលើការផ្ដល់នូវកិច្ចសម្រួលពាណិជ្ជកម្ម។

កាលពីខែមិថុនា ឆ្នាំ ២០០៤ ក្រុមការងារពិសេសរបស់អន្តរក្រសួងស្ដីពីកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ (SITF) ត្រូវបានបង្កើតឡើងដោយនាយករដ្ឋមន្ត្រី។ ក្រុមការងារពិសេសរបស់អន្តរក្រសួងស្ដីពីកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ (SITF) រួមមាន អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងពាណិជ្ជកម្ម (MoC) ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (MLVT) ក្រសួងមហាផ្ទៃ (MoI) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងអាជ្ញាធរកំពង់ផែក្រុងព្រះសីហនុ ។

[៨]សូមមើល ជំពូក ១

កាលពីខែមិថុនា ឆ្នាំ ២០០៤ ក្រុមការងារពិសេសរបស់អន្តរក្រសួងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ (SITF) បានអនុម័តលើ *ផែនការសកម្មភាពទាំង ១២ ចំណុច* ដែលផ្តោតលើវិធានការមួយចំនួនដែលត្រូវអនុវត្តដើម្បីធ្វើឲ្យប្រសើរដល់កិច្ចសម្រួលពាណិជ្ជកម្មនៅកម្ពុជា។ សូមមើលតារាងលេខ ១ ។

## ២ គោលដៅដែលត្រូវបន្ត

គោលដៅរបស់រដ្ឋាភិបាលក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺបានផ្តោតលើការធ្វើឲ្យប្រសើរឡើងនូវការប្រកួតប្រជែងរបស់កម្ពុជាតាមរយៈការកាត់បន្ថយការចំណាយលើការធ្វើធុរកិច្ច ដែលពាក់ព័ន្ធជាមួយនឹងពាណិជ្ជកម្ម តាមរយៈការអនុវត្ត *ផែនការសកម្មភាពទាំង ១២ ចំណុច*។

## ៣ បញ្ហាប្រឈមដែលបានជួបប្រទះ និងកត្តានានាសម្រាប់ភាពជោគជ័យ

ដើម្បីអនុវត្ត *ផែនការសកម្មភាពទាំង ១២ ចំណុច* បានប្រកបដោយជោគជ័យ រដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាប្រឈមនិងកត្តាសំខាន់ៗជាច្រើនរួមមាន៖

១. អភិវឌ្ឍសមត្ថភាពនៅតាមស្ថាប័ននានាដែលទទួលខុសត្រូវចំពោះវិធាននានាការតាមព្រំដែន និងចំពោះការអនុវត្តសកម្មភាពផ្សេងៗដូចដែលបានកំណត់នៅក្នុងផែនការ។
២. សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលជុំវិញផែនការសកម្មភាពដែលពាក់ព័ន្ធជាមួយនឹងក្រសួង និងភ្នាក់ងារពាក់ព័ន្ធមួយចំនួនទៀត។
៣. ធានាឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងឡាយ
៤. ធានាឲ្យមានជំនួយបច្ចេកទេស (TA) ក្នុងករណីដែលចាំបាច់ និងក្នុងករណីដែលអាចធ្វើទៅបាន
៥. កាត់បន្ថយកត្តាខាងក្រៅដែលអាចប៉ះទង្គិចដោយអវិជ្ជមានដល់ភាពជឿនលឿន

### ៣.១. ការអភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីអនុវត្តផែនការសកម្មភាព

ក្រោយពីការចាប់ផ្តើមដ៏យឺតយ៉ាវ ការអនុវត្តសកម្មភាពមួយចំនួនដែលបានដាក់បញ្ចូលក្នុងផែនការ ត្រូវបានបន្តអនុវត្តយ៉ាងល្អសមស្របជាពិសេសបញ្ហាដែលពាក់ព័ន្ធដោយផ្ទាល់ជាងគេទៅលើ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE)។ ការសិក្សាមួយដែលបានធ្វើឡើងកាលពីខែកុម្ភៈ ឆ្នាំ២០០៥ បានកត់សម្គាល់ឃើញថា មានការតម្រូវឲ្យមានឯកសាររដ្ឋបាលជាង ៤៥ នៅតាមព្រំដែនសម្រាប់ការនាំចេញ។ ឯកសាររដ្ឋបាលតែមួយមុខ (SAD) ត្រូវបានណែនាំឲ្យប្រើជំនួសឯកសារដ៏ច្រើនទាំងនោះ និងឯកសារផ្សេងៗទៀតត្រូវបានបំបាត់ចោលស្របពេលជាមួយគ្នានោះ។ ឧទាហរណ៍ អាជ្ញាប័ណ្ណនាំចេញត្រូវបានលុបចោលដោយក្រសួងពាណិជ្ជកម្ម លើកលែងតែចំពោះទំនិញមានលក្ខណៈរសើបមួយចំនួនប៉ុណ្ណោះ។ វិញ្ញាបនប័ត្រកែច្នៃ ត្រូវបានលុបចោលដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ការចេញវិញ្ញាបនប័ត្របញ្ជាក់ពីប្រភពដើមទំនិញ ត្រូវបានប្តូរពីការចេញមុនពេលដឹកជញ្ជូនមកជាការចេញក្រោយពេលដឹកជញ្ជូនវិញ។ យុទ្ធសាស្រ្ត ត្រួតពិនិត្យលើហានិភ័យសម្រាប់កិច្ចសម្រួលពាណិជ្ជកម្មត្រូវបានអនុម័តកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្របតាមអនុក្រឹត្យលេខ ២១ របស់រដ្ឋាភិបាល ស្តីពីការគ្រប់គ្រងហានិភ័យនៅតាមព្រំដែន។ ការត្រួតពិនិត្យរួមគ្នារវាង គយ-កាំកុងត្រូល ត្រូវបានបង្កើតឡើងនៅតាមចំណុចត្រួតពិនិត្យតាមព្រំដែន [៩]។

ចំណុចសំខាន់ៗ...សម្រាប់ប្រព័ន្ធ ASYCUDA ត្រូវបានប្រើប្រាស់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ដោយចាប់ផ្តើមកាលពីខែឧសភាឆ្នាំ២០០៨និងបន្តដល់២០០៩ដែលមានការណែនាំជាដំបូងនូវប្រព័ន្ធនេះនៅក្នុងចំណុចត្រួតពិនិត្យគយធំៗចំនួន៥កន្លែងដែលស្មើនឹងជាងពាក់កណ្តាលនៃការត្រួតពិនិត្យទាំងអស់ រួមមាន ៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ផែស្ងួតចំនួន ៣ កន្លែងក្នុងទីក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ ឯកសាររដ្ឋបាលតែមួយមុខ (SAD) ជាអេឡិចត្រូនិចត្រូវបានសាកល្បងនៅក្នុងឆ្នាំ២០០៨ ហើយការគ្រប់គ្រងហានិភ័យត្រូវបានចាប់ផ្តើមនៅក្នុងចំណុចត្រួតពិនិត្យចំនួន ៥ កន្លែងស្របពេលជាមួយនឹងការចាប់ផ្តើមដំណើរការប្រព័ន្ធ ASYCUDA ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ (GDCE) គ្រោងនឹងចាប់ប្រើប្រព័ន្ធ ASYCUDA នៅក្នុងចំណុចផែកឆេគយដែលនៅសល់ចំនួន ១៧ កន្លែងទៀតក្នុងអំឡុងឆ្នាំ ២០១១ - ២០១២ ដើម្បីបំពេញទៅតាមគម្រោងកិច្ចសម្រួលពាណិជ្ជកម្ម និងការប្រកួតប្រជែង (TFCP) ដែលជាប្រភពមូលនិធិដ៏ធំសម្រាប់លទ្ធកម្មនៃប្រព័ន្ធនេះ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ក៏គ្រោងនឹងធ្វើការណែនាំឯកសារណែនាំប្រព័ន្ធ ASYCUDA ថ្មីផងដែរ ដែលមានបញ្ចូលកម្មវិធីមួយដែលអនុញ្ញាតឲ្យឈ្មួញកណ្តាល និងអ្នកដឹកជញ្ជូនទំនិញបញ្ចូលព័ត៌មានតាមអ៊ិនធឺណិតបានដោយផ្ទាល់។

[៩] កាំកុងត្រូល ឬ អគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញអាហ័រណ នីហ័រណ និងបង្រ្កាបការក្លែងបន្លំ។ ក្រសួងពាណិជ្ជកម្មត្រូវបានផ្តល់អាណត្តិឲ្យដើម្បីធានាគុណភាព និងសុវត្ថិភាពរបស់ផលិតផលនិងសេវាកម្ម និងដើម្បីការពារអ្នកប្រើប្រាស់តាមរយៈការធានាដល់ការគោរពតាមការតម្រូវរបស់ច្បាប់។ អគ្គនាយកដ្ឋាននេះត្រូវបានបង្កើតឡើងដោយអនុក្រឹត្យរដ្ឋាភិបាលលេខ ៥៩ ដែលត្រូវបានអនុម័តនៅកាលពីថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៨។ អនុក្រឹត្យនេះតំណាងឲ្យការដំឡើងឋានៈរបស់កាំកុងត្រូលដែលឡើងពីនាយកដ្ឋានមួយរបស់ក្រសួងពាណិជ្ជកម្ម។

នៅក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ការអនុវត្តផែនការសកម្មភាពទាំង ១២ ចំណុច ត្រូវបានសម្របទៅតាមការអនុវត្តផែនការទំនើបកម្មគយរយៈពេល ៥ ឆ្នាំ (ពីឆ្នាំ២០០៣-២០០៨ និងពី ២០០៨- ២០១២) ដែលត្រូវបានរៀបចំឡើងដោយមានជំនួយពីមូលនិធិរូបិយវត្ថុអន្តរជាតិ និងមានការអនុវត្តដោយមានការគាំទ្រពីដៃគូអភិវឌ្ឍមួយចំនួន។ ក្នុងចំណោមផ្នែកផ្សេងៗទៀត ផែនការ ៥ ឆ្នាំនេះបានជួយជ្រោមជ្រែងដល់កិច្ចការច្បាប់បទបញ្ញតិ និងស្ថាប័នដ៏ទូលំទូលាយដែលតម្រូវឲ្យអនុវត្តន៍ច្បាប់គយ (បានប្រកាសឲ្យប្រើនៅក្នុងខែកក្កដាឆ្នាំ២០០៧) និងនាំកម្ពុជាចូលទៅក្នុងរបត់នៃកាតព្វកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក។ សូមមើលតារាងលេខ២ ដែលមានបង្ហាញពីភាពរីកចម្រើនជឿនលឿនដែលសម្រេចបានដោយឈរលើមូលដ្ឋានច្បាប់ និងបទបញ្ញតិ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE)។

រហូតមកដល់បច្ចុប្បន្ននេះ ការរីកចម្រើនទទួលបានលើសពីការគ្រោងទុកនៅក្នុងក្រសួងពាណិជ្ជកម្ម ដែលជាស្ថាប័នសំខាន់មួយទៀតសម្រាប់ការងារត្រួតពិនិត្យទំនិញខូចគុណភាព និងខុសច្បាប់តាមព្រំដែន។ ក្រសួងពាណិជ្ជកម្មបានកាត់បន្ថយពេលវេលាតម្រូវការហិរញ្ញវត្ថុ និងថ្លៃចំណាយលើការចុះបញ្ជីពាណិជ្ជកម្មយ៉ាងច្រើន ជាពិសេសក្នុងឆ្នាំ២០០៧។ ទោះជាយ៉ាងណាក្តី ក្រសួងពាណិជ្ជកម្មទើបតែនឹងបានចាប់ផ្តើមក្នុងពេលកន្លងទៅថ្មីៗនេះប៉ុណ្ណោះ សម្រាប់ផែនការនៃបច្ចេកវិទ្យាព័ត៌មានមេ ICT សម្រាប់ការចេញលិខិតចុះបញ្ជីពាណិជ្ជកម និងវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ(Co)តាមបែបអេឡិចត្រូនិច។ ផែនការនេះមានបញ្ចូលការកសាងសមត្ថភាពុះ និងការងារបញ្ចូលក្នុងកុំព្យូទ័រនូវសកម្មភាពផ្សេងៗទៀតផងដែរ។ ផែនការនេះ គឺត្រូវអនុវត្តក្រោមមូលនិធិរបស់គម្រោងកិច្ចសម្រួលពាណិជ្ជកម្មនិងការប្រកួតប្រជែង (TFCP) និងកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP)។ បច្ចុប្បន្ននេះ Co ត្រូវបានចេញនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសជាការបន្ថែមក្រៅពីរាជធានីភ្នំពេញ ហើយកិច្ចពិភាក្សានានាកំពុងស្ថិតក្នុងដំណើរការដើម្បីរៀបចំចេញ Co នៅតាមបណ្តាទីរួមខេត្តសំខាន់ៗមួយចំនួនទៀត (ដូចជា ខេត្តបាត់ដំបង ខេត្តសៀមរាប) ដើម្បីទ្រទ្រង់ដល់ការនាំអង្ករចេញ។

ការណែនាំអំពីការគ្រប់គ្រងហានីភ័យនៅក្នុងកាំកុងត្រូល ដែលជាភ្នាក់ងារចំណុះក្រសួងពាណិជ្ជកម្ម និងទទួលបន្ទុករាល់សកម្មភាពតាមដានទីផ្សារឆ្លងដែនដើម្បីសុវត្ថិភាពចំណីអាហារ គឺស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។ ស្របតាមប្រកាសលេខ ១៥៥ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១០ អង្គភាពគ្រប់គ្រងហានិភ័យ (RUM) ត្រូវបានបង្កើតឡើងនៅក្នុងកាំកុងត្រូល។ លើសពីនេះទៀតការបញ្ជាក់ច្បាស់លាស់អំពីតួនាទីចំពោះសុវត្ថិភាពចំណីអាហារក្នុងចំណោមភ្នាក់ងារផ្សេងៗទៀតរបស់រដ្ឋ ស្របតាមបទបញ្ញត្តិរបស់អន្តរក្រសួងស្តីពី "ការអនុវត្ត និងការរៀបចំសម្របសម្រួលស្ថានប័នដើម្បីសុវត្ថិភាពម្ហូបអាហារផ្អែកលើវិធាន" ចាប់ពីកសិដ្ឋានផលិតដល់តុបរិភោគ "អនុម័តក្នុងខែតុលា ឆ្នាំ២០១០ នឹងជួយពន្លឿនដល់ដំណើរការកំណែទម្រង់នៅក្នុងកាំកុងត្រូល។ កាំកុងត្រូលបានទទួលជំនួយពីធនាគារអភិវឌ្ឍអាស៊ីដើម្បីធ្វើការបង្កើតផែនការគ្រប់គ្រងហានីភ័យតាមយុទ្ធសាស្រ្ត និងសម្រាប់ការបង្កើតដំបូងនូវអង្គភាពគ្រប់គ្រងហានីភ័យ។ គម្រោងអភិវឌ្ឍសមត្ថភាពតាមដានសម្រាប់អង្គភាពគ្រប់គ្រងហានីភ័យរបស់កាំកុងត្រូលត្រូវបានបង្ហាញ និងអនុម័តសម្រាប់ផ្តល់មូលនិធិពីកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP)[១០] ។

ការងារណែនាំអំពីច្រកចេញចូលតែមួយ ដែលបានដាក់បញ្ចូលទៅ *ក្នុងផែនការសកម្មភាពទាំង ១២ ចំណុច* ត្រូវបានរៀបចំកម្មវិធីការងារសារជាថ្មីចេញពីផែនការដើម ដើម្បីឲ្យស៊ីគ្នាជាមួយនឹងកម្មវិធីការងារដែលបានអនុម័តដោយ អាស៊ាន។ ការវិវឌ្ឍលើការប្រឈមនេះ ក៏ដូចជាការណែនាំអំពីប្រាក់ត្រូវបង់ថេរសម្រាប់សេវាកម្មស្របតាមអង្គការពាណិជ្ជកម្មពិភពលោកហាក់បីដូចជាមានការកំណត់ជាអន្លើៗតាមអត្រាដែលកាំកុងត្រូវនឹងអាចកែទម្រង់ ធ្វើទំនើបកម្ម និងអនុវត្តការគ្រប់គ្រងហានីភ័យ និងកំណត់យ៉ាងច្បាស់លាស់អំពីថ្លៃចំណាយពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការអនុញ្ញាត។

## ៣.២. ការសម្របសម្រួលរបស់រដ្ឋាភិបាល

លើកលែងតែចំពោះការត្រួតពិនិត្យជំហានដំបូងលើឯកសារចាំបាច់ ដែលនាំទៅដល់ការណែនាំអំពី ឯកសាររដ្ឋបាលតែមួយមុខ (SAD) និងការរៀបចំការត្រួតពិនិត្យរួមគ្នារវាងគយ-កាំកុងត្រូលតាមព្រំដែន ក្រៅពីនេះការសម្របសម្រួលរបស់រដ្ឋាភិបាលនៅក្នុងផ្នែកកំណែទម្រង់នេះគឺនៅមានកម្រិតនៅឡើយ។ កិច្ចប្រជុំរបស់ក្រុមការងារពិសេសអន្តរក្រសួងទទួលបន្ទុកសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ (SITF) មិនមានភាពមមាញឹកនោះទេ។ ការណែនាំអំពីការគ្រប់គ្រងហានិភ័យនៅក្នុង កាំកុងត្រូល និងការចាប់ផ្តើមការងារច្រកចេញចូលតែមួយទំនងជាត្រូវធ្វើការសម្របសម្រួលឡើងវិញរវាងគយ និងកាំកុងត្រូល។

## ៣.៣. ការធានាឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងឡាយ

ការចូលរួមមតិយោបល់ និងព័ត៌មានត្រឡប់ពីវិស័យឯកជនកើតឡើងភាគច្រើនតាមរយៈក្រុមការងារផ្នែករៀបចំការនាំចេញ និងការសម្របសម្រួលពាណិជ្ជកម្មដែលមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាប្រធាន ក្រោមវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) និងក្នុងពេលថ្មីៗនេះតាមរយៈ"បន្ទប់" ដែលត្រូវបានបង្កើតឡើងដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ដើម្បីពិនិត្យឡើងវិញលើបញ្ហាតាមព្រំដែនរវាងមន្ត្រីគយ និងក្រុមឈ្មួញកណ្តាល អ្នកដឹកជញ្ជូនទំនិញ និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធក្នុងកិច្ចការអាហ័រណ នីហ័រណេ។

[១០] TDSP, ឬ កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្មត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់គោលដៅមួយចំនួននៃ Trade SWAp របស់កម្ពុជា និងត្រូវបានអនុវត្តដោយក្រសួងពានិជ្ជកម្ម។ កម្មវិធីនេះទទួលបានហិរញ្ញប្បទានពីមូលនិធិក្រោមអាណត្តិព្យា បាលភាពរបស់ម្ចាស់ជំនួយចម្រុះ (MDTF) ដឹកនាំដោយធនាគារពិភពលោក និងទទួលមូលនិធិពីសហគមន៍អឺរ៉ុប Danida និង UNIDO។

## ៣.៤. ជំនួយសម្រាប់ពាណិជ្ជកម្ម

អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) បានទទួលការគាំទ្រផ្នែកជំនួយសម្រាប់ពាណិជ្ជកម្មយ៉ាងច្រើនចាប់តាំងពីអំឡុងដើមឆ្នាំ ២០០០ រួមមានពី មូលនិធិរូបិយវត្ថុអន្តរជាតិ ផ្នែកអគ្គបទ និងបញ្ញត្តិច្បាប់, AusAid, EU, JICA, NZAid ក្នុងផ្នែកការគ្រប់គ្រងហានិភ័យ (បង្កើតប្រព័ន្ធ និងនីតិវិធី និងសិក្សាពីរបៀបប្រើប្រាស់វា), TFCE របស់ធនាគារពិភពលោកក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ប្រព័ន្ធ ASYCUDA ។ ជារួម អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) បានធ្វើការងារប្រកបដោយប្រសិទ្ធិភាពគួរឲ្យកត់សម្គាល់មួយក្នុងការសម្របសម្រួលជំនួយបែបនេះតាមរយៈការប្រើប្រាស់ ផែនការសកម្មភាពទាំង ១២ចំណុច និងផែនការធ្វើទំនើបកម្មរយៈពេល ៥ឆ្នាំ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ផ្ទាល់ដើម្បីធ្វើការសម្របសម្រួល។

ចំពោះផ្នែកផ្សេង ជំនួយសម្រាប់ពាណិជ្ជកម្មមានកម្រិតតិចតួចបំផុត ដោយសារមានការលំបាកតាមផ្នែកខ្លះនៅក្នុងជួររដ្ឋាភិបាលក្នុងការរៀបចំចាត់ចែងតួនាទី និងការទទួលខុសត្រូវនានានៅក្នុងផ្នែកសំខាន់ៗនៃការជំរុញឲ្យអនុវត្តវិធានការ អនាម័យ និងភូតគាមអនាម័យ (SPS) និងឧបសគ្គផ្នែកបច្ចេកទេសចំពោះពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងការនាំចេញ និងការនាំចូល។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (UNIDO) បានផ្តល់ជំនួយឧបត្ថម្ភគាំទ្រដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលលើផ្នែកបច្ចេកទេសពាណិជ្ជកម្ម។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានចាប់ផ្តើមផ្តល់ជំនួយថ្មីៗទៅឲ្យកាំកុងត្រូលនៅក្នុងឆ្នាំ ២០០៩ នេះ។ កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម(TDSP) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងតែផ្តោតការយកចិត្តទុកដាក់លើការនាំជំនួយឧបត្ថម្ភថ្មីៗបន្ថែមទៀតមកឲ្យក្រសួងពាណិជ្ជកម្មដើម្បីធ្វើទំនើបកម្មជាពិសេសលើប្រតិបត្តិការ និងនីតិវិធីរបស់កាំកុងត្រូល។ ដូចបានបញ្ជាក់ពីខាងដើម សំណើពីអង្គភាពគ្រប់គ្រងហានីភ័យរបស់កាំកុងត្រូលត្រូវបានសម្រេចផ្តល់មូលនិធិពីសំណាក់កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម(TDSP)។ ជាមួយគ្នានេះដែរ ដូចដែលបានលើកឡើងពីខាងដើម ក្រសួងពាណិជ្ជកម្មកំពុងធ្វើការងារលើផែនការព័ត៌មានវិទ្យា ដើម្បីជួយក្នុងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រដើម្បីចេញCo និងឯកសារផ្សេងៗទៀតដែលត្រូវបានផ្តល់មូលនិធិដោយគម្រោងសម្របសម្រួលពាណិជ្ជកម្ម និងការប្រកួតប្រជែង (TFCP) និងកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) ។

ចំណែកឯផ្នែកខាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តវិញ គឺបាន និងកំពុងបន្តទទួលបានការគាំទ្រយ៉ាងច្រើនពីសំណាក់ដៃគូអភិវឌ្ឍនានាក្នុងការងារពង្រីកហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យពាណិជ្ជកម្ម។ ប្រទេសជប៉ុន កំពុងជួយធ្វើឲ្យប្រសើរឡើងចំពោះសំណង់មួយចំនួននៅក្នុងកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ ប្រទេសចិនកំពុងផ្តល់ហិរញ្ញប្បទានដល់ការពង្រីកកំពង់ផែស្វយ័តក្រុងភ្នំពេញ(ផែទន្លេ)។ ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាម្ចាស់កម្ចីដ៏ធំសម្រាប់ការជួសជុលកែលម្អផ្លូវសំខាន់ៗនៅក្នុងតំបន់ទន្លេមេគង្គដ៏ធំធេង ហើយក៏ជាម្ចាស់ជំនួយដ៏ធំមួយផងដែរនៅពីក្រោយការស្តារឡើងវិញនូវផ្លូវរថភ្លើង(ជាមួយនឹងកំណាត់ផ្លូវដែលត្រូវបានធ្វើការស្តារឡើងវិញលើកដំបូងចន្លោះពីទីក្រុងភ្នំពេញទៅកាន់ក្រុងព្រះសីហនុដែលទើបនឹងបានបើក)។ ប្រទេសបារាំង និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានធ្វើការវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន។

## ៣.៤. ការកាត់បន្ថយកត្តាខាងក្រៅ

មិនមានកត្តាខាងក្រៅគួរឲ្យកត់សម្គាល់ណាមួយហួសពីការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលធ្វើឲ្យប៉ះពាល់ដល់ផ្នែកកំណែទម្រង់ និងការកសាងសមត្ថភាពនេះឡើយ។ ជាក់ស្តែង វាមិនមានកង្វះខាតជំនួយបច្ចេកទេស ឬ កង្វះខាតធនធានពីសំណាក់ដៃគូអភិវឌ្ឍក្នុងការផ្តល់ជូនជំនួយបច្ចេកទេសបន្ថែមនៅក្នុងវិស័យដ៏ធំទូលាយនេះឡើយ។

វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឆ្នាំ ២០០៨ -២៥០៩ មិនបានបង្កផលប៉ះពាល់ដល់ការគាំទ្រផ្នែកជំនួយសម្រាប់ពាណិជ្ជកម្មដែលកំពុងតែបន្ត ឬ ដែលបានសន្យាផ្តល់សម្រាប់ការសម្របសម្រួលពាណិជ្ជកម្មនោះឡើយ។

# ៤ លទ្ធផលដែលសម្រេចបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន

ការដាក់ឲ្យអនុវត្តឯកសាររដ្ឋបាលតែមួយមុខ(SAD)និងការគ្រប់គ្រងហានិភ័យនៅតាមចំណុចត្រួតពិនិត្យរបស់គយដែលប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ ASYCUDA មានឥទ្ធិពលយ៉ាងខ្លាំងទៅលើកុងតេន័រជាច្រើន ដែលកំពុងស្ថិតក្រោមការត្រួតពិនិត្យយ៉ាងពេញលេញ។ សូមមើលតារាងលេខ ៣។ ចំនួនមធ្យម ២០% នៃកុងតេន័រនាំទំនិញចូល និង ១៣% នៃកុងតេន័រនាំទំនិញចេញត្រូវបានស្ថិតក្រោមការត្រួតពិនិត្យយ៉ាងពេញលេញ (ច្រកផ្លូវ "ក្រហម") ។ ចំនួនខ្ពស់ជាងនេះបន្តិចនៅក្នុងទីក្រុងភ្នំពេញលេខ ១៥ (PNHH15) បានឆ្លុះបញ្ចាំងជាប្រក្រតីអំពីមូលដ្ឋានដែលថានេះគឺជាការត្រួតពិនិត្យចុងក្រោយគេបង្អស់ដែលត្រូវបានធ្វើឡើង។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) បានគូសបញ្ជាក់ថា កាលពីដើមឆ្នាំ ២០១១ នេះ ចំនួន ៩០% នៃការប្រកាសនាំចូលត្រូវបានធ្វើរួចរាល់ ហើយទំនិញត្រូវបានបញ្ចេញក្នុងអំឡុងពេល ២៤ ម៉ោងក្រោយពីការចេញប្រកាស ហើយប្រព័ន្ធ ASYCUDA ត្រូវបានប្រើប្រាស់។

យោងតាមរបាយណ៍ការធ្វើអាជីវកម្មក្នុងឆ្នាំ២០១១របស់ធនាគារពិភពលោក និង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) រយៈពេលនាំចេញត្រូវបានកាត់បន្ថយពីរយៈពេលមធ្យម ៣៧ថ្ងៃ កាលពីឆ្នាំ ២០០៧ មកនៅត្រឹមតែ ២២ថ្ងៃ ក្នុងឆ្នាំ២០១០ និងរយៈពេលនាំចូលពីរយៈពេលមធ្យម ៤៥ថ្ងៃកាលពីឆ្នាំ២០០៧ មកនៅត្រឹមតែ២៦ថ្ងៃនៅក្នុងឆ្នាំ២០១០[១១]។ ពាក់ព័ន្ធការចាត់ចំណាត់ថ្នាក់ប្រទេសទាំងអស់សម្រាប់ "ពាណិជ្ជកម្មឆ្លងដែន" កម្ពុជាមានភាពល្អប្រសើរជាងមុនដែលឡើងពីលំដាប់ទី ១២៦ មកនៅ ១១៨ នៅចន្លោះពីឆ្នាំ ២០០៩ - ២០១០[១២]។ យោងតាមរបាយណ៍ការធ្វើអាជីវកម្មក្នុងឆ្នាំ ២០១១ ដដែល កម្ពុជានៅតែត្រូវការឯកសារបន្ថែមសម្រាប់ការនាំចូល និងនាំចេញច្រើនជាងបណ្តាប្រទេសជិតខាងខ្លួនទាំងអស់នៅក្នុងអាស៊ាន (ឯកសារប្រហែល ១០មុខ) ។

## ៥ បទពិសោធន៍ដែលទទួលបាន

រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការកែទម្រង់ផ្នែកសំខាន់ៗមួយចំនួនទាក់ទងនឹងការសម្របសម្រួលពាណិជ្ជកម្ម ដោយសារតែខ្លួនមានឆន្ទៈក្នុងការកែទម្រង់ និងមានការដឹកនាំរឹងមាំទៅលើផ្នែកដែលភ្នាក់ងារបានទទួលរងផលប៉ះពាល់។ ការរីកចម្រើននេះបានក្លាយទៅជាករណីមួយដែលជាពិសេសនៅក្នុងស្វ័យប្រវត្តិកម្មគយ និងការអនុវត្តវិធានគ្រប់គ្រងហានិភ័យដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) ។

វានៅមានភាពជឿនលឿនតិចតួចនៅឡើយនៅក្នុងផ្នែកត្រួតពិនិត្យឧបសគ្គផ្នែកបច្ចេកទេសចំពោះពាណិជ្ជកម្ម និងអនាម័យ និងភូតគាមអនាម័យ (SPS) ពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ ចំណុចនេះកំពុងតែមានការប្រែប្រួល ហើយមានការចាត់វិធានការនានាដើម្បីកែទម្រង់ និងធ្វើទំនើបកម្មក្នុងផ្នែកសំខាន់ៗនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចតាមព្រំដែនដែនទៅលើអនាម័យ និងភូតគាមអនាម័យ (SPS) ពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។

នៅមិនទាន់មានការខ្វះខាតធនធានផ្នែកជំនួយបច្ចេកទេសម្រាប់គាំទ្រឲ្យមានការធ្វើកំណែទម្រង់ និងការវិនិយោគនៅក្នុងការសម្របសម្រួលពាណិជ្ជកម្មនៅឡើយទេ។ ការសម្របសម្រួលពាណិជ្ជកម្មអាចជាផ្នែកមួយនៅក្នុងការអភិវឌ្ឍពាណិជ្ជកម្ម ដែលទទួលបានជំនួយដែលមានការសម្របសម្រួលច្រើនបំផុត និងល្អបំផុតពីដៃគូអភិវឌ្ឍជាច្រើនសូម្បីតែនៅមុនការដាក់ចេញនូវអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) របស់កម្ពុជាកាលពីដើមឆ្នាំ ២០០៨។

**តារាងលេខ ១ ៖** ស្ថានភាពក្នុងឆ្នាំ ២០១១ នៃផែនការសកម្មភាពទាំង ១២ចំណុច ដែលបានអនុម័តដោយក្រុមការងារអន្តរក្រសួងពិសេសស្តីពីការសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ (SITF) នៅក្នុងខែមិថុនា ឆ្នាំ២០០៤

| # | សកម្មភាពដែលបានឯកភាព ខែមិថុនា ឆ្នាំ២០០៤ | សកម្មភាពដែលបានស្នើ ខែមិថុនា ឆ្នាំ២០០៤ | សកម្មភាពដែលបានអនុវត្ត និងស្ថានភាព ខែមិថុនា ឆ្នាំ២០០៤ |
|---|---|---|---|
| ១. | បង្កើតក្រុមការងារសម្របសម្រួលពាណិជ្ជកម្មឆ្លងភ្នាក់ងារ/ក្រុមការងារកំណែទម្រង់បរិយាកាសវិនិយោគ។ | ១. ក្រុមការងារត្រូវបានបង្កើត<br>២. ត្រូវការការងារបន្ថែមលើការធ្វើឲ្យមានក្រិតក្រមក្នុងការរៀបចំការងារ ពិធីការទំនាក់ទំនង និងល័ក្ខខ័ណ្ឌការងារលម្អិត។ | ១. ក្រុមការងាររបស់ SITF ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៤ (រួមមាន GDCE MEF MoC, MAFF, MLSW, MoI, CDC, កំពង់ផែស្វ័យត្តក្រុងព្រះសីហនុ )។<br>២. កិច្ចប្រជុំធ្វើឡើងមិនបានញឹកញាប់។ |
| ២. | បង្កើតប្រព័ន្ធវាស់វែងការអនុវត្តការងារប្រកបដោយតម្លាភាពរួមទាំងការត្រួតពិនិត្យតាមដានវិស័យឯកជនផងដែរ។ | ១. ចាប់ផ្តើមធ្វើការពិភាក្សាជាមួយនឹងអង្គការវិស័យឯកជនដែលពាក់ព័ន្ធ<br>២. បង្កើតសូចនាករ និងវិធីសាស្ត្រក្នុងការវាស់វែងការអនុវត្តការងារ<br>៣.ធនាគារពិភពលោកផ្តល់មូលនិធិដើម្បីបង្កើតវិធីសាស្ត្រកាត់បន្ថយពេលវេលាសម្រាប់ប្រមូលទិន្នន័យតាមមូលដ្ឋាន និងត្រួតពិនិត្យតាមដានតាមពេលកំណត់។ | ១. បន្ទប់មួយត្រូវបានរៀបចំឡើងនៅក្នុងផ្នែកគយសម្រាប់ការប្រជុំជាទៀងទាត់ជាមួយនឹងវិស័យឯកជនដើម្បីពិនិត្យ/ពិភាក្សាអំពីបញ្ហាដែលកំពុងតែកើតមាននិងបច្ចុប្បន្នភាពនានា។<br>២ និង ៣. ការសិក្សាអំពីការកាត់បន្ថយពេលវេលាក្នុងឆ្នាំ២០០៥ និងការធ្វើផែនទីអំពីដំណើរការពាណិជ្ជកម្ម ឆ្នាំ ២០១០ ត្រូវបានរៀបចំឡើងក្រោមការផ្តល់មូលនិធិពីធនាគារពិភពលោក។ |

[11] IFC, Doing Business in 2011: Making a Difference for Entrepreneurs – Cambodia, Washington, DC: 2011
[5] Ibid

| # | សកម្មភាពដែលបានឯកភាព ខែមិថុនា ឆ្នាំ២០០៤ | សកម្មភាពដែលបានស្នើ ខែមិថុនា ឆ្នាំ២០០៤ | សកម្មភាពដែលបានអនុវត្ត និងស្ថានភាព ខែមិថុនា ឆ្នាំ២០០៤ |
|---|---|---|---|
| ៣. | ពិនិត្យឡើងវិញលើដំណើរការសម្របសម្រួលពាណិជ្ជកម្មដើម្បីលុបចោលនូវសេចក្ដីសម្រេចណាដែលជាន់គ្នា និងមិនចាំបាច់។ ដំណើរការនេះនឹងរួមបញ្ចូលនូវការពិនិត្យឡើងវិញនិងការធ្វើសនិទានកម្មលើឯកសារយោងនៃការនាំចូល/នាំចេញ និងការសម្រេចលើទម្រង់តែមួយសម្រាប់ការប្រកាសនាំចូល/ការនាំចេញ ដែលត្រូវប្រើប្រាស់ដោយភ្នាក់ងារនិយ័តកម្មទាំងអស់។ | ១. ទទួលអនុវត្តការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃលើដំណើរការនានានិងឯកសារសំអាងនាពេលបច្ចុប្បន្ន។ការត្រួតពិនិត្យឡើងវិញគួរធ្វើឡើងដោយមានជំនួយពីខាងក្រៅ/ ឯករាជ្យ។ ល័ក្ខខ័ណ្ឌយោងសម្រាប់ការត្រួតពិនិត្យឡើងវិញនិងការគាំទ្រផ្នែកផ្ដល់ប្រឹក្សា គឺតម្រូវឲ្យមាន។ EC បានគូសបញ្ជាក់អំពីការត្រៀមខ្លួនក្នុងការផ្ដល់ជំនួយបច្ចេកទេសទៅតាមការស្នើសុំរបស់រដ្ឋាភិបាល។<br>២. អនុវត្តទម្រង់ប្រកាសតែមួយសម្រាប់រាល់តម្រូវនៃការនាំចូល/ការនាំចេញ។<br>៣. ត្រួតពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានប្រសិនបើចាំបាច់។<br>៤. ផ្ដួចផ្ដើមដំណើរការកំណត់តម្រូវការ ITរយៈពេលវែងដើម្បី បន្តផ្សព្វផ្សាយពីនីតិវិធី និងសម្រួលឲ្យមានការទទួលយកនូវវិធានអនុវត្តដែលល្អបំផុត។ | ១. ការសិក្សាមួយដែលបានធ្វើឡើងកាលពីខែកុម្ភៈ ឆ្នាំ ២០០៥ បានបង្ហាញឲ្យឃើញថា ឯកសារចំនួន ៤៥ ប្រភេទតម្រូវឲ្យមានសម្រាប់ការនាំចេញ។<br>២ និង ៣. ឯកសាររដ្ឋបាលតែមួយ (SAD)ត្រូវបានណែនាំឲ្យប្រើជាដំបូង + ឯកសារមិនចាំបាច់នានាត្រូវបានកាត់ចោលដោយដាក់ជំនួសវិញនូវឯកសារទាំង ៤៥ មុខនោះ ។ យុទ្ធសាស្ត្រត្រួតពិនិត្យលើហានិភ័យសម្រាប់ការសម្របសម្រួលពាណិជ្ជកម្មត្រូវបានអនុម័តនៅក្នុងខែឧសភា ឆ្នាំ ២០០៦ ដោយអនុក្រឹត្យលេខ ២១។ SAD បែបអេឡិចត្រូនិចត្រូវបានសាកល្បងកាលពីឆ្នាំ ២០០៨។<br>៤.ប្រព័ន្ធ ASYCUDA ត្រូវបានណែនាំឲ្យប្រើនៅតាមចំណុចត្រួតពិនិត្យរបស់គយចំនួន ៥ កន្លែង រួមមាន អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ផែស្ងួត ៣កន្លែងក្នុងទីក្រុងភ្នំពេញ និងកំពង់ផែស្វយ័ត្តក្រុងព្រះសីហនុ ដោយមានជំនួយដំបូងពីក្រុមការងារបច្ចេកទេសរបស់ UNCTAD (បានបញ្ចប់ក្នុងឆ្នាំ ២០០៩)។ ប្រព័ន្ធ ASYCUDA ត្រូវបានដាក់ឲ្យដំណើរការដំបូងដោយមិនមានជំនួយបច្ចេកទេសអស់រយៈពេជាងមួយឆ្នាំ។ ការសិក្សាអំពីតម្រូវការប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានធ្វើឡើងនៅតាមចំណុចត្រួតពិនិត្យតាមព្រំដែនចំនួន ១៧ កន្លែងទៀតដែលនៅសល់កាលពីឆ្នាំ២០១០។ ប្រព័ន្ធ ASYCUDA ត្រូវចាប់ដំណើរការនៅតាមកន្លែងដែលនៅសល់ទាំងប៉ុន្មានក្នុងអំឡុងឆ្នាំ២០១១ និងដើមឆ្នាំ ២០១២។ ម៉ូឌុលប្រព័ន្ធ ASYCUDA ថ្មីត្រូវបានណែនាំឲ្យប្រើ រួមមានម៉ូឌុលដែលអនុញ្ញាតឲ្យឈ្មួញកណ្ដាលអាចបញ្ចូលទិន្នន័យដោយផ្ទាល់តាមប្រព័ន្ធអ៊ីនធឺណិតបាន និងម៉ូឌុលអំពីការដោះដូរពាណិជ្ជកម្ម។ |
| ៤. | ដាក់ចេញនូវយុទ្ធសាស្ត្រ គ្រប់គ្រងហានិភ័យជារួមដើម្បីច្របាច់បញ្ចូលគ្នា និងធ្វើសនិទានកម្មលើតម្រូវការនៃការត្រួតពិនិត្យទាំងអស់របស់ភ្នាក់ងារត្រួតពិនិត្យផ្សេងៗ។ | ១. បើកវគ្គបណ្ដុះបណ្ដាលអំពីការគ្រប់គ្រងហានិភ័យនិងអំពីការស៊ើបអង្កេតសម្រាប់គយ កាំកុងត្រូលនិងក្រុមមន្ត្រីរាជការដែលពាក់ព័ន្ធផ្សេងៗទៀត។ ការបណ្ដុះបណ្ដាលផ្ដោតលើជំនាញឯកទេសដែលមិនមាននៅក្នុងជួររដ្ឋាភិបាលកម្ពុជា។ AusAid បានបញ្ជាក់ពីឆន្ទៈក្នុងការផ្ដល់មូលនិធិសម្រាប់សកម្មភាពបែបនេះតាមរយៈ CATAF តបតាមការស្នើសុំរបស់រដ្ឋាភិបាល។<br>២. បង្កើត និងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ។ | ១. ការគ្រប់គ្រងហានិភ័យត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ២១ ស្ដីពីការគ្រប់គ្រហានិភ័យ (ខែមីនា ឆ្នាំ ២០០៦)។<br>២.ការគ្រប់គ្រងហានិភ័យត្រូវបានណែនាំឲ្យអនុវត្តលើកដំបូងនៅក្នុងចំណុចត្រួតពិនិត្យតាមព្រំដែនចំនួន ៥ កន្លែងជាកន្លែងដែលត្រូវបានដាក់ឲ្យប្រើប្រព័ន្ធ ASYCUDA រួមមានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ផែស្ងួត ៣ កន្លែងក្នុងទីក្រុងភ្នំពេញ និងកំពង់ផែស្វយ័ត្តក្រុងព្រះសីហនុ។ (ផែស្ងួត PHN MSE-KPM គឺជាផែទី៥ ដែលត្រូវអនុវត្តប្រព័ន្ធ ASYCUDA ដែលចូលជាធរមានកាលពីខែសីហា ឆ្នាំ ២០១០)។ ជាមធ្យមការត្រួតពិនិត្យពេញលេញ ("ច្រកក្រហម") នៅក្នុងទីតាំង ៤ កន្លែងត្រូវបានកាត់បន្ថយមកនៅត្រឹម ២០% នៃកុងតេន័រនាំចូល និង ១៣% នៃកុងតេន័រនាំចេញ។ ការអនុវត្តនេះទទួលបានផលតាមរយៈការកាត់បន្ថយប្រភេទទំនិញហាមឃាត់ពីបញ្ជីដើមប្រហែលពី ៥០០០ មុខ មកនៅត្រឹម ១៥៣៧ មុខ (អនុក្រឹត្យ ឆ្នាំ ២០០៧) |
| ៥. | ទទួលអនុវត្តការពិនិត្យឡើងវិញតាមយុទ្ធសាស្ត្រលើតួនាទី និងអាណត្តិរបស់កាំកុងត្រូលដើម្បីធានាថាខ្លួនបានប្រើប្រាស់អ្នកជំនាញច្បាស់លាស់របស់ខ្លួនប្រកបដោយផលិតភាពបំផុតលើការគ្រប់គ្រងគុណភាព។ | ១. ត្រួតពិនិត្យឡើងវិញទ្រង់ទ្រាយធំលើតួនាទីប្រតិបត្តិការ និងការផ្ដល់អាណត្តិដល់កាំកុងត្រូល។ ដើម្បីធានាឲ្យមានភាពឯករាជ្យ ការត្រួតពិនិត្យឡើងវិញគួរធ្វើឡើងដោយអ្នកជំនាញពីខាងក្រៅ។ ល័ក្ខខ័ណ្ឌយោងតម្រូវឲ្យមានការរៀបចំ។<br>២. រដ្ឋាភិបាលត្រូវពិនិត្យលើអនុសាស្ត្រនានា និងធ្វើការសម្រេចចិត្ត។<br>៣. រៀបចំជាថ្មី និងបណ្ដុះបណ្ដាលដល់មន្ត្រីដែលរងការប៉ះពាល់។<br>៤. វាយតម្លៃ និងត្រួតពិនិត្យតាមដានលើលទ្ធផល។ | ១. ផែនការគ្រប់គ្រងហានិភ័យតាមយុទ្ធសាស្ត្ររបស់កាំកុងត្រូលត្រូវបានបង្កើតឡើងដោយមានជំនួយពីអ្នកប្រឹក្សាអន្តរជាតិម្នាក់ និងអនុម័តដោយក្រសួងពាណិជ្ជកម្មកាលពីឆ្នាំ២០១០។ អង្គភាពគ្រប់គ្រងហានិភ័យរបស់កាំកុងត្រូលត្រូវបានបង្កើតឡើងកាលពីខែកញ្ញា ឆ្នាំ២០១០។<br>២. សំណើសុំការអភិវឌ្ឍសមត្ថភាពអង្គភាពគ្រប់គ្រងហានិភ័យរបស់កាំកុងត្រូលត្រូវបានរៀបចំឡើង និងត្រូវបានសម្រេចផ្ដល់មូលនិធិឲ្យដោយ TDSP ។<br>៣. ប្រកាសអន្តរក្រសួងស្ដីពី "ការអនុវត្តនិងការរៀបចំស្ថានប័នសម្រាប់សុវត្ថិភាពម្ហូបអាហារផ្អែកលើវិធាន" ចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគត្រូវបានអនុម័តកាលពីខែតុលា ឆ្នាំ២០១០។ ប្រកាសស្ដីពីវិធាន SPS របស់ភ្នាក់ងារផ្សេងៗនៅតាមព្រំដែន។ |

| # | សកម្មភាពដែលបានឯកភាព ខែមិថុនា ឆ្នាំ២០០៤ | សកម្មភាពដែលបានស្នើ ខែមិថុនា ឆ្នាំ២០០៤ | សកម្មភាពដែលបានអនុវត្ត និងស្ថានភាព ខែមិថុនា ឆ្នាំ២០០៤ |
|---|---|---|---|
| ៦. | បង្កើត និងអនុវត្តសាកល្បងនូវដំណើរការ "ច្រកចេញចូលតែមួយ" ដើម្បីគ្រប់គ្រងការសម្របសម្រួលពាណិជ្ជកម្មក្នុងកំពង់ផែក្រុងព្រះសីហនុ។ ការប្រើប្រាស់ស្វ័យប្រវត្តិកម្ម (សូមមើលផ្នែកសកម្មភាព ក្រោមចំណុច ៣ ខាងលើ) | ១. ធ្វើការបណ្តុះបណ្តាលដល់ភ្នាក់ងារគ្រប់គ្រងព្រំដែន។<br>២. បង្កើតហេដ្ឋារចនាសម្ព័ន្ធ និងសំណង់សមស្រប ដើម្បីឲ្យ "ការិយាល័យច្រកចេញចូលតែមួយ" មានដំណើរការល្អ។<br>៣. ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានដើម្បីជម្រុះ ចោលនូវឧបសគ្គនានាដែលរារាំងដល់កាម្រេចគោលដៅ "ច្រកចេញចូលតែមួយ" ។<br>៤. បង្កើត និងអនុវត្តសាកល្បងនូវវិធាន "ច្រកចេញចូលតែមួយ" នៅក្នុងកំពង់ផែក្រុងព្រះសីហនុ។ | ១. ប្រព័ន្ធ ASYCUDA នឹងក្លាយជាប្រព័ន្ធគ្រប់ដណ្តប់ដ៏សំខាន់មួយនៃច្រកចេញចូលតែមួយ។ គណៈកម្មាធិការច្រកចេញចូលតែមួយត្រូវបានបង្កើតឡើង<br>២. ត្រូវការពេលវេលាបន្ថែមទៀតសម្រាប់ GDCE និងភ្នាក់ងារពាក់ព័ន្ធដទៃទៀតក្នុងការត្រួតពិនិត្យឡើងវិញលើវិធីដែលល្អបំផុតក្នុងការរៀបចំបង្កើតច្រកចេញចូលតែមួយដែលល្អបំផុតសម្រាប់កម្ពុជា។ ការប្រើប្រាស់បទដ្ឋាន និងពិធីសារអន្តរជាតិ។ ការអនុវត្តនឹងត្រូវធ្វើទៅតាមកម្មវិធីការងារនៃច្រកចេញចូលតែមួយមួយរបស់អាស៊ាន។ ប្រទេសឡាវ វៀតណាម ភូមា កម្ពុជាមានពេលរហូតដល់ឆ្នាំ ២០១២ ដើម្បីដាក់ឲ្យប្រើប្រព័ន្ធនេះ ប៉ុន្តែ ASEAN-6 មានភាពយឺតយ៉ាវ។ |
| ៧. | ណែនាំឲ្យប្រើថ្លៃសេវាថេរស្របតាមអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដើម្បីធ្វើសនិទានកម្មលើប្រាក់បង់ផ្សេងៗ ដែលទើបប្រមូលបានក្នុងពេលបច្ចុប្បន្ន។ | ១. ពិនិត្យឡើងវិញលើប្រាក់បង់បច្ចុប្បន្នទាំងអស់ដើម្បីកំណត់ភាពស្របទៅតាមបទបញ្ញត្តិនានារបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។<br>២. បង្កើត និងអនុវត្តប្រព័ន្ធ និងរចនាសម្ព័ន្ធប្រាក់បង់ថ្មី<br>៣. បង្កើត និងអនុវត្តប្រាក់បង់សម្រាប់ការដាក់ក្នុងបញ្ជីតាមវិបសាយ និងព័ត៌មានពាក់ព័ន្ធ។ | ១. ការប៉ាន់ប្រមាណលើថ្លៃចំណាយប្រតិបត្តិការគយស្វ័យតត្រូវបានបង្កើតឡើង។ ការវិភាគលើថ្លៃចំណាយសម្រាប់ភ្នាក់ងារផ្សេងៗទៀតក៏តម្រូវឲ្យមានផងដែរ។<br>ត្រូវការពេលវេលាបន្ថែមទៀត។ |
| ៨. | ផ្សព្វផ្សាយពីដំណើរការ និងកាត់បន្ថយថ្លៃចំណាយលើការចុះបញ្ជីពាណិជ្ជកម្មសម្រាប់ការបង្កើតក្រុមហ៊ុន ។ | ១.បង្កើតការបណ្តុះបណ្តាលសម្រាប់មន្ត្រីពាក់ព័ន្ធ<br>២.កាត់បន្ថយថ្លៃបង់សម្រាប់ការចុះបញ្ជី<br>៣.ធ្វើវិមជ្ឈការដំណើរការចុះបញ្ជី<br>៤.កាត់បន្ថយតម្រូវការភាគហ៊ុនឲ្យនៅទាបបំផុតតាមដែលអាចធ្វើបាន។<br>៥.ណែនាំឲ្យប្រើប្រព័ន្ធចុះបញ្ជីតាមបែបអេឡិចត្រូនិច។ | ១. ផែនការព័ត៌មានវិទ្យាបច្ចុប្បន្នសម្រាប់ក្រសួងពាណិជ្ជកម្ម រួមមាន ការបញ្ចូលទៅក្នុងកុំព្យូទ័រសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមដោយមានជំនួយមូលនិធិពី TFCP និង TDSP។ ក្រសួងពាណិជ្ជកម្មចង់ឲ្យមានរីកចម្រើន ហើយគណៈគ្រប់គ្រង់ជាន់ខ្ពស់បានសម្រេចអនុម័តលើផែនការផ្សេងៗ ។<br>២. ដើមទុនអប្បបរមាសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មត្រូវបានកាត់បន្ថយពី ៥០០០ដុល្លារ មកនៅត្រឹមតែ១០០០ដុល្លារ។ ថ្លៃចំណាយសម្រាប់ការចុះបញ្ជីត្រូវបានកាត់ពី ៦៣០ដុល្លារ មកនៅត្រឹមតែ ១០៥ ដុល្លារ ប៉ុណ្ណោះក្នុងឆ្នាំ ២០០៧។ រយៈពេលចុះបញ្ជីក៏ត្រូវបានកាត់បន្ថយផងដែរ។<br>៣. បច្ចុប្បន្ននេះ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមត្រូវបានចេញនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ កិច្ចពិភាក្សានានាកំពុងតែដំណើរការដោយផ្តោតទៅលើការចេញវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមដែលអាចធ្វើបាននៅតាមបណ្តាខេត្តសំខាន់ៗ (ឧ. ខេត្តបាត់ដំបង សៀមរាប) ដើម្បីជួយដល់ការពង្រីកការនាំអង្ករចេញ (វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម បច្ចុប្បន្ននេះមានការចេញនៅក្នុងទីក្រុងភ្នំពេញ) ។ |
| ៩. | ផ្សព្វផ្សាយពីដំណើរការជូនដំណឹងទៅដល់ក្រសួងការងារ ដើម្បីចាប់ផ្តើមជ្រើសរើសនិយោជិត។ | ឧបសគ្គពេលវេលាបានធ្វើឲ្យរាំងស្ទះដល់ការពិចារណាលម្អិតរបស់ក្រុមការងារកំណែទម្រង់។ | មានការសម្របសម្រួលលើដំណើរការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ គ្មានការផ្លាស់ប្តូរនៅកន្លែងផ្សេងឡើយ។ |
| ១០. | ធ្វើសុខដុមនីយកម្មការចុះបញ្ជីសម្រាប់ VAT ពន្ធនាំចូល ការចុះបញ្ជីក្រុមហ៊ុន ដោយប្រើប្រាស់ទម្រង់ដូចគ្នា និងទទួលបានលេខពិសេសដូចគ្នា។ | ឧបសគ្គពេលវេលាបានធ្វើឲ្យរាំងស្ទះដល់ការពិចារណាលម្អិតរបស់ក្រុមការងារកំណែទម្រង់។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ឲ្យប្រើលេខអត្តសញ្ញាណកម្មតែមួយសម្រាប់ VAT និងគយកាលពីចុងឆ្នាំ ២០០៩។ |
| ១១. | អនុវត្តវិធីផ្តល់រង្វាន់លើកទឹកចិត្តថ្នាក់ជាតិ ដើម្បីលើកកម្ពស់ភាព ជាប្រជាពលរដ្ឋ និងអភិបាលកិច្ចដែលមានការសហការបានល្អនៅក្នុងវិស័យឯកជន | ១. បង្កើតគណៈកម្មាធិការវាយតម្លៃ<br>២. រៀបចំសិក្ខាសាលាផ្សេងៗ<br>៣. អនុវត្ត និងត្រួតពិនិត្យតាមដាន(ចំណាំ: សកម្មភាពនានាដែលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមនេះបច្ចុប្បន្ននេះកំពុងត្រូវបានអនុវត្តដោយក្រសួងពាណិជ្ជម្ម)។ | |
| ១២. | ត្រួតពិនិត្យតាមដាន និងរាយការណ៍ | ឧបសគ្គពេលវេលាបានធ្វើឲ្យរាំងស្ទះដល់ការពិចារណាលម្អិតរបស់ក្រុមការងារកំណែទម្រង់។ | ១. ទម្រង់រាយការណ៍ និងត្រួតពិនិត្យតាមដានមួយចំនួនស្ថិតក្នុងបរិបទ G-SPF រៀងរាល់ ២ឆ្នាំម្តង។<br>២. គយបានប្រើប្រាស់ផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ ដើម្បីដឹកនាំការរីកចម្រើនរបស់ខ្លួនឆ្ពោះទៅមុខ។ |

**តារាងលេខ ២ ៖** ច្បាប់ អនុក្រឹត្យរបស់រដ្ឋាភិបាល និងប្រកាសអន្តរក្រសួង

| | |
|---|---|
| ១. | **ច្បាប់គយ** បានប្រកាសឲ្យប្រើប្រាស់កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧។ |
| ២. | **អនុក្រឹត្យរបស់រដ្ឋាភិបាលលេខ ២០៩ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញរឹតត្បិត** ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៧។ |
| ៣. | **ប្រកាសរបស់ក្រសួង**<br>ប្រកាសស្តីពី បញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ<br>ប្រកាសស្តីពី ការផ្ទៀត និងកិច្ចដំណើរការដើងសារគយ<br>ប្រកាសស្តីពី ការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល<br>ប្រកាសស្តីពី ភណ្ឌាគារគយមានដែនកំណត់<br>ប្រកាសស្តីពី សន្និធិគយបណ្តោះអាសន្ន<br>ប្រកាសស្តីពី ការបង្វិលសងវិញនូវពន្ធ និងអាករគយ<br>ប្រកាសស្តីពី និមុត្តិធានា<br>ប្រកាសស្តីពី ការរាយការណ៍ ការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនទំនិញនាំចេញ<br>ប្រកាសស្តីពី ការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក<br>ប្រកាសស្តីពី ការគ្រប់គ្រងឯកសារ បញ្ជីគនណេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងៗទៀតអំពីការនាំចេញ និងនាំចូល<br>ប្រកាសស្តីពី ការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធ និងអាករ<br>ប្រកាសស្តីពី នីតិវិធីគ្រប់គ្រងទំនិញលើកលែងពន្ធ និងអាករ<br>ប្រកាសស្តីពី ការគ្រប់គ្រងទំនិញគ្មានការទាមទារ<br>ប្រកាសស្តីពី ការនាំចេញទំនិញបណ្តោះអាសន្ន<br>ប្រកាសស្តីពី ការអនុញ្ញាតឲ្យបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ<br>ប្រកាសស្តីពី ការពង្រីកវង់អំណាចគយ<br>ប្រកាសស្តីពី សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដោយទីចាត់ការគយ និងរដ្ឋាករ<br>ប្រកាសស្តីពី ការឆ្លងកាត់គយ<br>ប្រកាសស្តីពី នីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស<br>ប្រកាសស្តីពី នីតិវិធីនៃការគ្រប់គ្រងទំនិញកំណត់ពិសេស<br>ប្រកាសស្តីពី ការដឹកជញ្ជូន ការចែកចាយ និងការកាន់រក្សាទំនិញនៅក្នុងដែនគយ<br>ប្រកាសស្តីពី ការប្រើប្រាស់ព័ត៌មានដែលទទួលបានពីមន្ត្រីគយ<br>ប្រកាសស្តីពី ការសម្រុះសម្រួលបទល្មើសគយ<br>ប្រកាសស្តីពី អត្រាពន្ធគយ និងចំណាត់ថ្នាក់អត្រាពន្ធលើមុខទំនិញ<br>ប្រកាសស្តីពី ការចែកចាយជារង្វាន់ |
| ៤. | **គោលការណ៍ណែនាំដែលបានអនុម័ត**<br>សេចក្តីណែនាំលេខ ៥៨៣ ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការអនុវត្តសវនកម្មក្រោយពេលបញ្ចេញទំនិញលើកដំបូង<br>សៀវភៅណែនាំនៅក្នុងនាយកដ្ឋានគយ និងរដ្ឋាករ<br>សេចក្តីណែនាំលេខ ៧៩០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ និងនីតិវិធីសម្រាប់ការឆ្លងកាត់គយ |
| ៥. | **អនុក្រឹត្យ និងប្រកាសសំខាន់ៗ**<br>ប្រកាសស្តីពី នីតិវិធីនៃការបង់ពន្ធ និងអាករ និងពន្ធដទៃទៀតលើទំនិញនាំចូល និងទំនិញនាំចេញ<br>ប្រកាសស្តីពី ការរាយការណ៍អំពីទំនិញនាំចូល<br>ប្រកាសស្តីពី ការកំណត់អាត្រាការប្រាក់បំណុល<br>ប្រកាសស្តីពី នីតិវិធីសម្រាប់ការរឹបអូសជាបណ្តោះអាសន្ននូវទំនិញ ឯកសារផ្ទេរទំនិញ ឯកសារ និងសម្ភារៈផ្សេងទៀត<br>ប្រកាសស្តីពី ការរឹបអូស (បទល្មើស) របាយការណ៍<br>ប្រកាសស្តីពី នីតិវិធីបណ្តឹងឧទ្ធរណ៍<br>ប្រកាសស្តីពី ការលើកលែងពន្ធ អាករសម្រាប់អ្នកធ្វើដំណើរ កម្មករ និងអ្នកឆ្លងកាត់ព្រំដែន<br>អនុក្រឹត្យស្តីពី ការអនុញ្ញាតឲ្យមន្ត្រីគយអនុវត្តតួនាទីនៅក្រៅដែនគយ និងផ្តល់ការអនុញ្ញាតដល់មន្ត្រីគយបរទេសអនុវត្តតួនាទីនៅក្នុងដែនគយ។ |

*ការគ្រប់គ្រងគយ និងរដ្ឋាករ (ស្ថានភាពដើមឆ្នាំ ២០១១)*
***ប្រភព:*** *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ*
*គេហទំព័រ www.customs.gov.kh (ច្បាប់ និងបញ្ញត្តិ)*

**តារាងលេខ ៣** ៖ ការគ្រប់គ្រងហានិភ័យ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**នាយកដ្ឋានគយ និងរដ្ឋាករ កម្ពុជា**
**ក្រុមការងារគម្រោងថ្នាក់ជាតិនៃ** ASYCUDA

ឧបសម្ព័ន្ធ ១

ការរៀបចំ SAD សម្រាប់ឆ្នាំ 2010: អាត្រាការត្រួតពិនិត្យលើហានីភ័យលើ ទីតាំងរបស់ ASYCUDA ទាំងអស់

**ការរៀបចំ SAD សម្រាប់ការនាំចូល**

| ការិយាល័យ | សរុប | ក្រហម | | លឿង | | ខៀវ | | បៃតង | |
|---|---|---|---|---|---|---|---|---|---|
| | | SAD | ភាគរយ | SAD | ភាគរយ | SAD | ភាគរយ | SAD | ភាគរយ |
| PNH01 | 19868 | 3861 | 19.43% | 3553 | 17.88% | 11621 | 58.49% | 762 | 3.84% |
| PNH15 | 504 | 245 | 48.61% | 168 | 33.33% | 76 | 15.08% | 1 | 0.20% |
| PNH19 | 6286 | 1546 | 24.59% | 2015 | 32.06% | 2518 | 40.06% | 162 | 2.58% |
| PNH20 | 4004 | 462 | 11.54% | 1425 | 35.59% | 2075 | 51.82% | 31 | 0.77% |
| SHV11 | 44348 | 8921 | 20.12% | 21329 | 48.09% | 12293 | 27.72% | 385 | 0.87% |
| **G.T.** | **75010** | **15035** | **20.04%** | **28490** | **37.98%** | **28583** | **38.11%** | **1341** | **1.79%** |

**ការរៀបចំ SAD សម្រាប់ការនាំចេញ**

| ការិយាល័យ | សរុប | ក្រហម | | លឿង | | ខៀវ | | បៃតង | |
|---|---|---|---|---|---|---|---|---|---|
| | | SAD | Percent | SAD | Percent | SAD | Percent | SAD | Percent |
| PNH01 | 14049 | 1729 | 12.31% | 667 | 4.75% | 11401 | 81.15% | 252 | 1.79% |
| PNH15 | 168 | 53 | 31.55% | 42 | 25.00% | 75 | 44.64% | 0 | 0.00% |
| PNH19 | 31 | 2 | 6.45% | 14 | 45.16% | 15 | 48.39% | 0 | 0.00% |
| PNH20 | 138 | 6 | 4.35% | 64 | 46.38% | 68 | 49.28% | 0 | 0.00% |
| SHV11 | 1792 | 340 | 18.97% | 193 | 10.77% | 1155 | 64.45% | 78 | 4.35% |
| **G.T.** | **16178** | **2130** | **13.17%** | **980** | **6.06%** | **12714** | **78.59%** | **330** | **2.04%** |

**Note:**

PNH01 = 30 នាំចូល និង 15 SADs នាំចេញត្រូវបានលុបចោល

PNH15 = 13 នាំចូល និង 00 SAD នាំចេញត្រូវបានលុបចោល

PNH19 = 03 នាំចូល និង 00 SAD នាំចេញត្រូវបានលុបចោល

PNH20 = 02 ការនាំចូល និង 00 SAD នាំចេញត្រូវបានលុបចោល

SHV11 = 36 ការនាំចូល និង 02 SAD នាំចេញត្រូវបានលុបចោល

SAD G.T. មិនរាប់បញ្ចូលការលុបចោលការនាំចូល ៧២ និងការនាំចេញ ០៩

ក្រហម = ការត្រួតពិនិត្យរូបវ័ន្តពេញលេញ

លឿង = ស្ថិតក្រោមការត្រួតពិនិត្យឯកសារបញ្ជាក់

ខៀវ = ស្ថិតក្រោមសវនកម្មក្រោយការបញ្ចេញទំនិញ

បៃតង = បញ្ចេញភ្លាមៗ

G.T. = សរុបរួម

Total = ចំនួនសរុបនៃ of SAD

Offi. = ការិយាល័យ

PNH01 = ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

PNH15 = អនុសាខាគយ និងរដ្ឋាករផែស្ងួត MSE-KPM

PNH19 = អនុសាខាគយ និងរដ្ឋាករផែស្ងួត តិចស្រ៊ុន

PNH20 = អនុសាខាគយ និងរដ្ឋាករផែស្ងួត តេងឡាយ TENG LAY DRY PORT

SHV11 = អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការិយាល័យ Asycuda សាខាក្រុងព្រះសីនុ

SAD= ឯកសាររដ្ឋបាលតែមួយ



Photo by: Oxfam

# ការពង្រីក និងការធ្វើពិពិធកម្ម ការនាំអង្ករ ចេញរបស់កម្ពុជា



# IV. ការពង្រីក និងការធ្វើឲ្យមានភាពសម្បូរបែបសម្រាប់ការនាំអង្ករចេញរបស់កម្ពុជា

## សេចក្តីសង្ខេប


ផលិតកម្មស្រូវបានរីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ រាល់បរិមាណដែលលើសក្នុងស្រុកទាំងអស់ត្រូវបាននាំចេញក្នុងទម្រង់ជាស្រូវទៅកាន់ប្រទេសវៀតណាមនិងប្រទេសថៃដែលមកដល់ប្រទេសទាំងនេះស្រូវត្រូវបានកែច្នៃ ហើយបាននាំចេញក្នុងទម្រង់ជាអង្ករ ហើយទទួលបានតម្លៃបន្ថែមយ៉ាងច្រើន។ក្នុងអំឡុងពេល៣ឆ្នាំចុងក្រោយនេះមានសមាគមតូចមួយនៃក្រុមរោងម៉ាស៊ីនកិនស្រូវខ្នាតធំ និងមានកម្លាំងខ្លាំងបានចាប់ផ្តើមធ្វើការនាំចេញអង្ករ។ ចាប់ផ្តើមពីកាលពី ៣ ឬ ៤ឆ្នាំមុនដែលស្ទើរតែគ្មានការនាំអង្ករចេញសោះនោះ ការនាំចេញក្នុងឆ្នាំ ២០១០ - ២០១១ នឹងកើនឡើងដល់ ៥០.០០០ ទៅ ៦០.០០០តោន ហើយអាចនឹងមានការកើនឡើងប៉ុន្មានពាន់តោនទៀតក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខ។

ដើម្បីគាំទ្រដល់ការជំរុញការនាំចេញអង្ករ រដ្ឋាភិបាលបានសម្រេចចេញគោលនយោបាយនាំអង្ករចេញកាល ពីខែកក្កដា ឆ្នាំ ២០១០ ដែលផ្តោតលើការខិតខំប្រឹងប្រែងរបស់ក្រសួងពាក់ព័ន្ធនានាក្នុងការជម្រះចោលនូវឧបសគ្គទាំងឡាយ។ គោលនយោបាយនេះបានកំណត់នូវគោលដៅដ៏មាន មហិច្ឆតា គឺនាំចេញអង្ករឲ្យបាន ១ លានតោនក្នុងឆ្នាំ ចាប់ពីឆ្នាំ២០១៥ - ២០១៦។ ក្រៅពីការទទួលបានផលចំណេញពីវិស័យអង្ករនេះផ្ទាល់ ការអនុវត្ត និងភាពជោគជ័យនៃគោលនយោបាយនេះផ្តល់នូវបទពិសោធន៍ដ៏មានតម្លៃសម្រាប់រាជរដ្ឋាភិបាលក្នុងការបង្កើតនូវគោលនយោបាយស្រដៀងគ្នានេះសម្រាប់វិស័យនាំចេញផលិតផលកសិឧស្សាហកម្មដែលមានគោលដៅ ដើម្បីពង្រីក និងធ្វើពិពិធកម្ម។


## ១ បញ្ហាដែលត្រូវបានដោះស្រាយ

ដោយសារតែមានការរីកចម្រើនគួរឲ្យកត់សម្គាល់លើផ្នែកទិន្នផលដោយសារតែមានគ្រាប់ពូជល្អជាងមុន ផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជាបានការកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលកើនពី ៤,៥ លានតោនអំឡុងឆ្នាំ ២០០៣-២០០៤ ដល់ ៧,៥ លានតោន ក្នុងអំឡុងឆ្នាំ ១០០៧-២០១០។ បច្ចុប្បន្ននេះកម្ពុជា គឺជាប្រទេសធំជាងគេទី ១៤ លើពិភពលោកខាងផលិតកម្មស្រូវដែលឈរបន្ទាប់ពីប្រទេសថៃ ( ទី ៧ ) វៀតណាម ( ទី ៥ ) និងឥណ្ឌូណេស៊ី ( ទី៣ ) ក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ ប្រទេសចិននិងឥណ្ឌាគឺជាប្រទេសពីរដែលផលិតស្រូវធំជាងគេបង្អស់ ។

ស្របគ្នាជាមួយនឹងការកើនឡើងជាលំដាប់នូវការផ្គត់ផ្គង់ក្នុងស្រុក បរិមាណកើនឡើងនៃផលិតផលរបស់កម្ពុជាកំពុងត្រូវបានធ្វើការនាំចេញ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ការនាំចេញរបស់កម្ពុជាត្រូវបានធ្វើឡើងក្នុងទម្រង់ជាស្រូវដែលមិនមានការកែច្នៃក្រោយពីប្រមូលផលភ្លាមៗពីក្នុងស្រែ ហើយដឹកជញ្ជូនតាមរថយន្តទៅកាន់ប្រទេសវៀតណាម និងប្រទេសថៃជាទីដែលស្រូវត្រូវបានកែច្នៃ បន្ទាប់មកត្រូវបាននាំចេញបន្តទៀត។ ប្រទេសថៃ និងវៀតណាម គឺជាប្រទេសនាំចេញធំបំផុតនៅលើពិភពលោក។ ភាគច្រើនបំផុតនៃការនាំចេញស្រូវរបស់កម្ពុជា គឺមានលក្ខណៈ "ក្រៅផ្លូវការ" ហើយការតាមដានមានកម្រិតទាបតាមរយៈការប្រើប្រាស់វិធីសាស្ត្រវាស់វែងស្ថិតិពាណិជ្ជកម្មធម្មតាៗ (ទិន្នន័យនាំចេញជាផ្លូវការ ឬ ស្ថិតិដែលបង្ហាញដោយបណ្តាប្រទេសដែលនាំចូល)។ ស្របពេលជាមួយគ្នានេះដែរ ក្រុមអ្នកស្រាវជ្រាវបានប្រើប្រាស់វិធានមួយដែលផ្អែកលើទិន្នន័យផលិតកម្មសរុប និងការប្រើប្រាស់ក្នុងស្រុកដើម្បីធ្វើការប៉ាន់ស្មានអំពីទិន្នផលសរុបដែលត្រូវបាននាំចេញ។ សូមមើលតារាងលេខ ១១ ក្នុងអំឡុងឆ្នាំ ២០០៨-២០០៩ ស្រូវជិត ១,៦លានតោនត្រូវបានប៉ាន់ប្រមាណថា ត្រូវបាននាំចេញពីកម្ពុជា ដែលស្ទើរតែទាំងអស់គឺជាស្រូវ។ គិតត្រឹមឆ្នាំ ២០១០-២០១១ ចំនួននោះមានការកើនឡើងជាង ២ លានតោន ដែលមួយផ្នែកនៃការកើនឡើងនោះ គឺជាអង្ករ ។[១៣]

[១៣] អ្នកស្រាវជ្រាវជាច្រើនបានកំពុងធ្វើការងារទៅលើសង្វាក់ផលិតកម្មស្រូវរបស់កម្ពុជា ហើយមានការប៉ាន់ប្រមាណខុសៗគ្នាអំពីបរិមាណនាំចេញស្រូវតាមសមាមាត្រ (ផ្លូវការ និងក្រៅផ្លូវការ) ចន្លោះពី ២ លាន ទៅ ៣ លានតោន ក្នុងអំឡុងឆ្នាំ ២០០៨-២០០៩។ ករណីសិក្សានេះប្រើប្រាស់ការប៉ាន់ប្រមាណក្នុងលំដាប់ទាបជាងដែលអ្នកស្រាវជ្រាវទាំងនោះមើលឃើញថាមានភាពស៊ីគ្នាច្រើនជាមួយនឹងលំដាប់ដែលបានប៉ាន់ប្រមាណដោយក្រុមម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញធំៗបំផុតមួយចំនួនរួមទាំង Green Trade ផងដែរសម្រាប់អំឡុងឆ្នាំ ២០០៩-២០១០ និង ២០១០-២០១១។ ភាពខុសគ្នាតែងតែកើតចេញពីភាពមិនដូចគ្នានៃការប៉ាន់ប្រមាណលើការបាត់បងក្រោយពេលប្រមូលផល និងការប្រើប្រាស់ក្នុងស្រុក។ តាមការសិក្សាពេលបច្ចុប្បន្ន ដោយ Tom Slayton,ចំណងជើង A Road Map for Cambodian Rice Export, ខែឧសភា ឆ្នាំ ២០០៩។ ដោយ DAI,ចំណងជើង Rice Sector Value Chain, ឆ្នាំ ២០០៨។ ដោយ Gergely, Baris, និង Meas,ចំណងជើង An Economic Survey of the Rice Sector in Cambodia, AFD, ខែវិច្ឆកា ឆ្នាំ ២០១០ និងក្រសួងពាណិជ្ជកម្ម អង្គភាពអសង្វាក់ផលិតកម្ម ចំណងជើង Rice Sector Profile, ខែកញ្ញា ឆ្នាំ២០១០។

ការវិភាគយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មដែលបានធ្វើបច្ចុប្បន្នភាពកាលពីឆ្នាំ ២០០៧ របស់កម្ពុជា គឺ *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧* (CTIS 2007) បានកំណត់ការនាំចេញស្រូវថា ជាវិស័យមួយក្នុងចំណោមវិស័យនាំចេញដែលមានសក្តានុពលទាំង ១៩ ដែលត្រូវបានដឹងថា មានកាលានុវត្តភាពសម្រាប់កម្ពុជាក្នុងការធ្វើពិពិធកម្ម លើមូលដ្ឋាននាំចេញបច្ចុប្បន្នរបស់ខ្លួន រួមមានតាមរយៈការសម្រួលសង្វាក់តម្លៃ និងការពង្រីកទីផ្សារចូលទៅក្នុងទីតាំងភូមិសាស្ត្រថ្មីៗ។[១៤]

## ២ គោលដៅដែលត្រូវបន្ត

គោលដៅរបស់កម្ពុជាគឺត្រូវរំកិលចេញឲ្យឆ្ងាយពីភាពជាអ្នកនាំចេញស្រូវដ៏ចម្បងមួយមកជាអ្នកនាំចេញអង្ករដ៏ចម្បងវិញ ដូច្នេះត្រូវធ្វើការបង្កើនខ្សែសង្វាក់តម្លៃ រក្សាឲ្យបាននូវចំណែកនៃតម្លៃបន្ថែមដែលកំពុងមានកំណើនឡើង និងចាកចេញឆ្ងាយពីការពឹងផ្អែកក្នុងពេលបច្ចុប្បន្នរបស់ខ្លួនទៅលើការនាំចេញដែលមានតម្លៃទាបទៅកាន់ប្រទេសជិតខាងទាំងពីររបស់ខ្លួន។ គោលនយោបាយរបស់រដ្ឋាភិបាលបានដាក់ចេញនូវគោលដៅនាំអង្ករចេញឲ្យបាន ១ លានតោនក្នុងឆ្នាំ ២០១៥-២០១៦[១៥] ។ ក្នុងពេលរៀបចំករណីសិក្សានេះ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយនឹងរោងម៉ាស៊ីនកិនស្រូវធំៗមួយចំនួនដែលមានសមត្ថភាពអាចបំពេញតាមបរិមាណ និងបទដ្ឋានរបស់ប្រទេសហើយបានបង្ហាញថា ការនាំចេញអង្ករជាច្រើនពាន់តោនអាចសម្រេចបានភាគច្រើននៅក្នុងអំឡុងពេលពីរឆ្នាំ។

## ៣ បញ្ហាប្រឈមដែលបានជួបប្រទះ និងកត្តានាំទៅរកភាពជោគជ័យ

### ៣.១ ការពង្រីកសមត្ថភាពផ្គត់ផ្គង់ការនាំចេញអង្ករ និងការបង្កើតទីផ្សារថ្មីៗ

ដើម្បីឲ្យប្រទេសកម្ពុជាឆ្លើយតបទៅនឹងគោលដៅរបស់ខ្លួនក្នុងការពង្រីកការនាំចេញអង្ករដ៏ច្រើនសន្ធឹកសន្ធាប់ ចាំបាច់ត្រូវធ្វើការដោះស្រាយបញ្ហាជាច្រើនក្នុងពេលបច្ចុប្បន្ននេះ ដែលក្នុងនោះមានបញ្ហាសំខាន់ៗបំផុតមួយចំនួនដូចជា[១៦] ៖

១. ការបង្កើនផលិតភាព និងគុណភាពស្រូវ
២. ការបង្កើនកិច្ចសម្រួលពាណិជ្ជកម្ម (បន្ទាបថ្លៃចំណាយ រួមទាំងថ្លៃដឹកជញ្ជូន និងកាត់បន្ថយរយៈពេលកែច្នៃ)
៣. ការបង្កើនសមត្ថភាពកិនស្រូវ និងគុណភាពអង្ករ និងកាត់បន្ថយថ្លៃចំណាយលើការកិនស្រូវ (ជាពិសេសថ្លៃចំណាយលើថាមពល)
៤. ការបំពេញទៅតាមបទដ្ឋានទីផ្សារនាំចូល (គុណភាព និងអនាម័យ និងភូតគាមអនាម័យ [SPS])
៥. ការបង្កើតទំនាក់ទំនង និងកិច្ចសន្យាទីផ្សារក្រៅប្រទេសថ្មីៗ
៦. ការបង្កើនលទ្ធភាពប្រើប្រាស់ទុនសម្រាប់ដំណើរការម៉ាស៊ីនកិនស្រូវ។

គុណភាពនិងផលិតភាពគ្រាប់ពូជមានភាពល្អប្រសើរយ៉ាងច្រើនក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងនេះក្តី តាមការពិចារណាភាគច្រើន ចំណុចនេះនៅតែជាផ្នែកមួយដែលត្រូវធ្វើការកែលម្អដដែល។ ការគ្រប់គ្រងទឹក និងប្រព័ន្ធស្រោចស្រព្វក៏ជាផ្នែកដែលត្រូវតែធ្វើការកែលម្អ និងវិនិយោគផងដែរ។

ថ្លៃចំណាយមធ្យមលើការនាំចេញសម្រាប់កុងតេន័រលេខ២០មួយទូគឺថ្លៃ៧៣២ដុល្លារចេញពីកម្ពុជានៅក្នុងឆ្នាំ២០០៩បើប្រៀបធៀបទៅនឹងប្រទេសឥណ្ឌូណេស៊ីគឺ៧០៤ដុល្លារ និងប្រទេសថៃ៦២៥ដុល្លារដែលជាប្រទេសពីរជិតខាងមានការប្រកួតប្រជែងក្នុងការនាំអង្ករចេញ[១៧]។ សំខាន់ជាងនេះទៀត ការចំណាយលើការដឹកជញ្ជូនតាមផ្លូវគោក គឺមានកម្រិតខ្ពស់បើប្រៀបធៀបទៅនឹងប្រទេសថៃ និងវៀតណាម (១៥ដុល្លារ/តោន/១០០គីឡូម៉ែត្របើប្រៀបធៀបជាមួយនឹងប្រទេសថៃចំណាយត្រឹមតែ៨ដុល្លារ និងវៀតណាម៧,៥ដុល្លារ)[១៨]។ ជាមួយគ្នានេះដែរឧបមាថាអាចសម្រេចបានការនាំអង្ករចេញក្នុងចំនួន ១ លានតោន និងឧបមាថា កុងតេន័រលេខ ២០ មួយទូរផ្ទុកអង្ករបាន ២៤តោន នោះនឹងមានកុងតេន័រប្រហែល៤២០០០ទូរឬលើសពីនេះនឹងត្រូវការប្រើប្រាស់ឆ្លងកាត់តាមច្រកត្រួតពិនិត្យគយ និងច្រកព្រំដែនស្របច្បាប់ដែលធ្វើឲ្យមានកំណើនជិត ២៥% លើសចំនួនកុងតេន័របច្ចុប្បន្នដែលមានប្រហែល ១៨០ ០០០ ទូរ (គ្រប់ប្រភេទ) ត្រូវបានចរាចរតាមច្រកត្រួតពិនិត្យស្របច្បាប់[១៩] ។ ជាក់ស្តែងដំណើរការនេះនឹងទាមទារឲ្យមានការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធសម្របសម្រួលពាណិជ្ជកម្មផ្សេងៗ។

---

[១៤] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម ឆ្នាំ ២០០៧ ដាក់ចេញនៅរាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៧

[១៥] រាជរដ្ឋាភិបាលកម្ពុជា ឯកសារគោលនយោបាយស្តីអីការបង្កើនផលិតកម្មស្រូវ និងការនាំចេញអង្ករ អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០

[១៦] អង្គភាពខ្សែសង្វាក់តម្លៃ នាយកដ្ឋានជំរុញការនាំចេញ ក្រសួងពាណិជ្ជកម្ម ព័ត៌មាន និងយុទ្ធសាស្ត្រអំពីវិស័យអង្ករ រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១០

[១៧] ដោយ IFC, Doing Business 2011: Cambodia, ទីក្រុងវ៉ាស៊ីងតោន DC ឆ្នាំ ២០១១

[១៨] រាជរដ្ឋាភិបាលកម្ពុជា Policy Paper on the Promotion of Paddy Production and Rice Export, អនុម័តដោយទីស្តីការណៈរដ្ឋមន្ត្រី រាជធានី ភ្នំពេញ ថ្ងៃទី ២៥ ខែកក្កដា ឆ្នា ណា២០១០

[១៩] ការប៉ាន់ស្មានផ្អែកលើទិន្នន័យ និងព័ត៌មានដែលទទួលបានពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(GDCE) .

សមត្ថភាពកិនស្រូវក្នុងឆ្នាំ ២០១០ នាពេលបច្ចុប្បន្នដែលអាចបំពេញតាមបទដ្ឋានជាតិសម្រាប់ការនាំចេញអង្ករ គឺនៅមានកម្រិតសម្រាប់រោងម៉ាស៊ីនកិនស្រូវធំៗមួយចំនួនរបស់កម្ពុជា និងក្នុងលំដាប់ពី ៥០ ០០០ ទៅ ៦០ ០០០ តោន ។ តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែការវិនិយោគថ្មីៗធំៗនៃរោងម៉ាស៊ីនកិនស្រូវធំៗចំនួន ៣ បន្ថែមទៀត ធ្វើឲ្យសមត្ថភាពកើនឡើងយ៉ាងឆាប់រហ័សដល់បរិមាណប្រហែល ២៥០ ០០០ ទៅ៣៥០០០០តោនក្នុងអំឡុងពេល១៨ខែក្រោយ ឬប្រហាក់ប្រហែលនេះ។ ថ្លៃចំណាយលើផលិតកម្ម ជាពិសេសការចំណាយលើភ្លើងអគ្គិសនីនៅតែជាកត្តាមួយដ៏សំខាន់ ប្រសិនបើរោងម៉ាស៊ីនកិនស្រូវមិនមានលទ្ធភាពប្រើប្រាស់ប្រភពថាមពលផ្សេងដែលមានតម្លៃទាបនោះទេ (រាប់បញ្ចូលទាំងការប្រើប្រាស់អង្កាមសម្រាប់ផលិតថាមពលផងដែរ) ។

ក្រុមរោងម៉ាស៊ីនកិនស្រូវសម្រាប់នាំចេញភាគច្រើនក៏ត្រូវធ្វើការកែលម្អគុណភាពផលិតផលរបស់ខ្លួននិងបទដ្ឋានអនាម័យនិងភូតគាមអនាម័យ(SPS)ផងដែរដើម្បីបំពេញតាមតម្រូវការទីផ្សារនាំចូល។ ក្រោយពីដំណើរបេសកកម្មនាពេលថ្មីៗទៅកាន់ទ្វីបអឺរ៉ុប(ខែកញ្ញាឆ្នាំ២០១០) ក្រោមជំនួយហិរញ្ញប្បទានរួមពី AFD UNDP TRADE និង GTZ ក្រុមរោងម៉ាស៊ីនកិនស្រូវរបស់កម្ពុជាទាំងអស់ដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចនេះបានចង្អុលបង្ហាញពីបទពិសោធន៍ដ៏មានសារៈសំខាន់ដែលពួកគាត់ទទួលបានពីដំណើរទស្សនកិច្ចនេះ[២០]។ បច្ចេកវិទ្យាកែច្នៃថ្មីដែលកំពុងត្រូវបានដាក់ឲ្យប្រើនាពេលបច្ចុប្បន្ននឹងជួយដល់ដំណើរការនេះ ជាពិសេសក្នុងការកែលម្អគុណភាពនៃការកិន (និងកាត់បន្ថយភាគរយអង្ករបាក់)។

អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា កត្តាមួយក្នុងចំណោមកត្តានានាដែលអាចនឹងរឹតត្បិតលើអាត្រាដែលរោងម៉ាស៊ីនកិនស្រូវអាចមានលទ្ធភាពពង្រីកការនាំចេញរបស់ខ្លួននោះ គឺសមត្ថភាពក្នុងការជ្រៀតចូលទៅកាន់ទីផ្សារថ្មីៗ និងការបង្កើតទំនាក់ទំនង និងកិច្ចសន្យាធុរកិច្ចថ្មីៗ។ ការយកចិត្តទុកដាក់នាពេលបច្ចុប្បន្ននេះ គឺទៅលើទីផ្សាររបស់សហគមន៍អឺរ៉ុបដោយសារមានការលុបចោលពន្ធស្របតាម EBA (មានសុពលភាពកាលពីខែកញ្ញា ឆ្នាំ២០០៩)។ រោងម៉ាស៊ីនកិនស្រូវមួយចំនួនក៏អាចបង្កើតទំនាក់ទំនង និងឱកាសដើម្បីនាំចេញទៅកាន់ប្រទេសរុស្ស៊ីបានផងដែរ។ អាជ្ញាធរគយក្រុងព្រះសីហនុ បានចង្អុលបង្ហាញថា ការនាំចេញអង្ករជាង ៩០% ដែលបានឆ្លងកាត់តាមកំពង់ផែរនេះនៅក្នុងឆ្នាំ ២០១០ គឺមានគោលដៅទៅកាន់សហគមន៍អឺរ៉ុបឬទៅប្រទេសរុស្ស៊ី។ សម្រាប់រយៈពេលខ្លី ទីផ្សារទាំងនេះគឺជាឱកាសដ៏ល្អ ប៉ុន្តែសម្រាប់រយៈពេលវែង ទីផ្សារទាំងនោះនៅមិនទាន់ជាទីផ្សារនាំចូលដ៏ធំនៅឡើយទេ។

បណ្តាប្រទេសក្នុងសហគមន៍អឺរ៉ុបនាំអង្ករចូលប្រហែល១លានតោនជារៀងរាល់ឆ្នាំ បើធៀបទៅនឹងការនាំចូលសរុបរបស់ពិភពលោកដែលមានប្រហែល ៣៣ លានតោនក្នុងមួយឆ្នាំ (២០០៨-២០០៩) ដែលតិចជាង ៣% នៃការនាំចូលរបស់ពិភពលោក។ បរិមាណនៃការនាំចូលមានសភាពនៅទ្រឹងយ៉ាងខ្លាំងកាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ[២១] ។ ការនាំចូលប្រហែល ១០%របស់ប្រទេសក្នុងទ្វីបអឺរ៉ុប គឺជាប្រភេទអង្ករ Japonica ហើយនៅសល់ ៩០% ទៀតគឺជាប្រភេទអង្ករ Indica។ កម្ពុជាផលិតអង្ករប្រភេទ Indica។ យោងតាមពាណិជ្ជកររបស់សហគមន៍អឺរ៉ុប គឺថាកម្ពុជាអាចនឹងនាំអង្ករដល់ទៅ ១០០ ០០០ តោនចូលទៅក្នុងសហគមន៍អឺរុប ហើយចំនួន ៤០ ០០០ តោនទៀតនាំចូលទៅប្រទេសរុស្ស៊ី។ ដូច្នេះ ទីផ្សារផ្សេងៗទៀតនឹងចាំបាច់ត្រូវបង្កើតឡើងសម្រាប់រោងម៉ាស៊ីនកិនស្រូវរបស់កម្ពុជាដើម្បីធ្វើការនាំចេញឲ្យបានបរិមាណកាន់តែច្រើន។ ប្រតិបត្តិកររោងម៉ាស៊ីនកិនស្រូវមួយចំនួនចាប់ផ្តើមរុករកទីផ្សារនៅសហរដ្ឋអាមេរិក និងអាហ្វ្រិក។ ជាងនេះទៅទៀត វាក៏មានឱកាសផងដែរនៅក្នុងតំបន់អាស៊ី ដែលអាចធ្វើបាន រួមមានតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងរដ្ឋាភិបាល ដូចករណីក្នុងប្រទេសហ្វីលីពីនជាដើម។

តារាងលេខ ២ និងលេខ ៣ បង្ហាញពីផ្សារដែលសកម្មបំផុតចំនួន ២០ លំដាប់លើគេបង្អស់សម្រាប់ "អង្ករស" និង "អង្ករបាក់" ផ្សេងៗពីគ្នានេះបើតាមវិធីសាស្ត្ររបស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិដែលច្របាច់បញ្ចូលគ្នានូវទីផ្សារនាំចូល អត្រាកំណើននៃការនាំចូល និងអត្ថប្រយោជន៍លើពន្ធដែលបណ្តាអ្នកនាំចេញកម្ពុជាទទួលបាន បើប្រៀបធៀបទៅនឹងអ្នកប្រកួតប្រជែងផ្ទាល់បំផុតរបស់ខ្លួន។ ជាទូទៅ ពួកគេកំណត់ទិសដៅទៅតំបន់អាហ្វ្រិកដែលក្រុមប្រទេសតំបន់ឈូងសមុទ្រ និងប្រទេសក្នុងតំបន់អាស៊ីផ្សេងទៀត ដែលជាគោលដៅថ្មីមួយចំនួនក្នុងចំណោមគោលដៅថ្មីដែលមានការទាក់ទាញបំផុត។

ជាចុងក្រោយ បញ្ហាសំខាន់មួយទៀតនោះ គឺលទ្ធភាពទទួលបានទុនសម្រាប់ដំណើរការ។ ទន្ទឹមនឹងពេលដែលក្រុមរោងម៉ាស៊ីនកិនស្រូវធំៗបំផុត អាចមានលទ្ធភាពផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគថ្មីលើវិស័យកិនស្រូវនោះ កិច្ចការមួយក្នុងចំណោមកិច្ចការចាំបាច់បំផុតជាច្រើនដែលពួកគាត់ប្រឈមនោះ គឺលទ្ធភាពទទួលបានទុនសម្រាប់ដំណើរការដោយសារតែពួកគាត់ត្រូវផ្តល់ហិរញ្ញប្បទានសម្រាប់ទិញស្រូវ និងដើម្បីជួយដល់កសិករក្នុងការទិញពូជ និងជី។

## ៣.២. ការសម្របសម្រួល និងការគាំទ្រគោលនយោបាយរបស់រដ្ឋាភិបាល

ដើម្បីដោះស្រាយបញ្ហាទាំងនោះបាន ទីស្តីការគណៈរដ្ឋមន្ត្រីបានសម្រេចចេញនូវ ឯកសារគោលនយោបាយស្តីពីការលើកកម្ពស់ផលិតកម្មស្រូវ និងការនាំចេញអង្ករ នៅថ្ងៃទៅ២៥ខែកក្កដា ឆ្នាំ២០១០។ គោលនយោបាយនេះបានដោះស្រាយបញ្ហាសំខាន់ៗខាងលើ។ ឯកសារនេះត្រូវបានធ្វើសេចក្តីព្រាងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាភ្នាក់ងារស្រាវជ្រាវមួយរបស់ទីស្តីការគណៈរដ្ឋមន្ត្រីក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។ តារាងលេខ ៤ ផ្តល់នូវសេចក្តីសង្ខេបអំពីគោលនយោបាយនេះ។

[២០] Dr. Ralf Muller, បេសកកម្មរោងម៉ាស៊ីនកិនស្រូវកម្ពុជាទៅកាន់ទ្វីបអឺរ៉ុប របាយការណ៍បេសកកម្ម ក្រសួងពាណិជ្ជកម្ម /TDP,ខែតុលា ឆ្នាំ២០១០
[២១] គណៈកម្មាអឺរ៉ុប កសិកម្ម និងការអភិវឌ្ឍជនបទ៖ ស្រូវ ឆ្នាំ ២០១១

ដើម្បីឲ្យមានប្រសិទ្ធភាព គោលនយោបាយនេះត្រូវការការសម្របសម្រួលក្នុងកម្រិតណាមួយក្នុងចំណោមក្រសួងពាក់ព័ន្ធជាច្រើន។ គោលនយោបាយនេះបញ្ជាក់ថា គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុនឹងត្រូវទទួលបន្ទុកធ្វើការត្រួតពិនិត្យតាមដាន និងសម្របសម្រួលនៅកម្រិតគោលនយោបាយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ហើយក្រសួងពាណិជ្ជកម្ម (MoC) នឹងទទួលខុសត្រូវចំពោះការអនុវត្តវិធានការសំខាន់ៗជាច្រើន ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា (NBC) ត្រូវអនុវត្តផ្នែកហិរញ្ញវត្ថុ។ ក្នុងពេលនេះ គោលនយោបាយនេះមានគោលដៅរួមច្បាស់លាស់ (នាំអង្ករចេញឲ្យបាន ១ លានតោន) និងគោលដៅច្បាស់លាស់នានាពាក់ព័ន្ធនឹងជំនួយហិរញ្ញវត្ថុដែលមានការកើនឡើងចំពោះវិស័យនេះ និងប្រតិបត្តិករនៅក្នុងវិស័យនេះ។ នៅក្នុងផ្នែកផ្សេងៗទៀត គោលនយោបាយនេះមិនមានរៀបរាប់លម្អិតអំពីគោលដៅនៃការអនុវត្តការងារចំពោះអ្វីដែលក្រសួងនានាមានការរំពឹងទុក និងមិនមានយន្តការច្បាស់លាស់ដើម្បីគាំទ្រដល់ការត្រួតពិនិត្យតាមដានផ្ទាល់ជាងនេះលើការអនុវត្តរបស់ខ្លួនឡើយ។

## ៣.៣. ជំនួយសម្រាប់ពាណិជ្ជកម្ម

អំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ កម្ពុជាបានទទួលជំនួយយ៉ាងច្រើនពីប្រទេសអូស្ត្រាលីនិងជប៉ុននៅតាមកម្រិតកសិដ្ឋានជាពិសេសផ្តោតលើគ្រាប់ពូជ ការងារច្រូតកាត់ និងក្រោយការប្រមូលផល ប្រព័ន្ធស្រោចស្រព ទិន្នផលនិងផលិតភាពជាដើម។ល។ ជំនួយនេះមានសារៈសំខាន់ណាស់ក្នុងការចាប់ផ្តើមជាថ្មីនូវវិស័យសេដ្ឋកិច្ចកសិកម្មដែលពឹងផ្អែកយ៉ាងខ្លាំងលើអង្ករ និងទទួលរងការខ្ទេចខ្ទាំដោយសារសង្គ្រាមជាច្រើនឆ្នាំនិងអស្ថេរភាព។

នាពេលថ្មីៗនេះ គម្រោងជំនួយពាក់ព័ន្ធនឹងពាណិជ្ជកម្មសម្រាប់ការអភិវឌ្ឍ និងសមភាព (TRADE) របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) គម្រោងការកែច្នៃកសិកម្មរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) (មូលនិធិពីសហគមន៍អឺរ៉ុប) GTZ ក៏ដូចជាទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) បានផ្តោតការយកចិត្តទុកដាក់លើការរៀបចំរោងម៉ាស៊ីនកិនស្រូវ ដើម្បីបំពេញតម្រូវការទីផ្សារនាំចូល និងសិក្សាអំពីទីផ្សារទាំងនោះ។ ចន្លោះពីឆ្នាំ ២០០៨ មកដល់ដើមឆ្នាំ ២០១១ ម្ចាស់ជំនួយទាំងនោះបានផ្តល់មូលនិធិឲ្យក្រុមរោងម៉ាស៊ីកិនស្រូវទាំងនោះដើម្បីសិក្សា និងបង្កើតទំនាក់ទំនងអាជីវកម្មនៅក្នុងទីផ្សារតំបន់អាហ្វ្រិកខាងត្បូង (បេសកកម្មមួយ) និងទីផ្សារក្នុងសហគន៍អឺរ៉ុប (បេសកកម្ម៣)។លើសពីនេះទៀត រោងម៉ាស៊ីនកិនស្រូវត្រូវបាននាំទៅចូលរួមនៅក្នុងកម្មវិធីទីផ្សារអ្នកលក់-អ្នកទិញភាគខាងត្បូង ដែលរៀបចំឡើងនៅក្នុងទីក្រុង ហូជីមិញ នៅក្នុងឆ្នាំ ២០០៩។ ជំនួយបច្ចេកទេសបន្ថែមក្នុងការរុករកទីផ្សារផ្សេងទៀតនៅតំបន់អាហ្វ្រិក ដែលជាទីផ្សាររបស់ប្រទេស ក្នុងតំបន់ឈូងសមុទ្រ និងទីផ្សារនៅអាស៊ីក៏នឹងមានផលល្អផងដែរក្នុងទស្សនៈនៃការប្រកួតប្រជែងនាពេលអនាគត។

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងធនាគារពិភពលោកកំពុងរកវិធីផ្តល់មូលនិធិតាមយន្តការផ្តល់ហិរញ្ញប្បទានផ្សេងៗដែលមានការអំពាវនាវក្រោមគោលនយោបាយស្រូវ។ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) អាចនឹងចូលរួមជាផ្នែកខ្លះនៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនោះ។ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) រួមជាមួយនឹងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានធ្វើហិរញ្ញប្បទានដល់សន្និសីទអ្នកជំនាញមួយស្តីពីជំនួយហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៩ ដែលជួយត្រួសត្រាយផ្លូវសម្រាប់អនុសាស្ត្រមួយចំនួនដែលមានបញ្ចូលទៅក្នុងគោលនយោបាយនេះ។ ធនាគារអភិវឌ្ឍអាស៊ី និងកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) បានកំពុងនឹងធ្វើការងារលើបញ្ហាបទដ្ឋានបច្ចេកទេស និងអនាម័យ និងភូតគាមអនាម័យ (SPS) រួមទាំងផ្នែកដែលបង្កផលប៉ះពាល់ដល់ការនាំចេញផងដែរ[២២]។

ទន្ទឹមពេលដែលជំនួយសម្រាប់ពាណិជ្ជកម្មកំពុងត្រូវបានកំណត់គោលដៅយ៉ាងល្អសមស្របចំពោះ បញ្ហាដែលត្រូវការយកចិត្តទុកដាក់ ការសម្របសម្រួលនៃជំនួយសម្រាប់ពាណិជ្ជកម្មខាងភាគីរដ្ឋាភិបាលហាក់មានលក្ខណៈមិនហាក់លោតខ្លាំងរហូតមកដល់បច្ចុប្បន្ននេះនៅក្នុងផ្នែកពិសេសមួយនេះ។ ជាមួយនឹងអភិក្រមគ្របដណ្តប់លើវិស័យកសិកកម្ម និងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម និងលើពីនេះទៀត ធ្វើឲ្យគោលនយោបាយនាំចេញអង្ករកំពុងផ្តល់នូវគន្លឹះសំខាន់ៗ មួយចំនួនដល់រដ្ឋាភិបាលដើម្បីធ្វើឲ្យមានប្រសិទ្ធភាពកាន់តែខ្លាំងឡើងទៅលើការសម្របសម្រួលជំនួយសម្រាប់ពាណិជ្ជកម្ម។

## ៣.៤. ការកាត់បន្ថយកត្តាខាងក្រៅ

ក្នុងអំឡុងពេលវែង តម្រូវការសម្រាប់ការនាំចូលអង្ករនៅលើទីផ្សារពិភពលោក គឺជាមុខងារមួយនៃកត្តាពីរ គឺ កំណើនប្រជាជន និងកំណើនចំណូលរបស់មនុស្សម្នាក់ៗ។ ជំហានដំបូងនឹងមានទំនោរជំរុញឲ្យមានតម្រូវការ ជំហានបន្ទាប់នឹងជំរុញឲ្យមានការធ្លាក់ចុះ ។ ក្នុងអំឡុងពេលខ្លី ល័ក្ខខ័ណ្ឌអាកាសធាតុនឹងបង្កផលប៉ះពាល់ដល់តម្រូវការនាំចូល។ កត្តាផ្សេងៗទាំងនេះគឺហួសពីការគ្រប់គ្រងរបស់កម្ពុជា ឬ ហួសពីការគ្រប់គ្រងរបស់ក្រុមប្រតិបត្តិការរោងម៉ាស៊ីនកិនស្រូវរបស់ខ្លួន។ អត្រាកំណើន ៦% នាពេលបច្ចុប្បន្នក្នុងការនាំចូលអង្កររបស់ពិភពលោក គឺជាអត្រាមធ្យម ប៉ុន្តែវានៅតែមានការអនុគ្រោះដល់បណ្តាអ្នកនាំចេញរបស់កម្ពុជា។

[២២] TDSP ឬ កម្មវិធីទ្រទ្រង់ការអភិវឌ្ឍពាណិជ្ជកម្មត្រូវបានបង្កើតឡើងដើម្បីគាំទ្រគោលបំណងនានារបស់អភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្មកម្ពុជា និងអនុវត្តដោយក្រសួងពាណិជ្ជកម្ម។ កម្មវិធីនេះទទួលហិរញ្ញប្បទានពីមូលនិធិក្រោមអាណត្តិព្យាលភាពរបស់ម្ចាស់ជំនួយចម្រុះ (MDTF) ក្រោមការគ្រប់គ្រងរបស់ធនាគារពិភពលោក និងទទួលមូលនិធិពីសហគមន៍អឺរ៉ុប Danida និង UNIDO ។

នៅពីលើ និងបន្ថែមលើអាជីវកម្មផ្ទាល់ ការនាំចេញនាពេលបច្ចុប្បន្នទៅកាន់សហគមន៍អឺរ៉ុប និងរុស្ស៊ី កំពុងផ្តល់ឲ្យកម្ពុជានូវឱកាស "ខ្សែកោងសិក្សា" ដ៏មានសារៈសំខាន់។ ទោះជាយ៉ាងណាវានឹងមានហានិភ័យក្នុងការសន្មតថា ច្រកនៃឱកាសបច្ចុប្បន្ននៅក្នុងទីផ្សារនោះនឹងលែងមានទៀតលុះត្រាតែកម្ពុជាបានដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលកំពុងធ្វើឲ្យចុះខ្សោយដល់ការប្រកួតប្រជែងរបស់ខ្លួន។អ្នកនាំចូលដែលត្រៀមបង់ប្រាក់បន្ថែមក្រៅដំបូងដើម្បីបង្កើតភាពសម្បូរបែបចំពោះប្រភពផ្គត់ផ្គង់របស់ខ្លួននឹងមិនចង់បង់ប្រាក់បន្ថែមក្រៅនេះក្នុងរយៈពេលមធ្យម ឬ រយៈពេលវែងនោះទេ។ ដូចដែលបានគូសបញ្ជាក់ បច្ចេកវិទ្យាកិនស្រូវនឹងមានភាពប្រសើរឡើងជាមួយនឹងគុណភាព និងបទដ្ឋានអនាម័យ និងភូតគាមអនាម័យ (SPS) ប៉ុន្តែ ថ្លៃដឹកជញ្ជូនតាមផ្លូវគោក និងថ្លៃចំណាយលើថាមពលគឺមានកម្រិតខ្ពស់ និងជាកត្តាអវិជ្ជមានខ្លាំង។

លើសពីនេះទៀត ការទទួលបានអត្ថប្រយោជន៍ពីពន្ធគយនាពេលបច្ចុប្បន្នរបស់កម្ពុជាស្ថិតក្រោម EBA អាចនឹងមិនបញ្ចប់ទេ ប្រសិនបើពន្ធគយក៏ត្រូវបានកាត់បន្ថយចំពោះអ្នកប្រកួតប្រជែងដែលមិនមែនជាប្រទេសក្រីក្រនោះ (រួមមានប្រទេស ថៃ និងវៀតណាម)។ ការគំរាមកំហែងក្នុងការប្រកួតប្រជែងដ៏ចម្បងមួយទៀតសម្រាប់ការនាំចេញរបស់កម្ពុជាគឺប្រទេសភូមា ដែលជាប្រទេសមានសមត្ថភាពផ្គត់ផ្គង់ដ៏មានសក្តានុពលខ្លាំងក្លា និងដែលល័ក្ខខ័ណ្ឌក្នុងការជ្រៀតចូលទីផ្សារអាចនឹងប្រែប្រួលប្រសិនបើស្ថានភាពនយោបាយរបស់ប្រទេសនេះមានការផ្លាស់ប្តូរដែរនោះ។

ជាការពិតណាស់ រដ្ឋាភិបាលក៏ត្រូវមានការខ្វាយខ្វល់ផងដែរអំពីកំណើនយ៉ាងលឿនដែលអាចកើតមានទាក់ទងនឹងតម្លៃទីផ្សារពិភពលោកដែលជាលទ្ធផល អាចនឹងប៉ះពាល់ដល់ទីផ្សារក្នុងស្រុក។ ដូច្នេះហើយ នេះគឺជាលទ្ធភាពមួយដែលវិធានការបណ្តោះអាសន្នដែលដាក់កម្រិតលើការនាំចេញ អាចនឹងតម្រូវឲ្យអនុវត្ត ដើម្បីបង្ការការហក់ឡើងលឿននៃតម្លៃអាហារមូលដ្ឋានដ៏សំខាន់បំផុតរបស់ប្រទេស ដូចដែលបានកើតឡើងនៅក្នុងរដូវក្តៅក្នុងឆ្នាំ ២០០៩។ វិធានការបែបនេះត្រូវបានអនុញ្ញាតដោយអង្គការពាណិជ្ជកម្មពិភពលោក។

## ៤ លទ្ធផលដែលទទួលបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន

កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃចំណុចផ្លាស់ប្តូរ។ ត្រឡប់ទៅពាក់កណ្តាលឆ្នាំ២០០០ការនាំចេញអង្ករគឺមិនមានសារៈសំខាន់នោះទេ។ ក្នុងអំឡុងឆ្នាំ ២០០៩-២០១០ ការនាំចេញមានបរិមាណប្រហែលជា ២០ ០០០ តោន[២៣] ។ ក្នុងអំឡុងឆ្នាំ ២០១០-២០១១បរិមាណនាំចេញនេះអាចនឹងកើនដល់ ៥០ ០០០ ទៅ ៦០ ០០០ តោន[២៤]។ ការនាំចេញទៅគ្រប់ទិសទីក្នុងបរិមាណចន្លោះពី២៥០ ០០០ ទៅ ៥០០ ០០០ តោន ទំនងជាអាចសម្រេចបានក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខ[២៥] ។

## ៥ បទពិសោធន៍ដែលទទួលបាន

ការផ្លាស់ប្តូរពីការនាំចេញស្រូវដែលមានតម្លៃទាបទៅជាការនាំចេញអង្ករដែលមានតម្លៃខ្ពស់នឹងនាំឲ្យមានបទពិសោធន៍ជោគជ័យមួយនៃការពង្រីក និងការធ្វើពិពិធកម្មសម្រាប់បរិមាណនាំចេញរបស់កម្ពុជា។

គោលនយោបាយនាំចេញអង្ករអាចជាមគ្គុទេសក៍មួយសម្រាប់គោលនយោយ នៃវិស័យស្រដៀងគ្នាសម្រាប់ឱកាសនៃការនាំចេញផលិតផលកសិពាណិជ្ជកម្ម។ កង្វះគោលនយោបាយបែបនេះនៅក្នុងវិស័យផ្សេងៗទៀត (ឧ. គ្រាប់ស្វាយចន្ទី ដំឡូងមី កៅស៊ូ សូត្រ និងផលិតផលផ្សេងទៀត) មានន័យថា ជាញឹកញាប់អាជីវកម្មតែងតែខ្វះខាតការគាំទ្រដែល ខ្លួនអាចនឹងត្រូវការដើម្បីធ្វើឲ្យកាន់តែមានប្រសិទ្ធភាពឡើង ហើយជំនួយសម្រាប់ពាណិជ្ជកម្មអាច នឹងបាត់បង់ប្រសិទ្ធភាពជាងការដែលស្ថិតក្រោមការដឹកនាំដែលកាន់តែរឹងមាំ និងកាន់តែច្បាស់លាស់របស់រដ្ឋាភិបាល។ ជាការពិតនេះគឺជាកង្វល់ដែលត្រូវបានលើកឡើងដោយក្រុមដៃគូអភិវឌ្ឍខ្លួនឯងផ្ទាល់ ដែលចង់ឃើញមានភាពច្បាស់លាស់ជាងនោះទាក់ទងនឹងការផ្តោតការយកចិត្តទុកដាក់ទៅលើគោលនយោបាយនានានៅតាមកម្រិតផ្នែកនាំចេញជាលក្ខណៈបុគ្គល ដើម្បីផ្តល់ការណែនាំដែលប្រសើរឡើងសម្រាប់ជំនួយរបស់ខ្លួន។

---

[២៣] ការប៉ាន់ប្រមាណសម្រាប់ឆ្នាំ ២០០៩-២០១០ របស់ Green Trade និងដកស្រង់ពី Gergely, Baris, and Meas, An Economic Survey of the Rice Sector in Cambodia, AFD, ខែវិច្ឆិកា ឆ្នាំ ២០១០។

[២៤] ការប៉ាន់ប្រមាណសម្រាប់ឆ្នាំ ២០១០-២០១១ របស់ Green Trade និងផ្អែកលើសមត្ថភាពនៃម៉ាស៊ីនកិនស្រូវ ដែលបំពេញ បានទៅតាមបទដ្ឋានទីផ្សារអន្តរជាតិដែលមានស្រាប់ក្នុងប្រទេសកម្ពុជា ដូចកាលពីចុងឆ្នាំ ២០១០ (ប្រហែលជា ៥៥ តោន/ម៉ោង)

[២៥] ផ្អែកតាមការងារតាមមូលដ្ឋានៈ ខែមេសា ឆ្នាំ ២០១១ រោងម៉ាស៊ីនកិនស្រូវមួយត្រូវបានបើក ដែលត្បាល់កិនថ្មីមួយមានសមត្ថភាពផលិតបាន ១០០តោន/ម៉ោង ហើយរោងម៉ាស៊ីនពីរផ្សេងទៀត គ្រោងនឹងដំឡើងត្បាល់ថ្មីចំនួនពីរទៀតដែលមានសមត្ថភាពផលិត ប្រហាក់ប្រហែលគ្នា។

**តារាងលេខ ១** ៖ តារាងតម្លៃអង្ករបស់កម្ពុជា (២០០៨-២០០៩)




*ប្រភព ៖ Tom Slayton, ផែនទីបង្ហាញផ្លូវសម្រាប់ការនាំចេញស្រូវរបស់ប្រទេសកម្ពុជា, ខែឧសភា ឆ្នាំ២០០៩ ធ្វើបច្ចុប្បន្នកម្មដោយអង្គភាពខ្សែចង្វាក់តម្លៃនៃក្រសួងពាណិជ្ជកម្ម*

## **តារាងលេខ ២ ៖** ទីផ្សារទាក់ទាញបំផុតទាំង ២៥ សម្រាប់អង្ករបស់កម្ពុជា ឆ្នាំ ២០០៨ (HS 100630)

| ទីផ្សារ | ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារ (១.០០០ដុល្លារ) | ការនាំចូលសរុបទៅក្នុងទីផ្សារពីជុំវិញពិភពលោក | ចំណែកទីផ្សារនាំចូលទូទាំងពិភពលោក | កំណើនតម្លៃទីផ្សារ (អាចមានការប្រែប្រួល) | កំណើនតម្លៃទីផ្សារ (មានការប្រែប្រួលទាំងស្រុង) | ពន្ធអនុវត្តចំពោះកម្ពុជា | ផលប្រយោជន៍ពន្ធសម្រាប់កម្ពុជា (+) ឬ ការបាត់បង់ផលប្រយោជន៍ (-) | អ្នកប្រកួតប្រជែងធំៗក្នុងទីផ្សារ |
|---|---|---|---|---|---|---|---|---|
| ១. អារ៉ាប់ រួមអេមីរ៉េត | 0 | ១.៤៩៨.៩៨៤ | ៩,0 | ៤0 | ៨១៣.៣៥៦ | 0% | 0% | ឥណ្ឌា ប៉ាគីស្ថាន ថៃ |
| ២. អ៊ីរ៉ង់ | 0 | ១.១១៣.៥៨៤ | ៦,៦ | ៣៣ | ៤៤៤.៤0១ | ៤% | 0% | អារ៉ាប់រួម ប៉ាគីស្ថាន អ៊ុយរ៉ាហ្គាយ |
| ៣. អារ៉ាប៊ីសាអូឌីត | 0 | ១.១៤៥.៤១២ | ៦,៨ | ២១ | ៦១២.៥៥0 | 0% | 0% | ឥណ្ឌា ប៉ាគីស្ថាន សហរដ្ឋអាមេរិក |
| ៤. ហ្វីលីពីន | 0 | ១.៩៥១.0៦៥ | ១១,៦ | ៦៥ | ១.៦៨៨.៧៣៨ | ៥0% | 0% | វៀតណាម ថៃ សហរដ្ឋអាមេរិក |
| ៥. សហរដ្ឋអាមេរិក | 0 | ៥៣២.១៣៩ | ៣,២ | ២0 | ២៧៤.៨៨១ | 0% | ១% | ថៃ ឥណ្ឌា ចិន |
| ៦. ម៉ាឡេស៊ី | ៥៩៩ | ៦៥៣.៧៦៣ | ៣,៩ | ៤៨ | ៥១៧.៤៨៥ | ៤0% | 0% | ថៃ វៀតណាម ប៉ាគីស្ថាន |
| ៧. បេណាំង | 0 | ៤៩៩.៨២៧ | ៣,0 | ៤៨ | ៣៩៦.៤៦៧ | ១0% | 0% | ថៃ ប្រេស៊ីល ប៉ាគីស្ថាន |
| ៨. បង់ក្លាដេស | 0 | ៥0៣,0១៥ | ៣,0 | ២៩ | ៣១៩.៧៧២ | ៥% | 0% | ឥណ្ឌា ថៃ ប៉ាគីស្ថាន |
| ៩. អាហ្វ្រិកខាងត្បូង | 0 | ៤៤៦.៣៣៩ | ២.៧ | ២២ | ២៤៤.0៤៤ | 0% | 0% | ថៃ ឥណ្ឌា ចិន |
| ១0. អូម៉ង់ | 0 | ៣៥0.៨៤១ | ២,១ | ៥២ | ២៨៥.៥៩៦ | 0% | 0% | ប៉ាគីស្ថាន ថៃ អារ៉ាប់រួម |
| ១១. យេមែន | 0 | ២២៤.៤៩៦ | ១,៣ | ៥៥.៦ | ១៨៦,២៤១ | 0% | 0% | ថៃ ឥណ្ឌា ប៉ាគីស្ថាន |
| ១២. ចក្រភពអង់គ្លេស | 0 | ២៨៨.១៨១ | ១,៧ | | | 0% | 0% | អ៊ីតាលី ហ៊ុឡង់ បារាំង |
| ១៣. បារាំង | ១.៨៤៩ | ៣៤៤.៥៦៨ | ២,១ | ១៤ | ១៣៧,១៦៧ | 0% | ៧% | អ៊ីតាលី ថៃ អេស្ប៉ាញ |
| ១៤. គុយវ៉ែត | 0 | ២៤៣.៧0៦ | ១,៥ | ៣២,៦ | ១៦៣,៨៤៦ | 0% | 0% | ឥណ្ឌា ប៉ាគីស្ថាណ ថៃ |
| ១៥. កូឌីវ៉រ | 0 | ៣៣១.៩៥៨ | ២.0 | ១៨,៨ | ១៦៥,២១៩ | ១0% | 0% | ថៃ វៀតណាម ប៉ាគីស្ថាន |
| ១៦. អាឡឺម៉ង់ | ១២១ | ២២៥.៣៨៨ | ១.៣ | ១៩,៥ | ១១៥,00៨ | 0% | ៧% | អ៊ីតាលី ថៃ ហ៊ុឡឡង់ |
| ១៧. កាតា | 0 | ១៣៧.១៤៣ | 0.៨ | ៧៣,៧ | ១២២,0៩២ | 0% | 0% | ប៉ាគីស្ថាន ឥណ្ឌា ថៃ |
| ១៨. អូស្ត្រាលី | 0 | ១៥៧.៦0៣ | 0.៩ | ៤0,២ | ១១៦,៨៦៨ | 0% | 0% | ប៉ាគីស្ថាន ឥណ្ឌា ថៃ |
| ១៩. សហព័ន្ធរុស្ស៊ី | 0 | ១៦២.៦៣0 | ១,0 | ១៨,២ | ៧៩.៤១៣ | 0% | ២១% | ថៃ វៀតណាម ចិន |
| ២0. កាណាដា | 0 | ២៤0.៧១១ | ១,៤ | ១៥,៧ | ១0៦,២៦៥ | 0% | 0% | សហរដ្ឋអាមេរិក ថៃ ឥណ្ឌា |
| ២១. ហុង កុង | 0 | ២៥៤,១៤២ | ១,៥ | ១៣,៤ | ១00,៧២២ | 0% | 0% | ថៃ ចិន អូស្ត្រាលី |
| ២២. សឹង្ហបូរី | ៨៦ | ២១៩,00៩ | ១,៣ | ១៨ | ១0៦,៩៧៥ | 0% | 0% | ថៃ ឥណ្ឌា វៀតណាម |
| ២៣. លីប៊ី | 0 | ១១២,0២៣ | 0,៧ | ៧៥,៨ | ១00,២៣៨ | 0% | 0% | ថៃ អេស៊ីប តៃវ៉ាន់ |
| ២៤. បេឡារូស្ស | ៨ | ២៥,៤១៩ | 0,២ | ៣0,៧ | ១៦,៧0៤ | 0% | ១៧% | ប៉ាគីស្ថាន វៀតណាម ឥណ្ឌា |
| ២៥. អ៊ីតាលី | ២៣៤ | ៤១,៥0៨ | 0,២ | ៣១,៨ | ២៧,៧៣៦ | ១៧% | ៣% | ថៃ អឡឺម៉ង់ បារាំង |

*ប្រភព : អង្គភាពខ្សែចង្វាក់តម្លៃនៃក្រសួងពាណិជ្ជកម្ម*

*ចំណាំ : ទីផ្សារដែលមានការទាក់ទាញត្រូវបានកំណត់ដោយផ្អែកលើសន្ទស្សន៍រួមផ្សំដែលរួមបញ្ចូលនូវទំហំនៃការនាំចូលបច្ចុប្បន្នតាមប្រទេសក្នុងឆ្នាំ ២០០៨ កំណើននៃការនាំចូលក្នុងអំឡុងឆ្នាំ ២០០៤-២០០៨ ពន្ធគយដែលត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា និងគុណប្រយោជន៍/*

*ចំណាំ : ទន្ទឹមនឹងការប្រើប្រាស់ទិន្នន័យឆ្នាំ ២០០៤-២០០៨ តារាងនេះ និងតារាងបន្តទៀតមាន ការកែតម្រូវ និងសន្មត់ពីពន្ធគយ 0% នៃការលើកលែងពន្ធគ្រប់ប្រភេទលើកលែងតែអាវុធសម្រាប់កម្ពុជា ទៅកាន់បណ្តាប្រទេសរបស់សហភាពអឺរ៉ុប (ដែលចូលជាធរមាននៅក្នុងខែកញ្ញា ឆ្នាំ២០០៩)*

**តារាងទី ៣ ៖** ទីផ្សារទាក់ទាញបំផុតទាំង ២០ សម្រាប់អង្ករបាក់របស់កម្ពុជាឆ្នាំ ២០០៨ ( HS 100640 )

| ទីផ្សារ | ការនាំចូលសរុបទៅក្នុងទីផ្សារពីជុំវិញពិភពលោក | ចំណែកក្នុងទីផ្សារនាំចូលរបស់ពិភពលោក | កំណើនការនាំចូល ២០០៤-២០០៨ | ពន្ធអនុវត្តចំពោះកម្ពុជា | ផលប្រយោជន៍ពន្ធសម្រាប់កម្ពុជា (+) ឬ ការបាត់បង់ផលប្រយោជន៍ (-) | ដៃគូប្រកួតប្រជែងសំខាន់ៗនៅលើទីផ្សារ |
|---|---|---|---|---|---|---|
| ១. បែលហ្ស៊ិក | ៨៥.២៩៣ | ៤,៥ | ៣៨,៤ | 0% | ១២% | ហ៊ុឡង់ ថៃ ប៉ាគីស្ថាន |
| ២. ហ្គាណា | ១៤៤.២៦៥ | ៧,៧ | ខ្ពស់ | ២០% | 0% | ថៃ សហរដ្ឋអាមេរិក វៀតណាម |
| ៣. កូឌីវ័រ | ១៣៦.២៩៧ | ៧,៣ | ៣១,៧ | ១០% | 0% | ថៃ វៀតណាម ប៉ាគីស្ថាន |
| ៤. ហ្វីលីពីន | ៦៧.៩៧៧ | ៣,៦ | ២១,៩ | 0% | ៩% | ថៃ អេស្ប៉ាញ អ៊ីតាលី |
| ៥. ចក្រភពអង់គ្លេស | ៦៧.៣០៨ | ៣,៦ | ១៦,២ | 0% | ១១% | អេស្ប៉ាក ថៃ សហរដ្ឋអាមេរិក |
| ៦. សណេហ្គាល់ | ៥៦៨.៤២៨ | ៣០,៣ | ២៥,១ | ១០% | 0% | ថៃ វៀតណាម ប្រេស៊ីល |
| ៧. ម៉ាឡេស៊ី | ៨២.៧៦៤ | ៤,៤ | ១១៦,២ | ៤០% | 0% | ថៃ វៀតណាម ប៉ាគីស្ថាន |
| ៨. ម៉ូរីតានី | ៧២.៣១៧ | ៣,៨ | ៥១,0 | ១៣% | 0% | ថៃ ប្រេស៊ីល បែលហ្ស៊ិក |
| ៩. គីណេ | ៦៧.២២១ | ៣,៦ | ២៥,៩ | ១0% | 0% | ថៃ វៀតណាម ប៉ាគីស្ថាន |
| ១០. ម៉ាលី | ៤០.២៨៧ | ២,១ | ៣៩,៣ | ១0% | 0% | ថៃ ជប៉ុន ឥណ្ឌា |
| ១១. អាឡឺម៉ង់ | ២៨.៤៨៤ | ១,៥ | ២៦,៥ | 0% | ១៣% | ហ៊ុឡង់ ថៃ សហរដ្ឋអាមេរិក |
| ១២. ហ៊ុឡង់ | ៣២.៦៩៥ | ១,៧ | | 0% | ៤,៥% | អ៊ីតាលី ថៃ បែលហ្ស៊ិក |
| ១៣. ជប៉ុន | ៦៣.៩០០ | ៣,៤ | ១៣,0 | ៨២៧% | 0% | ថៃ  សហរដ្ឋអាមេរិក ចិន |
| ១៤. សហរដ្ឋអាមេរិក | ២២.៩៧៣ | ១,២ | ១១៤,២ | 0% | ១% | ថៃ មិចសីចកូ ចិន |
| ១៥ អ៊ីតាលី | ៧.៣៥១ | 0,៤ | | 0% | ៧,៥% | ថៃ បែលហ្ស៊ិក ចក្រភពអង់គ្លេស |
| ១៦. នីសេរីយ៉ា | ១៦.៦០០ | 0,៩ | ១១៩,៧ | ១0% | 0% | ថៃ ប៉ាគីស្ថាន វៀតណាម |
| ១៧. អារ៉ាប់រួមអេមីរ៉េត | ៧.៦១៧ | 0,៤ | ១១0,៥ | 0% | 0% | ប៉ាគីស្ថាន ថៃ ឥណ្ឌា |
| ១៨. ឥណ្ឌូណេស៊ី | ២៨.៩៧៤ | ១,៥ | ៣៦,0 | ២២% | 0% | ថៃ វៀតណាម ប៉ាគីស្ថាន |
| ១៩. អាហ្វ្រិកខាងត្បូង | ១២.៤៣៦ | 0,៧ | ៦១,៤ | 0% | 0% | វៀតណាម ថៃ ឥណ្ឌា |
| ២០. អូស្ត្រាលី | ១៣.0៦៤ | 0,៧ | ៤៥,៣ | 0% | 0% | ថៃ សហរដ្ឋអាមេរិក ប៉ាគីស្ថាន |

*ប្រភព ៖ អង្គភាពខ្សែចង្វាក់តម្លៃនៃក្រសួងពាណិជ្ជកម្ម*

## **តារាងទី ៤ ៖** គោលនយោបាយស្រូវខែកក្កដា ឆ្នាំ ២០១០ របស់រដ្ឋាភិបាល

| | បញ្ហាចម្បង (វិធានការគោលនយោបាយដែលត្រូវបានជ្រើសរើស) | ស្ថាប័នទទួលបន្ទុក |
|---|---|---|
| | **ផលិតកម្មស្រូវ** | |
| ជ័យជំនះរហ័ស | បង្កើនផលិតភាពតាមរយៈការប្រើគ្រាប់ពូជដែលទទួលបានទិន្នផលខ្ពស់ និងបច្ចេកទេសផលិតកម្មទំនើប (ជួយសម្រួលដល់ការនាំចូលគ្រាប់ពូជ និងជី និងពង្រឹងផលិតកម្មគ្រាប់ពូជក្នុងស្រុក ពិនិត្យឡើងវិញលើសេវាផ្សព្វផ្សាយកសិកម្ម។ល។) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | បន្តពង្រីកប្រព័ន្ធស្រោចស្រព (ពង្រឹងគម្រោងស្រោចស្រពខ្នាតតូច ថែទាំប្រព័ន្ធស្រោចស្រព ជាដើម)។ | ក្រសួងធនធានទឹក និងឧតុនិយម<br>និងក្រសួងពាក់ព័ន្ធផ្សេងទៀត |
| | ថែទាំផ្លូវថ្នល់ បង្កើតបណ្តាញផ្លូវតូចៗតាមទីជនបទ | ក្រសួងអភិវឌ្ឍន៍ជនបទ<br>និងក្រសួងពាក់ព័ន្ធនានា |
| | លើកកម្ពស់ឥណទានខ្នាតតូច | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា |
| រយៈពេលមធ្យម/<br>រយៈពេលវែង | ធ្វើឲ្យប្រសើរឡើងនូវផលិតភាព និងប្រពលវប្បកម្មដំណាំ (ផែនការគ្រប់គ្រងទឹករយៈពេលវែង និងការស្តារឡើងវិញនូវស្ថានីយ និងមជ្ឈមណ្ឌលកសិកម្ម កិច្ចការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាដើម | ក្រសួងធនធានទឹក និងឧតុនិយម<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | អនុវត្តគោលនយោបាយថ្នាក់ជាតិសម្រាប់ ចែកចាយអគ្គិសនីកម្មនៅតាមជនបទ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល,<br>ក្រសួងពាក់ព័ន្ធនានា |
| | បង្កើត និងពង្រឹងសមត្ថភាពអង្គការកសិករ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,<br>ក្រសួងពាក់ព័ន្ធនានា |
| | លើកកម្ពស់ និងអនុវត្តគោលនយោបាយស្តីពីការប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព | ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់,<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,<br>ក្រសួងពាក់ព័ន្ធនានា |
| | **ការប្រមូលស្រូវ និងការកែច្នៃ** | |
| ជ័យជំនះរហ័យ | លើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជនក្នុងការផលិត និងការកិនស្រូវ (បន្តអនុវត្តច្បាប់ស្តីពីការវិនិយោគ ធ្វើការកែលម្អ ប្រសិនបើចាំបាច់) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា,<br>ក្រសួងពាក់ព័ន្ធនានា |
| | លើកកម្ពស់ការផ្តល់ហិរញ្ញប្បទានដល់ការប្រមូលស្រូវ (ផ្តល់ទុនបន្ថែម ៧ លានដុល្លារទៅឲ្យធនាគារអភិវឌ្ឍជនបទ បង្កើនទុនទ្វេដងសម្រាប់មូលនិធិអភិវឌ្ឍន៍ និងគាំទ្រកសិកម្ម ពី ៨លាន ទៅ ៣៦ លានដុល្លារ បង្កើតគ្រោងការធានាឥណទានដើម្បីធានាចំពោះប្រាក់កម្ចីពីធនាគារពាណិជ្ជទៅឲ្យវិស័យអង្ករ បង្កើតវិធីសាស្ត្រចែករំលែកហានិភ័យសម្រាប់ធនាគារពាណិជ្ជដើម្បីផ្តល់កម្ចីសម្រាប់ការកែច្នៃពាណិជ្ជកម្ម) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា |
| | អនុវត្តចំពោះសមាគមម៉ាស៊ីនកិនស្រូវប្រហាក់ប្រហែលគ្នានឹងការប្រព្រឹត្តចំពោះ GMAC ដែរ | រាជរដ្ឋាភិបាលកម្ពុជា |
| រយៈពេលមធ្យម/<br>រយៈពេលវែង | បង្កើតលិខិតុបករណ៍ហិរញ្ញវត្ថុ និងយន្តការផ្តល់ហិរញ្ញប្បទានដ៏មានប្រសិទ្ធភាព (អនុវត្តច្បាប់ស្តីពីការផ្ទេរប្រាក់ដែលមានការធានា និងកិច្ចសន្យាផ្តល់ហិរញ្ញប្បទាន បង្កើតព័ត៌មានអំពីឥណទាន ពិចារណាលើការបង្កើតធនាគារអភិវឌ្ឍន៍កសិកម្ម) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា |
| | បង្កើត "ទីផ្សារស្រូវបើកចំហរ" (បង្កើតការធ្វើកសិដ្ឋានចុះកិច្ចសន្យាជុំវិញទីផ្សារទិញផលិតកម្មអង្ករ កម្ចីយកស្រូវជាទ្រព្យបញ្ចាំ) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,<br>ក្រសួងពាក់ព័ន្ធនានា |
| | ទម្លាក់តម្លៃអគ្គិសនី និងពង្រីកតំបន់គ្របដណ្តប់ (ពន្លឿនការធ្វើពិពិធកម្មនូវប្រភពថាមពលតាមជនបទ កែលម្អការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា ជាដើម )។ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា |
| | **កិច្ចការរៀបចំ** | |

| | | |
|---|---|---|
| ជ័យជំនះរហ័ស | បង្កើនការសម្របសម្រួលពាណិជ្ជកម្ម កាត់បន្ថយការចំណាយក្រៅផ្លូវការ លុបបំបាត់កុងត្រូវជផុះ (ពង្រីកការប្រព្រឹត្តពិសេសស្រដៀងគ្នាទៅនឹងវិស័យកាត់ដេរដែរ) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/<br>អគ្គនាយកដ្ឋានគយ និងរដ្ឋាករ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងពាណិជ្ជកម្ម/កាំកុងត្រូល<br>ក្រសួងពាក់ព័ន្ធ |
| | អនុវត្តសេវាច្រកចេញចូលតែមួយសម្រាប់ដំណើរការនាំចេញ (សម្រាប់ការចេញវិញ្ញាបនបត្រ SPS ការបាញ់ថ្នាំសម្លាប់សត្វល្អិត ការធ្វើចំណាត់ថ្នាក់ផលិតផល និងគុណភាព ទម្ងន់ ការវាស់វែង ការប្រកាសរបស់គយ) | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/<br>អគ្គនាយកដ្ឋានគយ និងរដ្ឋាករ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងពាណិជ្ជកម្ម/កាំកុងត្រូល<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល/<br>វិទ្យាស្ថានបទដ្ឋាននៃកម្ពុជា ក្រសួងពាក់ព័ន្ធ |
| | ដោះស្រាយបញ្ហាធ្វើចំណាត់ថ្នាក់ផលិតផល និងគុណភាពឲ្យស្របទៅតាមបទដ្ឋានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ (កំណត់បទដ្ឋាន បង្កើតស្ថាប័នពិនិត្យផ្ទៀងផ្ទាត់ដែលមានការទទួលស្គាល់ជាអន្តរជាតិ ឬ លើកទឹកចិត្តដល់ស្ថាប័នអន្តរជាតិឯករាជ្យ ជាដើម) ។ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល/<br>វិទ្យាស្ថានបទដ្ឋាននៃកម្ពុជា ក្រសួងកសិកម្ម<br>ក្រសួងពាណិជ្ជកម្ម វិស័ឯកជន |
| | លើកទឹកចិត្តដល់ការបង្កើតឃ្លាំងមានដែនកំណត់នៅក្នុងកំពង់ផែភ្នំពេញ | ក្រសួងសាធារណការ និងដឹកជញ្ជូន<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| រយៈពេលមធ្យម/<br>រយៈពេលវែង | បង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រ និងក្របខ័ណ្ឌច្បាប់ ដែលផ្តោតសំខាន់លើ SPS (ច្បាប់ស្តីពី SPS ពាក់ព័ន្ធនឹងអនុក្រឹត្យ និងប្រកាសនានា បង្កើតផ្នែកទទួលបន្ទុកកិច្ចការច្បាស់លាស់ក្នុងចំណោមក្រសួងពាក់ព័ន្ធ ពង្រឹងធនធានមនុស្ស និងធនធានស្ថាប័នជាដើម) ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងពាណិជ្ជកម្ម, ក្រសួងសុខាភិបាល<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| | វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធដើម្បីកាត់បន្ថយថ្លៃចំណាយលើការនាំចេញ (ឧ. ពន្លឿនការជួសជុលផ្លូវរថភ្លើង ភ្នំពេញ-ប៉ោយប៉ែត និង ភ្នំពេញ- ក្រុងព្រះសីហនុ ជាដើម) ។ | ក្រសួងសាធារណការ និងដឹកជញ្ជូន<br>ក្រសួងពាក់ព័ន្ធ |
| | សម្របសម្រួលការធ្វើហិរញ្ញប្បទានសម្រាប់ការនាំចេញ (ពិចារណាលើការបង្កើតធនាគារអាហ័រន-នីហ័រណ) | ក្រសួងពាណិជ្ជកម្ម<br>ធនាគារជាតិនៃកម្ពុជា |
| | សម្របសម្រួលការធ្វើហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ក្រសួងពាណិជ្ជកម្ម<br>ធនាគារជាតិនៃកម្ពុជា |
| **ការងារស្វែងរកទីផ្សារ** | | |
| ជ័យជំនះរហ័ស | រុករកឱកាសសម្រាប់ការនាំចេញនៅក្នុងទីផ្សារ ក្នុងតំបន់ និងទីផ្សារសាកល (ការសិក្សាអំពីទីផ្សារនាំចូលដែលមានសក្តានុពល ដឹកនាំបេសកកម្មទៅរកទីផ្សារដែលមានសក្តានុពល រុករកនៅក្នុងប្រទេសហ្វីលីពីន ឥណ្ឌូណេស៊ី ប្រ៊ុយណេ ។ល។) ។ | ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស<br>និងសហប្រតិបត្តិការអន្តរជាតិ |
| | រិះរកការបង្កើតអង្គភាពទីភ្នាក់ងារទីផ្សារអង្ករ | ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម<br>រុក្ខាប្រមាញ់ និងនេសាទ, វិស័យឯកជន |
| | ពង្រឹងការចែកចាយ និងការត្រួតពិនិត្យតាមដានព័ត៌មានទីផ្សារក្នុងប្រទេស។ | ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម<br>រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធាន ទឹក<br>និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ |
| រយៈពេលមធ្យម/<br>រយៈពេលវែង | រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់វិស័យអង្កររបស់កម្ពុជាដើម្បីប្រកួតប្រជែងក្នុងទីផ្សារក្នុង តំបន់ និងទីផ្សារសាកល (កំណត់វត្ថុបំណង កំណត់ទីផ្សារ ចរចារកិច្ចព្រមព្រៀងទ្វេភាគី ។ល។) ។ | ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស<br>និងសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងពាក់ពព័ន្ធនានា |

***ប្រភព:*** *យោងតាម ឯកសារគោលនយោបាយស្តីពីការលើកកម្ពស់ផលិតកម្មស្រូវ និងការនាំចេញអង្ករ ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ ។*

# ការពង្រីក និងការធ្វើពិពិធកម្ម
# ការនាំចេញផលិតផលសូត្រកម្ពុជា





# ការពង្រីក និងការធ្វើពិពិធកម្ម ការនាំចេញផលិតផលសូត្រកម្ពុជា

## សេចក្ដីសង្ខេប

ក្នុងនាមជាអ្នកផលិតអំបោះ និងក្រណាត់សូត្រដ៏ធំមួយ កម្ពុជាបានមើលឃើញវិស័យនេះជិតសាបសូន្យក្នុងអំឡុងពេលប៉ុន្មានឆ្នាំនៃអស្ថេរភាពសង្គម។ ដោយការចាប់ផ្ដើមឡើងវិញនៅពាក់កណ្ដាលឆ្នាំ ១៩៩០ នោះ ដៃគូអភិវឌ្ឍមួយចំនួនតូចបានផ្ដោតលើជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) លើការខិតខំប្រឹងប្រែងព្យាយាមស្ដារឡើងវិញលើវិស័យនេះ។ តម្រូវការដែលកើនឡើងជាលំដាប់ក្នុងទីផ្សារសាកលលោកសម្រាប់ផលិតផលពាក់ព័ន្ធនឹងសូត្រ (ម៉ូដ ការតុបតែងលម្អគេហដ្ឋាន តម្រូវការផ្សេងៗទៀត) ហើយវិស័យនេះត្រូវបានកំណត់នៅក្នុង *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ ២០០៧* ថាជា វិស័យមួយក្នុងចំណោមវិស័យដែលមានសក្ដានុពលភាពទាំង ១៩ ដើម្បីជួយដល់ការពង្រីក និងការធ្វើពិពិធកម្មលើបរិមាណនាំចេញរបស់ប្រទេស។ លើសពីនេះ ទៀត វិស័យនេះមានឥទ្ធិពលផ្ទាល់និងភ្លាមៗលើការកាត់បន្ថយភាពក្រីក្រនិងលើចំណូល និងការងាររបស់ស្ត្រីជាពិសេស។

បន្តទៀត ការអភិវឌ្ឍបន្តនៃចង្វាក់ផលិតកម្មសូត្រកម្ពុជាអាចនឹងត្រូវការការគ្រប់គ្រងរឹងមាំជាងមុន និងច្បាស់លាស់ជាងមុនរបស់រដ្ឋាភិបាលក្នុងការដាក់ចេញនូវផែនទីបង្ហាញផ្លូវ និងបរិយាកាសគោលនយោបាយសម្រាប់វិស័យនេះដើម្បីជួយឲ្យមានកំណើន និងការពង្រីកបន្ថែម ។

## ១ បញ្ហាដែលបានដោះស្រាយ

ក្នុងនាមជាអ្នកផលិតអំបោះ និងសូត្រតម្បាញដ៏ធំមួយ កម្ពុជាបានមើលឃើញសកម្មភាពពាក់ព័ន្ធ នឹងសូត្ររបស់ខ្លួនមានការអាក់ខានយ៉ាងច្បាស់លាស់ក្នុងអំឡុងឆ្នាំមានភាពចម្រូងចម្រាស។ ត្រឡប់ទៅអំឡុងពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ ដែលមានជំនួយដំបូងពី ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) កម្ពុជាបានចាប់ផ្ដើមស្ដារវិស័យនេះឡើងវិញ ដោយផ្ដោតជាសំខាន់លើកសិដ្ឋានផលិតសូត្រ (ការផលិតសូត្រឆៅ) ការផលិតអំបោះ តម្បាញ និងផលិតកម្មសម្លៀកបំពាក់ម៉ូដ និងក្រមា។ ចាប់តាំងពីឆ្នាំ ២០០៥ បន្ទាប់ពីការបញ្ចប់ជំនួយរបស់បារាំងលើវិស័យនេះ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ជាមួយនឹងមូលនិធិម្ចាស់ជំនួយពហុភាគីបានក្លាយជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់។

ការវិភាគសមាហរណកម្មពាណិជ្ជកម្មដែលបានធ្វើបច្ចុប្បន្នកម្មក្នុងឆ្នាំ ២០០៧ របស់កម្ពុជា ដែលហៅថា *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ ២០០៧ (CTIS 2007)* បានកំណត់ការនាំចេញសូត្រជាវិស័យមួយក្នុងចំណោមវិស័យដែលមានសក្ដានុពលទាំង ១៩ ដោយមានឱកាសសម្រាប់កម្ពុជាក្នុងការធ្វើពិពិធកម្មលើមូលដ្ឋាននៃការនាំចេញបច្ចុប្បន្នរបស់ខ្លួនរួមមានតាមរយៈការបង្កើនចង្វាក់តម្លៃនិងពង្រីកទីផ្សារសម្រាប់ផលិតផល និងភូមិសាស្ត្រទីផ្សារថ្មីៗទៀត[២៦] ។

---

[២៦] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ ២០០៧ ប្រកាសឲ្យប្រើ នៅរាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៧

## ២ គោលដៅដែលត្រូវបន្ត

សកម្មភាពការងារពាក់ព័ន្ធនឹងសូត្រ គឺជាការងារដែលត្រូវការកម្លាំងពលកម្មច្រើនដែលភាគច្រើនជាស្ត្រីរស់នៅតាមទីជនបទហើយការងារនេះមានឥទ្ធិពលកម្រិតខ្ពស់និងដោយផ្ទាល់ទៅលើការកាត់បន្ថយភាពក្រីក្រ។ ឧទាហរណ៍ការផលិតស្រូវក្នុង១ហិកតាផ្តល់ប្រាក់ចំណូលចន្លោះពី ៥០០ - ៦០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំសម្រាប់កសិករម្នាក់ នោះការដាំដើមមន ១ ហិកតា ស្មើគ្នា សម្រាប់ចិញ្ចឹមដង្កូវនាងនឹងផ្តល់ចំណូលបានប្រហែល ២០០០ ដុល្លារអាមេរិកសម្រាប់កសិករម្នាក់ ។

ផលិតផលសម្រេចធ្វើពីសូត្រ ដូចជាសម្លៀកបំពាក់  សម្ភារៈលម្អគេហដ្ឋាន ក្រមា កន្សែងផ្សេងៗគឺមានតម្រូវការខ្ពស់ទាំងសម្រាប់ការនាំចេញផ្ទាល់ ឬ ការទិញពីសំណាក់ភ្ញៀវទេសចរបរទេស។

គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ចំពោះវិស័យសូត្រ គឺធ្វើការអភិវឌ្ឍឡើងវិញនូវខ្សែចង្វាក់តម្លៃដើម្បីពង្រីក និងធ្វើពិពិធកម្មដល់ការនាំចេញរបស់ខ្លួន កាត់បន្ថយភាពក្រីក្រ និងផ្តល់ផលចំណេញដល់ស្ត្រី។

## ៣ បញ្ហាប្រឈមដែលជួបប្រទះ និងកត្តាឈានទៅរកជោគជ័យ

### ៣.១ ការអភិវឌ្ឍសមត្ថភាពផ្នែកខ្សែចង្វាក់តម្លៃ

ខ្សែចង្វាក់តម្លៃសូត្ររបស់កម្ពុជា រួមមានវិស័យរងចំនួន ៣ សំខាន់ៗ៖ កសិដ្ឋានផលិតដើមមន ចិញ្ចឹមដង្កូវនាង និងការផលិតអំបោះសូត្រ តម្បាញ និងការអភិវឌ្ឍផលិតផលសម្រេច និងការបង្កើតទីផ្សារ ។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៥០ កម្ពុជាផលិតសូត្របានចំនួនច្រើន គឺអំបោះ ៥០ តោន ក្នុងមួយឆ្នាំពីកសិដ្ឋានផលិតសូត្ររបស់ខ្លួន។ បច្ចុប្បន្ននេះ ការផលិតនេះមានប្រហែលជា ៥ តោន ក្នុងមួយឆ្នាំ ដែលមានអ្នកចិញ្ចឹមដង្កូវនាង ១ ៣០០ នាក់ និងដើមមនក្នុងផ្ទៃដី ១៦០ ហិកតា។ ផលិតកម្មនេះមានការកើនឡើងបន្តិចនៅពេលចុងបញ្ចប់នៃជំនួយប្រទេសបារាំងក្នុងឆ្នាំ ២០០៥ (ផលិតបាន ៧ តោន លើផ្ទៃដី ២៣០ ហិកតា) ប៉ុន្តែចំនួននេះបានធ្លាក់ចុះវិញបន្តិចចាប់ពីពេលនោះមក ដោយសារតែមានជំងឺជាអន្លើរៗ។ គម្រោងរយៈពេល ២ ឆ្នាំ មួយរបស់អង្គការ FAO បានចាប់ផ្តើមនាចុងឆ្នាំ២០០៩ និងផ្តោតលើការផលិតពងដង្កូវនាង ការគ្រប់គ្រងជំងឺ និងការដាំដើមមន (មនត្រូវបានដាំជាដើមទាបៗ ហើយវាអាចចាប់ផ្តើមការផលិតក្នុងអំឡុងពេល ៨ខែក្រោយពីដាំ)។គោលដៅគឺប្រអប់ដាក់ដង្កូវនាងដែលគ្មានជំងឺចំនួន៥០០០ប្រអប់ក្នុងមួយឆ្នាំ។កសិដ្ឋានគំរូចំនួន ៧ នឹងត្រូវបានបង្កើតឡើងដើម្បីបង្រៀនបច្ចេកទេសក្នុងការចិញ្ចឹមដង្កូវនាង និងការហូតសូត្រ។

ការដាំ និងការផលិតអំបោះសូត្រមានចំនួនច្រើននៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។ ឧបសគ្គចម្បងមួយចំនួនរារាំងដល់ការពង្រីកឲ្យកាន់តែលឿននូវការផលិតតាមផ្ទះនោះ គឺកង្វះដីដែលធំល្មម (ដែលជាមធ្យមក្នុងពេលបច្ចុប្បន្ននេះគឺ ០,១៥ ហិកតា) និងតម្រូវការក្នុងការបង្កើនការហូតសូត្រដើម្បីផលិតជាអំបោះដោយត្រូវបម្លែងទៅជារោងចក្រហូតសូត្រ (ការហូតសូត្រពេលបច្ចុប្បន្ននេះ គឺធ្វើឡើងដោយកសិករខ្លួនឯងផ្ទាល់ដែលនាំឲ្យមានគុណភាពមិនដូចគ្នា)។

សូត្រប្រហែលជា ៤០០ តោន ត្រូវបាននាំចូលជារៀងរាល់ឆ្នាំ។ ក្រណាត់ប្រហែលជា ២,៣ ទៅ ២,៤ លាន ម៉ែត្រការ៉េ ត្រូវបានផលិត និងប្រើប្រាស់ជារៀងរាល់ឆ្នាំ។ ការនាំចូលសូត្រមានការធ្លាក់ចុះមកនៅត្រឹម ៣០០ តោន ក្នុងឆ្នាំ ២០០៩ ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុប៉ុន្តែចំនួននេះបានកើនឡើងវិញចាប់ពីឆ្នាំនោះមក[២៧]។ ហានិភ័យដែលពាក់ព័ន្ធនឹងការនាំចូលនោះ គឺការឡើងចុះយ៉ាងខ្លាំងនៃតម្លៃដែលនេះអាចនឹងធ្វើឲ្យប្រាក់ចំណេញរបស់អ្នកតម្បាញមានការធ្លាក់ចុះ។ អ្នកតម្បាញ និងអ្នកចិញ្ចឹមដង្កូវនាងត្រូវបានរៀបចំជាសមាគម ដែលសមាគមធំជាងគេគឺ សមាគភូមិសូត្រខ្មែរដែលប្រមូលផ្តុំអ្នកចិញ្ចឹមដង្កូវនាងប្រហែលជា ៧០០ នាក់ នៅតំបន់ពាយ័ព្យ និង ៨០០ នៅតំបន់ភាគខាងត្បូងប្រទេស។

វាខុសពីផលិតកម្មនៅក្នុងតំបន់ពាយ័ព្យ ការតម្បាញភាគច្រើនគឺផ្អែកទៅលើភាគខាងត្បូងប្រទេស (ដែលមានអ្នកតម្បាញប្រហែលជា ២០០០០នាក់) និងចំនួនមានកម្រិតនៅភាគខាងជើង (ដែលមានអ្នកតម្បាញប្រហែលជា៣០០នាក់) សូមមើលតារាងទី១។ ជាការចាប់អារម្មណ៍តម្បាញគឺជាសកម្មភាពមួយដែលអនុវត្តដោយស្ត្រី។ជាការពិតណាស់ដោយសារតែផលិតកម្មសូត្រនៅតែមានកម្រិតតិចតួចខ្លាំងកម្ពុជាបានក្លាយជាប្រទេសដែលនាំសូត្រចូលដ៏ធំមួយពីប្រទេស វៀតណាម ចិន និងអ៊ុយបេគីស្ថាន។

[២៧] ការសែត ភ្នំពេញប៉ុស្ត៍ "ការនាំចូលសូត្រ ចាប់ផ្តើមហូរចូល ខណៈវិស័យនេះទទួលរងពីវិបត្តិ" ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០៩។

ដើម្បីធ្វើឲ្យមានអនុភាពដល់វិស័យតម្បាញ គម្រោងមួយរបស់ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិបាននឹងកំពុងព្យាយាមធ្វើការណែនាំអំពីបទដ្ឋានសូត្រមាសខ្មែរ (CGS) និង យីហោរួមផ្អែកលើបទដ្ឋានបច្ចេកទេសដែលត្រូវបានកំណត់យ៉ាងល្អ និងបទដ្ឋានពាណិជ្ជកម្មស្មើភាពគ្នា និងមានទិសដៅជួយដល់ការបង្កើតយីហោផលិតផលសូត្ររបស់កម្ពុជានៅលើទីផ្សារសកលលោក។

វិស័យរងសំខាន់ទី ៣ នៃខ្សែចង្វាក់តម្លៃសូត្រ គឺការបង្កើតផលិតផល និងការបង្កើតទីផ្សារ។ លើកលែងតែសិប្បកម្មធំមួយគឺសប្បកម្ម សិប្បករអង្គរ (Artisansd Angkor) (ទាំងជាអ្នកត្បាញផង និងអ្នកផលិតផង/អ្នកលក់រាយផលិតផលសម្រេច) ក្រៅពីនេះ វិស័យនេះត្រូវបានគ្របដណ្តប់ភាគច្រើនដោយផលិតករតូចតាច អ្នកលក់រាយ អង្គការមិនមែនរដ្ឋាភិបាល ដែលមានការប្រមូលផ្តុំគ្នាមិនបានល្អក្រោមការគ្រប់គ្រងរបស់អង្គការទាំងនេះ មានសមាគមសិប្បករកម្ពុជា វេទិកាសូត្រកម្ពុជា បណ្តាញសិប្បករកម្ពុជា និងអង្គការផ្សេងៗទៀត។ សិប្បករអង្គរ គឺជាសហគ្រាសរដ្ឋ-ឯកជនមួយដែល ៣០% ជាចំណែករបស់រដ្ឋាភិបាល ៣០% ជាចំណែករបស់ក្រុមហ៊ុន SCA (ក្រុមហ៊ុនប្រទេសបារាំង ប្រតិបត្តិករអាកាសយានដ្ឋានដ៏ធំរបស់កម្ពុជា) ហើយ ៤០% ទៀតគឺជារបស់សមាគមសិប្បករ។ ចំនួននៃអ្នកប្រតិបត្តិការនៅក្នុងវិស័យនេះមានការកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែចំនួននេះមានទំហំតូចណាស់ និងមានកម្រិតក្នុងការទទួលបានព័ត៌មានពីទីផ្សារ និងចំណេះដឹងមានក្រិតអំពីទីផ្សារអន្តរជាតិ លើកលែងតែចំពោះភ្ញៀវទេសចរ។ វិស័យរងនេះក៏ត្រូវការការលើកកម្ពស់ជំនាញក្នុងផ្នែករចនាផលិតផល ការបង្កើតផលិតផល និងការយល់អំពីតម្រូវការផលិតផលនៅក្នុងទីផ្សារនាំចេញដែលមានសក្តានុពល។

## ៣.២ ការសម្របសម្រួលរាជរដ្ឋាភិបាល-វិស័យឯកជន

ភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាលនៅក្នុងការបង្កើតវិស័យនេះត្រូវបានកំណត់រហូតមកដល់ពេលបច្ចុប្បន្ននេះ។

កិច្ចខិតខំប្រឹងប្រែងពីដំបូងបានធ្វើឡើងភាគច្រើនបំផុតដោយអ្នកផ្តល់ជំនួយហើយមានបំណងផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍវិស័យនេះដែលដឹកនាំដោយវិស័យឯកជន។ ប៉ុន្តែ កិច្ចការនេះមិនទំនងជាមានភាពគ្រប់គ្រាន់ ដើម្បីជំរុញការអភិវឌ្ឍពេញលេញនូវចង្វាក់តម្លៃសូត្ររបស់ប្រទេសកម្ពុជាដែលកំពុងឈានទៅមុខនោះនៅឡើយទេ។ រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដាក់ចេញនូវគោលនយោបាយ និងបរិយាកាសបង្កលទ្ធភាពដល់វិស័យពាណិជ្ជកម្មសម្រាប់វិស័យនេះ និងជាអ្វីមួយដែលវិស័យឯកជនមិនអាចធ្វើតែឯងបានឡើយ។

ការគាំទ្ររបស់ម្ចាស់ជំនួយពហុភាគីនៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៦ និងអនុវត្តដោយក្រសួងពាណិជ្ជកម្ម (MoC) បានធ្វើការងារជាមួយក្រសួងនេះ នៅដំណាក់កាលដំបូងដើម្បីបង្កើតយុទ្ធសាស្ត្រគ្របដណ្តប់លើវិស័យសូត្ររបស់កម្ពុជា។[២៨] នៅពេលបច្ចុប្បន្នគម្រោងនេះកំពុងផ្តោតលើការព្យាយាមដើម្បីបង្កើតយន្តការស្ថាប័ន "ក្រុមប្រឹក្សាភិបាលសូត្រ" ដើម្បីប្រមូលផ្តុំអ្នកដើរតួសំខាន់ៗទាំងអស់។ ក្រុមប្រឹក្សាភិបាលដែលបានស្នើសុំនេះ គឺដើម្បីបញ្ចូលមិនត្រឹមតែអង្គការតំណាងវិស័យឯកជន (អង្គការភូមិសូត្រខ្មែរសមាគមសិប្បករអង្គការផ្សេងៗទៀត)ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រសួងតាមខ្សែបណ្តោយសំខាន់ៗក៏ស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម(MoC) ដែរដូចជាក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ (MAFF) ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល(MIME) ក្រសួងកិច្ចការនារី (MoWA) ជាដើម។ គោលបំណងនេះ គឺដើម្បីឲ្យក្រុមប្រឹក្សាភិបាលសូត្រអាចផ្តល់ជាកម្លាំងរុញច្រាន និងទស្សនៈនានាអំពីវិធីសាស្រ្តផ្សេងៗ ដែលរដ្ឋាភិបាលអាចបង្កើតបរិយាកាសគាំទ្រ និងបង្កលទ្ធភាពសម្រាបការអភិវឌ្ឍកាន់តែឆាប់រហ័ស។ ល័ក្ខខ័ណ្ឌប្រតិបត្តិសម្រាប់ក្រុមប្រឹក្សាសូត្រកំពុងតែធ្វើសេចក្តីព្រាង។

## ៣.៣ ជំនួយសម្រាប់ពាណិជ្ជកម្ម

ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ដល់ពាក់កណ្តាលឆ្នាំ ២០០០ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) គឺជាដៃគូអភិវឌ្ឍន៍ដំបូងសម្រាប់វិស័យនេះតាមរយៈកម្មវិធី PRESNOC របស់ខ្លួន (១៩៩៥-១៩៩៨ ពង្រីកដល់ឆ្នាំ ២០០១) អនុវត្តតាមក្រោយដោយកម្មវិធី PASS (២០០២-២០០៥) របស់ខ្លួន។ នៅក្នុងឆ្នាំ ២០០៦ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) បានពង្រាយជំនួយហិរញ្ញប្បទានពី NZAid, SECO និង UNDP-TRADE[២៩] ។ នៅពេលថ្មីៗនេះ អង្គការស្បៀង និងកសិកម្ម (FAO) បានចាប់ផ្តើមផ្តល់ជំនួយដែលផ្តោតលើការចិញ្ចឹមដង្កូវនាង។ រដ្ឋាភិបាលប្រទេសបែលហ្សិកកំពុងរៀបចំផែនការផ្តល់ជំនួយដើម្បីពង្រឹងសមត្ថភាពផលិតកម្មអំបោះសូត្រក្នុងស្រុកនៅស្រុកភ្នំស្រុក។

[២៨] ITC, អភិក្រមគ្របដណ្តប់លើវិស័យ សម្រាប់វិស័យសូត្រកម្ពុជា ខែមីនា ឆ្នាំ ២០០៦

[២៩] UNDP-TRADE តំណាងឲ្យគម្រោង "ជំនួយពាក់ព័ន្ធនឹងពាណិជ្ជកម្មសម្រាប់ការអភិវឌ្ឍ និងសមភាព" របស់ UNDP

### ៣.៤ ការកាត់បន្ថយកត្តាខាងក្រៅ

ការអភិវឌ្ឍកាន់តែឆាប់រហ័សនូវវិស័យនេះអាចនឹងទាមទារឲ្យមានការប្តេជ្ញាចិត្តប្រកបដោយឆន្ទៈថែមទៀតលើធនធានស្ថាប័ន និងហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជា។ ប៉ុន្តែនៅក្នុងរយៈពេលដ៏ខ្លីនេះទំនងជាមានតម្រូវការជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) បន្ថែមដើម្បីបន្តវិនិយោគនៅពេលអនាគតក្នុងរយៈពេលយូរអង្វែងលើវិស័យនេះ។ ដើម្បីកៀងគរជំនួយសម្រាប់កសិកម្ម (AfT) ថ្មី គឺអាចនឹងត្រូវការការប្តេជ្ញាចិត្តច្បាស់លាស់បន្ថែម និងការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការដាក់ចេញនូវផែនទីបង្ហាញផ្លូវសម្រាប់វិស័យនេះអាចក្នុងទម្រង់ដែលបានកំណត់ក្រោមជំនួយរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ដែលអនុវត្តដោយក្រសួងពាណិជ្ជកម្ម (MoC) នាពេលបច្ចុប្បន្ន។

## ៤ លទ្ធផលសម្រេចបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន

ទិន្នផលសរុបនៃវិស័យនេះ គឺប្រហែល ៥០ លានដុល្លារ ដែលក្នុងនោះ ប្រាក់ប្រហែល ២៥ លានដុល្លារ សម្រាប់ចំណាយលើការនាំចូលអំបោះសូត្រ។ ម៉្យាងទៀត តម្លៃបន្ថែមនៃវិស័យនេះ គឺប្រហែល២៥លានដុល្លារ។ ការនាំចេញផលិតផលសូត្រប៉ាន់ស្មានដែលបានស្នើសុំក្នុងឆ្នាំ២០០៩ គឺមានតម្លៃប្រហែលពី ៣,៥ទៅ៤ លានដុល្លារ។ ការប្រែប្រួលដ៏ឆាប់រហ័សនូវផលិតកម្មក្នុងស្រុកសម្រាប់ការនាំចេញអំបោះសូត្រនាពេលបច្ចុប្បន្នអាចបង្កើតការងារបន្ថែមពី ២០ ០០០ ទៅ ២៥ ០០០ កើនការងារដល់ពី ២២ ០០០ ទៅដល់ ២៥ ០០០ នាពេលបច្ចុប្បន្ននៅក្នុងវិស័យនេះ។

ការងារភាគច្រើនបំផុតដែលបានបង្កើតឡើងនៅក្នុងវិស័យសូត្របានផ្តល់ផលប្រយោជន៍ដល់ស្ត្រី និងផ្តោតលើតំបន់ដែលមានភាពក្រីក្រខ្លាំង និងត្រូវការបង្កើតការងារដែលបង្កើតឲ្យមានចំណូល។

## ៥ បទពិសោធន៍ដែលទទួលបាន

រហូតមកដល់បច្ចុប្បន្ន ការអភិវឌ្ឍឡើងវិញនូវវិស័យសូត្រនៅក្នុងប្រទេសកម្ពុជា ជាវិស័យឯកជន និងកិច្ចខិតខំប្រឹងប្រែងធ្វើឡើយដោយអ្នកផ្តល់ជំនួយស្ទើរតែទាំងស្រុង។ បំណងពីដំបូងបំផុត គឺដើម្បីជំរុញវិស័យនេះដែលជាសំខាន់តាមរយៈការផ្តួចផ្តើមគំនិតរបស់វិស័យឯកជន ដូចជាវេទិកាស្តីពីសូត្រកម្ពុជា ឬ the CraftNetwork-Cambodia ដែលវាអាចជួយបានយ៉ាងច្រើន ប៉ុន្តែនៅមានកម្រិតនៅឡើយ។ វាជាការចាំបាច់ដែលត្រូវបង្កើតភាពជាដៃគូររដ្ឋ-វិស័យឯកជន ដើម្បីដោះស្រាយបញ្ហាដែលប្រឈមចំពោះវិស័យនេះ និងពង្រឹងការរីកចម្រើនដែលបានធ្វើកន្លងមក។ ការបង្កើតឡើងនូវក្រុមប្រឹក្សាអភិបាលសូត្រដែលបានស្នើឡើង គឺដើម្បីដោះស្រាយគម្លាតនៅក្នុងស្ថាប័ននេះ។

បន្ថែមទៅលើការបង្កើតយន្តការសមស្របសម្រាប់ភាពជាដៃគូរដ្ឋឯកជនក្នុងវិស័យសូត្រ មានការចាំបាច់សម្រាប់រដ្ឋាភិបាលដែលត្រូវផ្តល់ក្របខ័ណ្ឌគោលនយោបាយសម្រាប់វិស័យនេះ និងផែនទីបង្ហាញផ្លូវសម្រាប់ដៃគូផ្សេងៗគ្នា ដើម្បីរួមចំណែកដល់ភាពជោគជ័យនៃគោលនយោបាយនេះ។ "យុទ្ធសាស្ត្រគ្របដណ្តប់លើវិស័យសូត្ររបស់ប្រទេសកម្ពុជា" ឆ្នាំ ២០០៦ អាចផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់កិច្ចខិតខំប្រឹងប្រែងនោះ ប៉ុន្តែចុងក្រោយ វាត្រូវតែជាគោលនយោបាយដែលបានបង្កើតឡើង និងឯកភាពដោយរដ្ឋាភិបាល មិនមែនជាយុទ្ធសាស្ត្រជំរុញអ្នកផ្តល់ជំនួយនោះឡើយ។ ឯកសារគោលនយោបាយនាពេលថ្មីៗនេះរបស់រដ្ឋាភិបាលស្តីពីការនាំចេញអង្ករអាចនឹងផ្តល់នូវមធ្យោបាយ និងការណែនាំដ៏មានប្រយោជន៍យ៉ាងខ្លាំងសម្រាប់អ្វីដែលអាចនឹងត្រូវការឲ្យកើតឡើងនៅក្នុងវិស័យសូត្រ។[៣០]

ជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) ទៅដល់វិស័យសូត្ររបស់ប្រទេសកម្ពុជា គឺជាឧទាហរណ៍ដ៏ល្អដែលបង្ហាញពីវិធីដែលជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) អាចផ្តោតគោលដៅដោយផ្ទាល់លើក្រុមជនក្រីក្រ និងនាំមកនូវផលប្រយោជន៍ក្នុងការកាត់បន្ថយភាពក្រីក្រភ្លាមៗ បន្ថែមទៅលើការទទួលបានផ្នែកពាណិជ្ជកម្ម។

[៣០] រាជរដ្ឋាភិបាលកម្ពុជា ឯកសារគោលនយោបាតស្តីពីការលើកម្ពស់ផលិតកម្មស្រូវ និងការនាំចេញអង្ករ អនុម័តដោយដោយគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០

**តារាង ១** ៖ ចំនួន និងទីតាំងរបស់អ្នកតម្បាញសូត្រនៅប្រទេសកម្ពុជា ឆ្នាំ ២០១០

| តំបន់ | # អ្នកតម្បាញ | ឯកទេស |
|---|---|---|
| ខេត្តតាកែវ | ១២ ៥៨៤ | ហូល (៨៦%), ក្រណាត់លាត (៨%), ក្រម៉ា (៦%) |
| ខេត្តកណ្ដាល | ៤ ៥១៣ | ផាមួង, ចរល្បាប់, ល្បើក |
| ខេត្តកំពង់ចាម | ៧៧០ | ហូល (៩៥%) |
| ខេត្តព្រៃវែង | ២ ០៣៧ | ក្រណាត់លាត/Organza (៨៣%), ក្រម៉ា (១៧%) |
| តំបន់ពាយ័ព្យ | ៣២១ | ក្រណាត់លាត, ភួយ, ក្រម៉ា (៧០%) |
| សរុប | ២០ ២២៥ | |

*ប្រភព : ភូមិសូត្រខ្មែរ (ខែមេសា ឆ្នាំ២០១០)*



# ការកសាងសមត្ថភាពសម្រាប់ខ្សែចង្វាក់តម្លៃ នៃការនាំចេញ និងព័ត៌មានអំពីពាណិជ្ជកម្ម នៅប្រទេសកម្ពុជា



# ការកសាងសមត្ថភាពសម្រាប់ខ្សែសង្វាក់តម្លៃនៃការនាំចេញ និងព័ត៌មានអំពីពាណិជ្ជកម្មនៅប្រទេសកម្ពុជា

## សេចក្តីសង្ខេប


លទ្ធផលនៃការរៀបចំយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០០៧ (CTIS 2007) គឺដើម្បីបង្ហាញពីតម្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យនៃការស្រាវជ្រាវអំពីខ្សែចង្វាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្មនៅក្នុងរដ្ឋាភិបាល។ សសរសស្តម្ភទី ២ នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ដែលបានចាប់ផ្តើមអនុវត្តន៍នៅដើមឆ្នាំ ២០០៨ មានទំនួលខុសត្រូវក្នុងការសម្របសម្រួលការងារ ស្តីពីការនាំចេញខ្សែចង្វាក់នៃការនាំចេញនៅក្នុងវិស័យសក្តានុពលសម្រាប់នាំចេញទាំង ១៩ ដែលបានកំណត់នៅក្នុង CTIS ឆ្នាំ ២០០៧។ សសរសស្តម្ភទី ២ បានកំណត់ជាដំបូងលើតម្រូវការដើម្បីបង្កើតអង្គភាពខ្សែចង្វាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្ម (VCU) នៅក្នុងក្រសួងពាណិជ្ជកម្ម (MoC) ដើម្បីចាប់ផ្តើមអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងស្រាវជ្រាវព័ត៌មាន។

ជាមួយនឹងការចាប់ផ្តើមបង្កើតអង្គភាពខ្សែចង្វាកតម្លៃ (VCU) នៅក្នុងឆ្នាំ ២០០៩ និងការផ្លាស់ប្តូរនៃជំនួយរបស់ម្ចាស់ជំនួយនៅក្នុងឆ្នាំ ២០១១ វាជាការឆាប់រហ័សពេកដែលត្រូវកំណត់ផលប៉ះពាល់ជាក់លាក់ ឬមួយបង្រៀនរឹងមាំនោះ។ ប៉ុន្តែតាមវិស័យជាច្រើនបំផុត គឺគេត្រូវការសមត្ថភាពនោះជាចាំបាច់ព្រោះថាវាអាចផ្តល់ផលប្រយោជន៍ដល់វិស័យឯកជនក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការនាំចេញរបស់ខ្លួនដោយក្នុងនោះរដ្ឋាភិបាល ត្រូវចូលរួមក្នុងកិច្ចពិភាក្សាមួយចំនួនក្នុងចំណោមកិច្ចពិភាក្សានានារបស់ខ្លួនជាមួយនឹងដៃគូអភិវឌ្ឍន៍អំពីជំនួយសម្រាប់ពាណិជ្ជកម្ម(AfT) រដ្ឋាភិបាលចូលរួមក្នុងការធ្វើគោលនយោបាយផ្អែកលើវិស័យ ឬរដ្ឋាភិបាល វិស័យឯកជននិងដៃគូអភិវឌ្ឍន៍នានាក្នុងការត្រួតពិនិត្យលើការរីកចម្រើនរបស់ខ្លួនស្ថិតក្រោមអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម(Trade SWAp)។


## ១ បញ្ហាដែលបានដោះស្រាយ

នៅក្នុងឆ្នាំ ២០០៦-២០០៧ រាជរដ្ឋាភិបាលកម្ពុជា (RGC) ស្ថិតក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម (MoC) បានដំណើរការធ្វើបច្ចុប្បន្នភាពកម្មវិធីពង្រឹងសមត្ថភាពសមាហរណកម្មពាណិជ្ជកម្មឆ្នាំ ២០០១ របស់ខ្លួន។ លទ្ធផល គឺការរៀបចំ *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០០៧ (ដែលគេហៅថា CTIS ២០០៧)* ដែលបានឯកភាពដោយអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម នៅក្នុងខែមីនា ឆ្នាំ ២០០៧ និងអនុម័តដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៅក្នុងខែធ្នូ ឆ្នាំ២០០៧។

យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ ( CTIS 2007) បានកំណត់ និងផ្តល់ ការស្រាវជ្រាវដំបូងលើវិស័យប្រកបដោយសក្តានុពលទាំង ១៩ ដែលអាចធ្វើជាមូលដ្ឋានសម្រាប់ការពង្រីក និងការធ្វើពិពិធកម្ម លើមូលដ្ឋាននៃការនាំចេញរបស់ប្រទេសកម្ពុជា។ ទិសដៅនៃកិច្ចខិតខំប្រឹងប្រែងនោះ គឺដើម្បីបង្ហាញពីតម្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងផ្នែកនៃការស្រាវជ្រាវអំពីខ្សែចង្វាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្មនៅក្នុងរដ្ឋាភិបាល និងវិធីសាស្ត្រតូចៗឈានទៅរកការស្រាវជ្រាវខ្សែចង្វាក់តម្លៃដោយដៃគូអភិវឌ្ឍន៍រហូតដល់ចំណុចដែលត្រូវការ។

## ២ គោលដៅដែលត្រូវបន្ត

បន្ទាប់ពីការអនុវត្ត *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ ( CTIS 2007)* និង អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ខ្លួនឯង (ខែមករា ឆ្នាំ ២០០៨ ) អនុគណៈកម្មាធិការការអភិវឌ្ឍពាណិជ្ជកម្ម និងការវិនិយោគទាក់ទងនិងពាណិជ្ជកម្ម បានកំណត់"សសរសស្តម្ភ" ចំនួន ៣ ដើម្បីគាំទ្រដល់ការអនុវត្តអភិក្រមគ្របដណ្តប់លើវិស័យ ពាណិជ្ជកម្ម (Trade SWAp) និងសម្រប

សម្រួលជំនួយរបស់ដៃគូអភិវឌ្ឍន៍ដែលឈានឆ្ពោះទៅមុខជាមួយនឹងសសរស្តម្ភទី ២ ដែលផ្តោតលើខ្សែចង្វាក់តម្លៃនៃការនាំចេញ។ ចាប់ពីដំបូងមក សសរស្តម្ភទី ២ បានអភិវឌ្ឍសមត្ថភាពស្រាវជ្រាវខ្សែចង្វាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្មនៅក្នុងរដ្ឋាភិបាលដែលជាវត្ថុបំណងមួយក្នុងចំណោមវត្ថុបំណងសំខាន់ៗរបស់ខ្លួន ដោយផ្តោតលើការបង្កើតអង្គភាពខ្សែចង្វាក់តម្លៃ (VCU) នៅក្នុងក្រសួងពាណិជ្ជកម្ម (MoC)។[៣១]

## ៣ បញ្ហាប្រឈម និងកត្តាឈានទៅរកជោគជ័យ

### ៣.១ សាវតារបន្ថែម

ក្នុងខណៈពេលអនុវត្តការងារលើ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ ( CTIS 2007) និងកំពុងដាក់ឲ្យអនុវត្តន៍អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) កំពុងមានការរីកចម្រើននោះ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) ដោយមានជំនួយគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានរៀបចំកិច្ចប្រជុំមួយសម្រាប់ដៃគូ អភិវឌ្ឍន៍ដែលធ្វើការងារនៅក្នុងផ្នែកខ្សែចង្វាក់តម្លៃនៅខែកញ្ញាឆ្នាំ២០០៧។ ដោយឡែកការសិក្សាមួយត្រូវបានរៀបចំឡើងដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) ហើយបានទទួលអនុសាសន៍មួយចំនួនពីការសិក្សានោះ និងពីសិក្ខាសាលា។[៣២] អនុសាសន៍សំខាន់ៗពីសកម្មភាពខ្សែចង្វាក់តម្លៃរបស់ដៃគូអភិវឌ្ឍន៍របស់ប្រទេសកម្ពុជានិងការសិក្សាអំពីការសម្របសម្រួល រួមមាន ៖

១.ការបង្កើតលេខាធិការដ្ឋានខ្សែចង្វាក់តម្លៃដែលមានទាំងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកតំណាងវិស័យឯកជន ហើយវានឹងជួយក្នុងការកំណត់ពីតម្រូវការ និងសម្របសម្រួលជំនួយអភិវឌ្ឍន៍លើវិស័យនាំចេញ ដែលមានសក្តានុពលជាអាទិភាពដូចបានកំណត់ក្នុងយុទ្ធសាស្ត្រធ្វើសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ ( CTIS 2007)។
២.លេខាធិការដ្ឋាននេះនឹងដើរតួជាឃ្លាំងស្តុកខ្សែចង្វាក់តម្លៃ និងព័ត៌មានតាមវិស័យ
៣.ការបង្កើតក្រុមការងារតាមវិស័យដែលរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកតំណាងវិស័យឯកជននឹងធ្វើការងារជាមួយគ្នាលើវិស័យអាទិភាពនានា។

ជាលទ្ធផល ដោយសារតែមិនសូវអនុវត្តតាមទម្រង់ដើមដែលបានលើកឡើងនៅក្នុងលទ្ធផលនៃសិក្ខាសាលា ទើបធ្វើឲ្យអនុសាសន៍ទាំង ៣ ស្ថិតនៅក្នុងដំណាក់កាលផ្សេងៗនៃការអនុវត្ត។ សសរស្តម្ភទី២នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ស្ថិតក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម មានបំណងធ្វើជាអ្នកសម្របសម្រួល និងជាអ្នកដឹកនាំសកម្មភាពខ្សែចង្វាក់តម្លៃនៅក្នុងវិស័យនាំចេញជាអាទិភាព។សសរស្តម្ភទី២បានរៀបចំក្រុមការងារមួយចំនួនដែលភាគច្រើនជាក្រុមការងារផ្នែកវិស័យនាំចេញដែលមានអាណត្តិប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលសិក្ខាកាមបានលើកឡើងនៅក្នុងសិក្ខាសាលារៀបចំឡើងដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) នៅខែកញ្ញា ឆ្នាំ២០០៧។ មិនតែប៉ុណ្ណោះ វិធានការដំបូងមួយចំនួនត្រូវបានអនុវត្តដើម្បីបង្កើតអង្គភាពខ្សែចង្វាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្មនៅក្នុងនាយកដ្ឋានជំរុញពាណិជ្ជកម្ម (TPD) របស់ក្រសួងពាណិជ្ជកម្ម (MoC)។

ករណីសិក្សានេះ មិនគ្របដណ្តប់លើការអភិវឌ្ឍទាំង ៣ ឡើយទោះបីជាវាមានទំនាក់ទំនងជាមួយគ្នាក៏ដោយ ក៏ប៉ុន្តែវាផ្តោតតិចតួចប៉ុណ្ណោះទៅលើអង្គភាពខ្សែចង្វាក់តម្លៃ។

### ៣.២ ការអភិវឌ្ឍសមត្ថភាពដំបូងសម្រាប់ចង្វាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្មនៅក្នុងរដ្ឋាភិបាល

ជាមួយនឹងជំនួយគាំទ្រដំបូងពីគម្រោងពាណិជ្ជមក្ខរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីប្រឹក្សាម្នាក់ត្រូវបានជ្រើសរើសនៅក្នុងខែកញ្ញា ឆ្នាំ២០០៩ ដើម្បីជួយដល់ការអភិវឌ្ឍសមត្ថភាពនៅក្នុងការិយាល័យមួយក្នុងចំណោមការិយាល័យនានារបស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម (TPD)។ គោលដៅដំបូងនៃការគាំទ្រ គឺទៅលើ ៤ ផ្នែក ៖

១. អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងវិភាគក្នុងចំណោមបុគ្គលិកដែលឈ្លាសវៃដើម្បីរៀបចំការសិក្សាអំពីចង្វាក់តម្លៃតាមវិស័យ ដូចជា ការសិក្សាអំពីការប្រើប្រាស់ឧបករណ៍មូលដ្ឋាន (ការវិភាគ SWOT ការប្រើប្រាស់ និងការរៀបចំទិន្នន័យពាណិជ្ជកម្មមូលដ្ឋាន ការប្រើប្រាស់ឧបករណ៍ព័ត៌មានមូលដ្ឋាន ដូចជាផែនទីពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) និងបច្ចេកទេសស្ទង់មតិតាមផ្នែកជាដើម)។

[៣១]ការអភិវឌ្ឍច្រវាក់តម្លៃ និងព័ត៌មានអំពីពាណិជ្ជកម្ម លទ្ធផលទី ១ នៅក្នុងផែនទីបង្ហាញផ្លូវនៃសសរស្តម្ភទី ២ កំពុងបញ្ចប់ (សេចក្តីព្រាង ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១)
[៣២]USAID, សកម្មភាពច្រវាក់តម្លៃ និងការសិក្សាអំពីការសម្របសម្រួល នៅរាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៧

២. រៀបចំការសិក្សាអំពីខ្សែចង្វាក់តម្លៃតាមវិស័យដែលបានជ្រើសរើស ដោយផ្តោតជាដំបូងទៅលើវិស័យជាអាទិភាពទាំង ១៩ ដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៧ (CTIS 2007)*

៣. ផ្សព្វផ្សាយព័ត៌មានមួយចំនួនក្នុងចំណោមព័ត៌មានទាំងឡាយក្នុងទម្រង់ជាគេហទំព័រសៀវភៅបោះពុម្ព ការបណ្តុះបណ្តាលមន្ត្រីវិស័យឯកជន និងមន្ត្រីរដ្ឋាភិបាលនៅតាមខេត្ត ជាដើម។ ចែករំលែក និងផ្តល់សុពលភាពដល់ការសិក្សាអំពីខ្សែសង្វាក់តម្លៃជាមួយនឹងក្រុមការងារសសរស្តម្ភទី ២ តាមវិស័យសមស្រប។

៤. បង្កើតបញ្ជីសារពើភណ្ឌអំពីការសិក្សាលើខ្សែចង្វាក់ម្លៃថ្មីៗ និងដែលមានក្នុងបច្ចុប្បន្ននេះ។

ជាមួយនឹងគម្រោងពាណិជ្ជកម្មរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានបញ្ចប់ នៅក្នុងខែធ្នូ ឆ្នាំ២០១០នោះ គោលដៅទាំង ៤ គឺពិតជាមានមហិច្ឆតាលើសពីអ្វីដែលអាចសម្រេចបានពិតប្រាកដ។ នៅក្នុងការអនុវត្តជាក់ស្តែងការផ្តោតជាសំខាន់របស់អង្គភាពខ្សែចង្វាក់តម្លៃ (VCU) ដែលទើបតែបង្កើតថ្មី គឺទៅលើគោលដៅទី ១ និង ២ ដូចជា ៖

- ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលអំពីបច្ចេកទេស និងឧបករណ៍ស្រាវជ្រាវខ្សែចង្វាក់តម្លៃ
- ការរៀបចំកម្រងសំណួរស្ទាបស្ទង់មតិតាមមូលដ្ឋាន
- ការបង្កើតគំរូតាមប្រភេទសម្រាប់ការសិក្សាតាមវិស័យ និង
- ការបញ្ចប់ការសិក្សាអំពីខ្សែចង្វាក់តម្លៃទាំង ៣ ដូចជា អង្ករ ដំឡូងមី និងគ្រាប់ស្វាយចន្ទី។

## ៣.៣ ការសម្របសម្រួល និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល

ផ្តើមចេញពីក្រុមការងារអង្គភាពខ្សែចង្វាក់តម្លៃ (VCU) ដំបូងដែលមានបុគ្គលិក ៥រូប មកពីនាយកដ្ឋានជំរុញពាណិជ្ជកម្ម (TPD) ក្រសួងពាណិជ្ជកម្មបានសម្រេចពង្រីកការបណ្តុះបណ្តាលទៅដល់ក្រុមមនុស្សកាន់តែធំជាងមុន ឬ "ក្រុមការងារស្រាវជ្រាវរបស់ក្រសួងពាណិជ្ជកម្ម (MoC)" ដែលមានមនុស្សពី ២០ ទៅ ៣០ នាក់។ ដោយសារតែមានការបណ្តុះបណ្តាលដល់ក្រុមមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម (MoC) កាន់តែច្រើនអំពីបច្ចេកទេស និងវិធីសាស្ត្រសិក្សាអំពីខ្សែចង្វាក់តម្លៃមូលដ្ឋាន ព្រមទាំងអំពីប្រភពទិន្នន័យ និងការប្រមូលទិន្នន័យច្រើនជាងផែនការកាលពីដំបូង ទើបតម្រូវឲ្យមានការប្តេជ្ញាចិត្តកាន់តែច្បាស់លាស់ និងមានរយៈពេលកាន់តែវែងពីមន្ត្រីនៅក្នុងអង្គភាពខ្សែចង្វាក់តម្លៃ (VCU) ឲ្យផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើតការសិក្សាមូលដ្ឋាន និងការផ្សព្វផ្សាយព័ត៌មាន។ ការប្តេជ្ញាចិត្តគឺនៅមិនទាន់ច្បាស់លាស់ពេញលេញនៅឡើយទេ ដូចជា ការបែងចែកតួនាទីផ្សេងគ្នារបស់ក្រុមការងារអង្គភាពខ្សែចង្វាក់តម្លៃ (VCU) ដំបូងនិង "ក្រុមការងារស្រាវជ្រាវធំជាងមុនរបស់ក្រសួងពាណិជ្ជកម្ម (MoC)" ឬ បញ្ចូលក្រុមការងារទាំងពីរឲ្យទៅជាអង្គភាពខ្សែចង្វាក់តម្លៃ (VCU) ធំតែមួយ។

ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការអន្តរក្រសួងលើការស្រាវជ្រាវខ្សែសង្វាក់តម្លៃ និងការបង្កើតរូបមន្តយុទ្ធសាស្ត្រខ្សែចង្វាក់តម្លៃនៅក្នុងចំណោមខ្សែបណ្តោយអន្តរក្រសួងសំខាន់ៗព្រមទាំងនៅក្នុងចំណោមដៃគូអភិវឌ្ឍន៍នឹងតម្រូវឲ្យមានការធ្វើឲ្យប្រសើរឡើង និងអនុវត្តឲ្យស៊ីជម្រៅឆ្ពោះទៅធានាឲ្យបាននូវការងារប្រកបដោយគុណភាព។ នៅក្នុងរយៈពេលខ្លីនេះការចែករំលែកព័ត៌មាន និងទិន្នន័យ គឺមានកម្រិតតិចតួចយ៉ាងខ្លាំងរវាងក្រសួងពាណិជ្ជកម្ម (MoC) (ដែលផ្តោតលើពាណិជ្ជកម្ម) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) (ដែលផ្តោតលើផលិតកម្ម) នៅក្នុងវិស័យនាំចេញជាច្រើនដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០០៧ (CTIS 2007)*។ ចាំបាច់ត្រូវមានយន្តការនានាដើម្បី គាំទ្រដល់កិច្ចសហប្រតិបត្តិការនេះ។ ការពង្រឹងយន្តការនៅក្នុងសសរស្តម្ភទី ២ ដែលតម្រូវឲ្យមានការសម្របសម្រួលកាន់តែប្រសើរឡើងនៅក្នុងក្រសួងនានា គួរតែមានឥទ្ធិពលវិជ្ជមានទៅលើការងារនេះ។ ការសម្របសម្រួលនៅក្នុងចំណោមដៃគូអភិវឌ្ឍន៍និងរវាងក្រសួងទាំងឡាយនិងរដ្ឋាភិបាលនៅមានកម្រិតតិចតួចនៅឡើយ ហើយនឹងតម្រូវឲ្យធ្វើការកែប្រែ។

## ៣.៤ ជំនួយសម្រាប់ពាណិជ្ជកម្ម

ការបង្កើតដំបូងនូវអង្គភាពខ្សែសង្វាក់តម្លៃ(VCU)ត្រូវបានផ្តល់មូលនិធិឲ្យតាមរយៈគម្រោងពាណិជ្ជកម្មរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ នាយកដ្ឋានជំរុញពាណិជ្ជកម្ម (TPD) បានបញ្ជូនគម្រោងតាមដានរយៈពេល ១ឆ្នាំ ទៅឲ្យមូលនិធិសង្គមម្ចាស់ជំនួយពហុភាគីនៃកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) នៃអភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp)(៣៣)។ សំណើនេះត្រូវបានឯកភាពសម្រាប់ការផ្តល់មូលនិធិដោយកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP)។ ប៉ុន្តែវានឹងតម្រូវឲ្យមានការប្តេជ្ញាចិត្តសម្រាប់រយៈពេលកាន់វែងពីអ្នកផ្តល់ជំនួយ ឬ ក្រុមអ្នកផ្តល់ជំនួយដើម្បីជួយក្រសួងពាណិជ្ជកម្ម (MoC) ឲ្យបង្កើតអង្គភាពមួយប្រកបដោយចីរភាព។ វាក៏នឹងមានការប្រែប្រួលចំពោះឥរិយាបទមួយផ្នែករបស់ដៃគូអភិវឌ្ឍន៍ (PD) ផងដែរ។

ការសិក្សាអំពីខ្សែចង្វាក់តម្លៃយ៉ាងច្រើនលើវិស័យនាំចេញសំខាន់ៗរបស់ប្រទេសកម្ពុជាត្រូវបានរៀបចំឡើងកាលពីពេលមុនដោយដៃគូអភិវឌ្ឍន៍ (PD) ហើយជាញឹកញាប់វាត្រួតគ្នា និងមានការសម្របសម្រួលតិចតួច។ ប្រសិនបើដៃគូអភិវឌ្ឍន៍ (PD) មានភាពច្បាស់លាស់ចំពោះ

(៣៣) TDSP, ឬ កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម ត្រូវបានរៀបចំឡើងដើម្បីគាំទ្រវត្ថុបំណងមួយចំនួនរបស់ SWAp ពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងត្រូវបានអនុវត្តដោយ MoC។ កម្មវិធីត្រូវបានផ្តល់មូលនិធិដោយមូលនិធិក្នុងអាណត្តិព្យបាលភាពរបស់អ្នកផ្តល់ជំនួយពហុភាគី (MDTF) ដែលគ្រប់គ្រងដោយធនាគារពិភពលោក និងផ្តល់មូលនិធិដោយ EU, Danida និង UNIDO.

អនុសាសន៍នានាដែលពួកគេបានផ្តល់ឲ្យក្នុងអំឡុងសិក្ខាលាលារបស់ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) នៅខែកញ្ញា ឆ្នាំ២០០៧ ដែលបានពិភាក្សាពីខាងដើម ពួកគេនឹងត្រូវផ្សារភ្ជាប់ការងារវិភាគខ្សែចង្វាក់ម្លៃរបស់ពួកគេឲ្យកាន់តែជិតស្និទ្ធខ្លាំងទៅនឹងការងាររបស់អង្គភាពខ្សែចង្វាក់តម្លៃ (VCU) ដោយប្រើប្រាស់វាជាឱកាសដើម្បីកសាងសមត្ថភាពនៅក្នុងអង្គភាពខ្សែចង្វាក់តម្លៃ (VCU)។ ការងារនេះគឺស្ថិតនៅឆ្ងាយពីករណីនាពេលបច្ចុប្បន្ន។ ជាក់ស្តែង មានឧទហរណ៍ពីរក្នុងចំណោមឧទាហរណ៍ជាច្រើននាពេលបច្ចុប្បន្ន គឺការរៀបចំឯកសារគោលនយោបាយស្តីពីការនាំចេញអង្ករ ដែលអនុម័តនាពេលថ្មីៗនេះដោយគណៈរដ្ឋមន្ត្រី[៣៤] ទាមទារឲ្យមានការស្រាវជ្រាវខ្សែចង្វាក់តម្លៃឡើងវិញក្រោមការផ្តល់មូលនិធិរបស់អ្នកផ្តល់ជំនួយ ដែលភាគច្រើនក្នុងចំណោមព័ត៌មាននេះអាចទទួលបានយ៉ាងងាយពីការងារដែលអង្គភាពខ្សែចង្វាក់តម្លៃ (VCU) កំពុងតែធ្វើលើផ្នែកអង្ករ។ ដូចគ្នានេះដែរការសិក្សាអំពីខ្សែចង្វាក់តម្លៃស្រដៀងគ្នាចំនួន ២ អំពីគ្រាប់ស្វាយចន្ទីត្រូវបានរៀបចំឡើងនៅក្នុងអំឡុងឆ្នាំ ២០១០ ដោយមានការចែករំលែកព័ត៌មានក្នុងកម្រិតបន្តិចបន្តួចរហូតដល់គ្មានតែម្តងដោយរាប់បញ្ចូលទាំងការសិក្សាមួយដែលធ្វើឡើងដោយអង្គភាពខ្សែចង្វាក់តម្លៃ (VCU) ផងដែរ។

## ៣.៥ ការកាត់បន្ថយកត្តាពីខាងក្រៅ

ក្រៅពីការប្តេជ្ញាចិត្តដ៏ច្បាស់លាស់ផ្នែកស្ថាប័ន និងធនធានមនុស្សចំពោះអង្គភាពខ្សែចង្វាក់តម្លៃ (VCU) ពីសំណាក់ក្រសួងពាណិជ្ជកម្ម (MoC) កត្តាពីខាងក្រៅដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលក្នុងការសម្រាលបន្ទុកនោះ គឺការតម្រូវឲ្យក្រសួងពាណិជ្ជកម្ម (MoC) ធ្វើការធានាឲ្យមានធនធានជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) រយៈពេលយូរអង្វែង ដែលចាំបាច់សម្រាប់បង្កើតអង្គភាពដែលមានចីរភាពពិតប្រាកដមួយដែលមានសមត្ថភាពផលិត និងផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាពខ្ពស់។ ក្រសួងពាណិជ្ជកម្ម (MoC) ក៏នឹងចាំបាច់ត្រូវធានាឲ្យបាននូវការប្តេជ្ញាចិត្តកាន់តែខ្លាំងក្លាពីដៃគូអភិវឌ្ឍន៍ដែលបច្ចុប្បន្នមានការពាក់ព័ន្ធទៅនឹងការងារខ្សែចង្វាក់តម្លៃ និងការស្រាវជ្រាវខ្សែចង្វាក់តម្លៃដើម្បីភ្ជាប់ទំនាក់ទំនងការងាររបស់ពួកគេឲ្យកាន់តែជិតស្និទ្ធទៅនឹងតម្រូវការក្នុងការអភិវឌ្ឍសមត្ថភាព របស់ក្រសួងពាណិជ្ជកម្ម (MoC) នៅក្នុងផ្នែកនេះ។

# ៤ លទ្ធផលដែលសម្រេចបាន - ប្រសិទ្ធភាពដែលអាចវាស់វែងបាន

វាហាក់ដូចជាឆាប់រហ័សពេកក្នុងការអភិវឌ្ឍសមត្ថភាពផ្នែកខ្សែចង្វាក់តម្លៃ និងព័ត៌មានពាណិជ្ជកម្មនៅក្នុងក្រសួងពាណិជ្ជកម្ម (MoC) ឲ្យមានលទ្ធភាពកំណត់ពីឥទ្ធិពលមួយដែលអាចវាស់វែងបាន។ ការងារនេះ លើកលែងតែការបង្កើតអង្គភាពខ្សែចង្វាក់តម្លៃ (VCU) និងការគាំទ្រដំបូងគួរតែមានកិច្ច ពិភាក្សារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទៅលើចំណុចដែលត្រឹមត្រូវដើម្បីផលិតព័ត៌មានអំពីខ្សែចង្វាក់តម្លៃ និងពាណិជ្ជកម្ម ហើយជាវិធីល្អបំផុតដែលត្រូវធ្វើកិច្ចការនេះ ដើម្បីឲ្យរដ្ឋាភិបាលមានសមត្ថភាពខ្ពស់ក្នុងដំណើរការនេះ។

នៅក្នុងរយៈពេលមធ្យមនិងរយៈពេលវែងសមត្ថភាពរឹងមាំផ្នែកចង្វាក់តម្លៃនិងព័ត៌មានអំពីពាណិជ្ជកម្មនៅក្នុងក្រសួងពាណិជ្ជកម្ម(MoC) អាចបម្រើឲ្យដំណើរការយ៉ាងច្រើន ៖

- អាចបង្កើតព័ត៌មានដែលអាចផ្សព្វផ្សាយដោយមានសារៈប្រយោជន៍ចំពោះអាជីវកម្ម
- អាចបង្កើតព័ត៌មានដែលអាចប្រើប្រាស់ដោយដៃគូអភិវឌ្ឍន៍ រដ្ឋាភិបាល និងវិស័យអាជីវកម្ម នៅក្នុងបរិបទនៃសរសរស្តម្ភទី ២ ដើម្បីរៀចំផែនការជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) បន្ថែមសម្រាប់ខ្សែចង្វាក់តម្លៃនៃការនាំចេញ
- អាចបង្កើតព័ត៌មានមួយចំនួនដែលរដ្ឋាភិបាលត្រូវការដើម្បីបង្កើតរូបមន្តគោលនយោបាយតាមវិស័យ ដូចជាគោលនយោបាយដែលគេប្រើបច្ចុប្បន្នសម្រាប់អង្ករ ជាដើម
- អាចបង្កើតព័ត៌មានដែលរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍អាចប្រើប្រាស់ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការរីកចម្រើនដែលធ្វើឡើងស្ថិតក្រោមវត្ថុបំណងរបស់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp)។

# ៥ បទពិសោធន៍ដែលទទួលបាន

វាក៏ជាការឆាប់រហ័សពេកដែរដែលត្រូវទទួលបានបទពិសោធន៍ជាច្រើនពីការងារដំបូងរបស់អង្គភាពខ្សែចង្វាក់តម្លៃ(VCU)ព្រោះដូចបានបញ្ជាក់ហើយថា ការកសាងសមត្ថភាពត្រូវការពេលវេលា ជាពិសេសនៅពេលដែលខ្លួនព្យាយាមអភិវឌ្ឍសមត្ថភាពថ្មីដែលមិនធ្លាប់មានពីមុនមក។ ករណីនេះអាចជាបញ្ហាប្រឈមសម្រាប់រដ្ឋាភិបាលនៅពេលដែលជួបប្រទះជាមួយនឹងដៃគូផ្តល់ជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) ដែលទាមទារឲ្យសម្រេចបានលទ្ធផល និងប្រសិទ្ធភាពក្នុងរយៈពេលកាន់តែខ្លីនោះ។

[៣៤] រាជរដ្ឋាភិបាលកម្ពុជា គណៈរដ្ឋមន្ត្រី ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ អនុម័តនៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១០។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ១៥៧ MOC / SM 2010

# ប្រកាស
## ស្តីពីការ
## បង្កើតក្រុមការងារសម្រាប់រៀបចំឯកសារស្តីពីការអនុវត្តជំនួយពាណិជ្ជកម្មនៅកម្ពុជា
(Case Story of Aid for Trade)

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
-យោងអនុស្សរណៈយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីសេវាកម្មគម្រោង ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០
-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតក្រុមការងារប្រមូលព័ត៌មាន និងចងក្រងឯកសារស្តីពីលទ្ធផល និងសមិទ្ធិផលទទួលបានពីការអនុវត្តជំនួយបច្ចេកទេសពាណិជ្ជកម្មនៅកម្ពុជា (ជាឯកសារពហុព័ត៌មាន Multimedia) សម្រាប់ដាក់ជូនសន្និបាទសកលលោកលើកទី ៣ ស្តីពី "ការពិនិត្យឡើងវិញជំនួយសម្រាប់ពាណិជ្ជកម្ម (Third Global Review of Aid for Trade)" ដែលមានសមាសភាព ដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | នាយកគម្រោងការពង្រឹងសមត្ថភាពសមាហរណកម្មពាណិជ្ជកម្ម | ប្រធាន |
| ២. | ឯកឧត្តម | **សុខ សុភ័ក្រ្ត** | អគ្គនាយកពាណិជ្ជកម្មពាណិជ្ជកម្មអន្តរជាតិ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ពេជ ឫទ្ធី** | អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |

ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ : (៨៥៥ -២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥ -២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

| | | | | |
|---|---|---|---|---|
| ៤. | លោក | **សួន ប្រសិទ្ធ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥. | លោក | **ផាន់ យុវរដ្ឋ** | អនុប្រធាននាយកដ្ឋានផ្ទៀងផ្ទាត់ច្បាប់ និងផ្តល់ព័ត៌មាន | សមាជិក |
| ៦. | លោក | **ស៊ឹម សុខខេង** | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |

**ប្រការ ២.-**

ក្រុមការងារត្រូវអនុវត្តន៍តាមភារកិច្ចដូចខាងក្រោមៈ

ក. ប្រមូលព័ត៌មានស្តីពីការអនុវត្តគម្រោងជំនួយបច្ចេកទេសពាក់ព័ន្ធនិងពាណិជ្ជកម្មនៅកម្ពុជា និងលទ្ធផលទទួលបានពី ការវាយតម្លៃនៃប្រសិទ្ធភាពអនុវត្តន៍គម្រោង,

ខ. ធ្វើទំនាក់ទំនងជាមួយក្រសួង-ស្ថាប័ននានា និងជាមួយវិស័យឯកជន ដែលបាននិងកំពុងអនុវត្តន៍គម្រោងជំនួយបច្ចេក ទេសពាណិជ្ជកម្ម ដើម្បីប្រមូលឯកសារ រូបថត ប័ណ្ណផ្សព្វផ្សាយ ទស្សនាវដ្តី ហើយពិភាក្សាជាមួយអង្គភាព សាមី ដើម្បីឯកភាពជាគោលការណ៍មុនយកព័ត៌មានទាំងនោះទៅធ្វើការចងក្រងបោះពុម្ពផ្សាយ,

គ. ចងក្រងជាឯកសារគោល ដោយឈរលើមូលដ្ឋាននៃមាតិការបានផ្តល់ដោយគណៈកម្មាធិការស្តីពីពាណិជ្ជកម្មនិងការ អភិវឌ្ឍន៍ជំនួយសម្រាប់ពាណិជ្ជកម្មនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) និង OECD,

ឃ. រាល់ចំណាយសម្រាប់ជួលទីប្រឹក្សា ចងក្រង និងបោះពុម្ពឯកសារត្រូវយកថវិកាពីគម្រោងពង្រឹងសមត្ថភាពសមាហរណកម្មពាណិជ្ជកម្ម (Enhanced Integrated Framework) មកប្រើប្រាស់,

ង. ក្រុមការងារ ត្រូវរៀបចំបោះពុម្ពឯកសារសកម្មភាពនេះតាមកាលបរិច្ឆេទបានកំណត់ដោយស្ថាប័ន WTO/OECD បន្ទាប់ពីទទួលបានការឯកភាពពីអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងពាណិជ្ជកម្ម និងពីក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងសាមីខ្លួន ត្រូវអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ខែ ធ្នូ ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចំលងជូន</u>**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- អង្គការសហប្រជាជាតិស្តីពីសេវាកម្មគម្រោង UNOPS
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

**Ministry of Commerce**
Address: Lot 19-61, MoC Road (113B Road),
Phum Teuk Thla, Sangkat. Teuk Thla, Khan Sen
Sok, Phnom Penh, Kingdom of Cambodia

Tel: (855) 23 866 088 / 866 478
Fax: (855) 23 866 188 / 866 425
Email: moccab@moc.gov.kh
Website: www.moc.gov.kh

**CAMBODIA Trade Sector Wide Approach**
**Ministry of Commerce**
Department of International Cooperation (D/ICO)
Secretariat of Trade SWAp

Address: Lot 19-61, MoC Road (113B Road), Phum
Teuk Thla, Sangkat. Teuk Thla, Khan Sen Sok,
Phnom Penh, Kingdom of Cambodia

Tel: (855) 23 866 064
Fax: (855) 23 866 074
www.moc.gov.kh/tradeswap